សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Royal University of Law and Economics


**សារណាបញ្ចប់ការសិក្សា**

# ប្រតិបត្តិការលក់ទិញចលនវត្ថុដោយបង់រំលស់

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ល. ម៉ូវ សុខមាន**

**ក. ឃាន ហ្គិចហ័ង**

សាស្ត្រាចារ្យណែនាំ

**លោក គង់ សុភ័ក្រ្ត**


ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# **សេចក្តីថ្លែងអំណរគុណ**

នាងខ្ញុំ **ឃាន ហ្គិចហ័ង** និងខ្ញុំបាទ **ម៉ុច សុខមាន** ជានិស្សិតផ្នែកនីតិសាស្ត្រជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

*ជាបឋមយើងខ្ញុំសូមលំអានកាយវាចាចិត្ត សំដែងនូវភាពកតញ្ញូតាធម៌ និងគោរពដឹងគុណដ៏ជ្រាលជ្រៅបំផុតចំពោះ ៖*

១. លោកឪពុកអ្នកម្តាយ ដែលបានផ្តល់កំណើតដល់រូបកូន ចិញ្ចឹមបីបាច់ថែរក្សាយ៉ាងយកចិត្តទុកដាក់ អប់រំទូន្មានកូនប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងជួយផ្គត់ផ្គង់ទំនុកបម្រុង និងធ្វើពលីកម្មគ្រប់បែបយ៉ាង ដើម្បីផ្តល់ឱកាសឱ្យកូនបានបន្តការសិក្សារៀនសូត្រតាំងពីបឋមវ័យ រហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ដោយទទួលបានចំណេះដឹងយ៉ាងថ្លាថ្លៃ និងពុំអាចកាត់ថ្លៃបាន។

២. ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រីសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយសម្របសម្រួល ខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការបង្ហាត់បង្រៀន ផ្តល់នូវចំណេះដឹងដល់រូបយើងខ្ញុំ ព្រមទាំងបំណិនជីវិតផ្សេងៗក្នុងរយៈពេលបួនឆ្នាំ នៃការសិក្សាថ្នាក់បរិញ្ញាបត្រជំនាញផ្នែកនីតិសាស្ត្រកន្លងមកនេះ។

៣. លោក **សាស្ត្រាចារ្យ គង់ សុភ័ក្ត្រ** និងជាសាស្ត្រាចារ្យណែនាំ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការផ្តល់នូវអនុសាសន៍ល្អៗ និងចង្អុលបង្ហាញពីចំណុចសំខាន់នៃការស្រាវជ្រាវ។

៤. មួយវិញទៀត យើងខ្ញុំទាំងពីរនាក់ក៏សូមអរគុណ ចំពោះសិស្សច្បង និងមិត្តភក្តិទាំងអស់ដែលតែងតែផ្តល់ជាគំនិតយោបល់ល្អៗ និងលើកទឹកចិត្តក្នុងការសរសេរសារណានេះ។

ជាចុងបញ្ចប់ យើងខ្ញុំសូមលំឱនកាយគោរពដោយសេចក្តីដឹងគុណដល់អ្នកមានគុណដែលបានរៀបរាប់ខាងលើ សូមឱ្យលោកជួបតែពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សម័យកាលសម្ភារៈនិយម ឧបករណ៍ទំនើបៗកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ តម្រូវការរបស់មនុស្សក៏កាន់តែច្រើនឡើងមិនថាអ្នកដែលមាន ឬគ្មានលទ្ធភាពគ្រប់គ្រាន់នោះទេ សុទ្ធតែត្រូវការឧបករណ៍ប្រើប្រាស់ដែលមានបច្ចេកវិទ្យាទំនើប ផ្តល់នូវលក្ខខណៈងាយស្រួល និងរហ័ស ដើម្បីជួយសម្រាលការងាររបស់ពួកគេ។ មិនតែប៉ុណ្ណោះ ពួកគេអាចទិញឧបករណ៍ទាំងអស់នោះផ្តាច់តែម្តង ឬបង់រំលស់ក៏បាន។

អត្ថបទសារណាស្តីពី **"ប្រតិបត្តិការលក់ទិញចលនវត្ថុដោយបង់រំលស់"** ជាសញ្ញាណថ្មីមួយដែលពុំទាន់ត្រូវបានសិក្សាទូលំទូលាយនៅក្នុងបរិបទនៃព្រះរាជាណាចក្រកម្ពុជានៅឡើយ។ ការសម្រេចលើកយកប្រធានបទខាងលើមកសិក្សាស្រាវជ្រាវ ព្រោះការមើលឃើញពីការរីកលូតលាស់យ៉ាងឆាប់រហ័សនៃការលក់ទិញដោយបង់រំលស់ និងដើម្បីសិក្សាស្វែងយល់អំពីវិធានគតិយុត្ត ព្រមទាំងចំណុចខ្វះខាតមួយចំនួនដែលមានអានុភាពលើសកម្មភាពបង់រំលស់ចលនវត្ថុនេះ។ "ការបង់រំលស់" ជាបរិបទថ្មីមួយនៃការរស់នៅរបស់ប្រជាជនកម្ពុជានាពេលសព្វថ្ងៃនេះ ស្ទើរតែគ្រប់ផលិតផលទាំងអស់ទៅហើយដែលត្រូវបានដាក់លក់ដោយបង់រំលស់។ ការលក់ទិញចលនវត្ថុដោយការបង់រំលស់នាពេលបច្ចុប្បន្នមានភាពពេញនិយមយ៉ាងខ្លាំង ព្រោះវាបានផ្តល់នូវលក្ខណៈងាយស្រួល ព្រមទាំងគុណប្រយោជន៍ដល់គូភាគី។ បើទោះបីជាបានផ្តល់នូវគុណប្រយោជន៍ដល់គូភាគីពិតមែន ក៏វានៅតែមានហានិភ័យមួយចំនួនកើតឡើង ដោយសារការមិនទាន់យល់ដឹងឱ្យបានទូលំទូលាយអំពីវិធានច្បាប់ដែលត្រូវយកមកអនុវត្ត ហើយការអនុវត្តមិនបានត្រឹមត្រូវតាមវិធានដែលច្បាប់បានកំណត់អាចបណ្តាលឱ្យគូភាគីបាត់បង់នូវការការពារពីច្បាប់ពិសេសណាមួយឡើយ។ ដូច្នេះ ក្នុងអត្ថបទសារណានេះនឹងបង្ហាញអ្នកអំពីវិធានគតិយុត្ត ការអនុវត្ត និងបញ្ហាប្រឈមផ្សេងៗដែលនឹងកើតមានឡើងក្នុងសកម្មភាពនៃការបង់រំលស់ចលនវត្ថុ។

អំឡុងពេលនៃការតាក់តែងអត្ថបទសារណាមួយនេះឡើង គឺស្ថិតនៅក្នុងឆ្នាំ២០២១ ដែលសកលលោកព្រមទាំងកម្ពុជាផងដែរ បាននឹងកំពុងជួបប្រទះនូវជម្ងឺដ៏កាចសាហាវគឺ កូវីដ១៩ បណ្តាលឱ្យគ្រឹះស្ថានសិក្សា និងទីកន្លែងមួយចំនួនត្រូវបានបិទ។ ក្នុងស្ថានភាពបែបនេះ បានផ្តល់នូវផលលំបាកដល់យើងខ្ញុំក្នុងការស្រាវជ្រាវប្រភពឯកសារសំខាន់ៗនៅតាមទីកន្លែងផ្សេងៗ ដូចជា ការចុះកម្មសិក្សានៅតាមក្រសួង ឬស្ថាប័នដែលពាក់ព័ន្ធហាងលក់ទិញទំនិញដែលអនុញ្ញាតឱ្យមានការបង់រំលស់ គ្រឹះស្ថានហិរញ្ញវត្ថុ បណ្ណាល័យជាដើម។ នៅក្នុងបរិបទនេះ បានកំណត់ឱ្យយើងខ្ញុំរុករកប្រភពឯកសារ តាមរយៈបណ្តាញអ៊ិនធឺណេត ពិគ្រោះ និងផ្តោះផ្តល់យោបល់ពីអ្នកជំនាញនានាពីចម្ងាយ។ ម្យ៉ាងវិញទៀត ដោយសារវាជាប្រធានបទថ្មី ហើយសញ្ញាណនៃប្រធានបទនេះទៀតសោត ពុំសូវមានអ្នកជំនាញផ្តល់ជាមតិយោបល់ ឬបកស្រាយអ្វីឡើយ។ ការតាក់តែងអត្ថបទសារណានេះផង

ដែរ គឺពឹងផ្អែកទាំងស្រុងទៅលើការអានអត្ថបទពាក់ព័ន្ធនានាដើម្បីទុកជាមូលដ្ឋានជំនួយស្មារតី ដោយឯកសារមួយចំនួនជាភាសារខ្មែរ និងមួយចំនួនទៀតធ្វើការប្រែសម្រួលដោយក្រុមការងារតាក់តែងច្បាប់។

ជាចុងក្រោយ យើងខ្ញុំសង្ឃឹមជឿជាក់ថា សមិទ្ធផលដ៏តូចមួយនេះ នឹងបានចូលរួមចំណែកផ្តល់នូវអត្ថប្រយោជន៍ខ្លះដល់អ្នកសិក្សាស្រាវជ្រាវដទៃទៀតពាក់ព័ន្ធនឹង "ប្រតិបត្តិការលក់ទិញចលនវត្ថុដោយបង់រំលស់" ឱ្យកាន់ស៊ីជម្រៅអំពីការប្រើប្រាស់ និងការអនុវត្តទៅថ្ងៃអនាគត។ យើងខ្ញុំទាំងពីរនាក់ សូមមេត្តាខន្តីអភ័យទោសចំពោះរាល់កំហុសខុសឆ្គងដោយអចេតនាក្នុងការតាក់តែងអត្ថបទសារណានេះ ហើយក៏សូមស្វាគមន៍នូវរាល់មតិរិះគន់ពីសំណាក់បញ្ញវ័ន្តគ្រប់រូប និងមិត្តអ្នកអានទាំងអស់ ដើម្បីចូលរួមកែសម្រួល និងបំពេញបន្ថែមនូវចំណុចខ្វះខាតទាំងឡាយ ជាបច្ច័យកែលម្អសមិទ្ធិផលថ្មីមួយនេះឱ្យកាន់តែល្អប្រសើរឡើងថែមមួយកម្រិតទៀត។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម**............................................................................................................................... ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃការលក់ទិញចលនវត្ថុដោយបង់រំលស់**

១.១ សញ្ញាណទូទៅនៃការបង់រំលស់ ................................................................................................. ៣

១.១.១ អត្ថន័យនៃការបង់រំលស់............................................................................................... ៣

១.១.២ អត្ថប្រយោជន៍នៃការបង់រំលស់........................................................................................ ៥

១.២ ការជ្រើសរើសគូភាគី និងការជ្រើសរើសប្រតិបត្តិការ............................................................................ ៧

១.២.១ ការជ្រើសរើសភាគី ........................................................................................................ ៧

១.២.២ ការជ្រើសរើសប្រតិបត្តិការ.............................................................................................. ៩

**ជំពូកទី២**

**ការលក់ទិញដោយបង់រំលស់តាមរយៈគតិសន្យាហិរញ្ញវត្ថុ**

២.១ ការបង្កើតកិច្ចសន្យា.................................................................................................................. ១២

២.១.១ លក្ខខណ្ឌអានុភាព ........................................................................................................ ១៣

២.១.២ សិទ្ធិ និងកាតព្វកិច្ចគូភាគី................................................................................................ ១៧

២.២ ការបំពាន និងការសង្គ្រោះកិច្ចសន្យា....................................................................................... ២៦

២.២.១ ការបំពានកិច្ចសន្យា ....................................................................................................... ២៦

២.២.២ ការសង្គ្រោះកិច្ចសន្យា..................................................................................................... ២៩

**ជំពូកទី៣**

**ការលក់ទិញដោយបង់រំលស់តាមរយៈប្រតិបត្តិការដែលមានកិច្ចធានា**

៣.១ ការបង្កើតប្រតិបត្តិការដែលមានកិច្ចធានា ......................................................................................... ៣៥

៣.១.១. លក្ខខណ្ឌនៃការបង្កើតកិច្ចព្រមព្រៀងប្រាតិភោគ ............................................................................ ៣៦

៣.១.២ កម្មវត្ថុនៃទ្រព្យធានា ..................................................................................................... ៣៨

៣.១.២.១ កម្មវត្ថុជាទ្រព្យធានារូបិយ............................................................................................. ៣៩

៣.១.២.២ កម្មវត្ថុជាទ្រព្យអរូបិយ ...... ៤១

៣.១.២.៣ ប្រតិបត្តិការដែលមិនស្ថិតនៅក្រោមប្រតិបត្តិការដែលមានកិច្ចធានា ...... ៤២

៣.២ អានុភាពនៃប្រតិបត្តិការដែលមានកិច្ចធានា ...... ៤៣

៣.២.១ មធ្យោបាយក្នុងការធ្វើសុក្រឹត្យកម្ម ...... ៤៣

៣.២.២ អាទិភាពនៃសុក្រឹត្យកម្ម ...... ៤៧

៣.៣ ការអនុវត្តសិទ្ធិ និងកាតព្វកិច្ច ...... ៤៩

៣.៣.១.២ សិទ្ធិ និងករណីយកិច្ចរបស់កូនបំណុល ...... ៥១

៣.៣.២ កត្តាដែលមានឱ្យសិទ្ធិ និងករណីយកិច្ចរបស់គូភាគីត្រូវបានរំលត់ ...... ៥២

**សេចក្តីសន្និដ្ឋាន** ...... ៥៥

**អនុសាសន៍** ...... ៥៧

**គន្ថនិទ្ទេស**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

នៅលើលោកនេះអ្វីគ្រប់យ៉ាងសុទ្ធតែប្រែប្រួល មានតែការប្រែប្រួលប៉ុណ្ណោះ ដែលមិនប្រែប្រួល។ ច្បាប់និងសង្គមក៏ដូចគ្នាតែងតែមានការប្រែប្រួលពីមួយថ្ងៃទៅមួយថ្ងៃ ពីរបបមួយទៅរបបមួយ។ ប្រទេសកម្ពុជាក្រោយឆ្នាំ១៩៩៣ ក៏បានប្តូររបបសេដ្ឋកិច្ចមកជារបបសេដ្ឋកិច្ចទីផ្សារសេរី។ មនុស្សតែងធ្វើយ៉ាងណាឱ្យការរស់នៅរបស់ខ្លួនកាន់តែមានភាពងាយស្រួល និងល្អប្រសើរជាងមុន ហេតុនេះសកម្មភាពក្នុងការរស់នៅ និងជួញដូរក៏កាន់តែកើតឡើងតាមរបៀបថ្មីៗជាច្រើន ដោយគិតចាប់តាំងពីការប្តូរវត្ថុ និងវត្ថុ ការលក់ទិញ ការខ្ចីបុល រហូតមកដល់ពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជាក៏បានឈានមកដល់ការធ្វើជំនួញបែបទំនើបមួយប្រភេទទៀតគឺ "ការលក់ទិញដោយបង់រំលស់" នេះឯង។ កាលពីមុនបើយើងគ្មានលុយគ្រប់ ឬគ្មានទ្រព្យដាក់ធានាកាតព្វកិច្ចទេ យើងមិនអាចទិញឧបករណ៍ណាមួយយកមកប្រើប្រាស់បាននោះទេ។ ប៉ុន្តែសម័យនេះគឺខុសគ្នា ទោះបីជាយើងមិនមានប្រាក់គ្រប់គ្រាន់ ឬមិនចង់ចំណាយប្រាក់ទាំងអស់ ព្រមទាំងគ្មានទ្រព្យផ្សេងៗដើម្បីដាក់ធានាកាតព្វកិច្ចក៏ដោយ ក៏យើងនៅតែអាចទិញឧបករណ៍ទាំងនោះយកមកប្រើប្រាស់បានដោយរំលស់តម្លៃបន្តិចម្តងៗ។ ការរីកចម្រើននៃវិស័យជំនួញ និងប្រព័ន្ធច្បាប់គ្រប់គ្រងលើសកម្មភាពទាំងនោះហើយបានធ្វើឱ្យទំនុកចិត្តក្នុងការជួញដូរមានការកើនឡើងខ្ពស់ អ្នកមានប្រាក់មិនខ្លាចក្នុងការផ្តល់ហិរញ្ញប្បទាន ឯអ្នកទិញក៏អាចទទួលបានឧបករណ៍យកទៅប្រើប្រាស់បានដោយមានលក្ខណៈងាយស្រួលជាងមុនផងដែរ។

ទន្ទឹមនឹងការរីកច្រើននេះដែល សកម្មភាពទាំងអស់នោះមិនអាចត្រូវបានឃ្លាតចាកឆ្ងាយពីច្បាប់ឡើយ ដោយមើលឃើញពីការវិវត្តនូវសកម្មភាពនេះហើយ ប្រព័ន្ធគតិយុត្តនៅកម្ពុជាក៏បានបង្កើតឱ្យមាន ក្រមរដ្ឋប្បវេណីបែបទំនើបថ្មីមួយនៅឆ្នាំ២០០៧ ព្រមទាំងច្បាប់ពិសេសៗជាច្រើនទាក់ទងនឹងវិស័យឯកជន រួមទាំង ច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ និងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាផងដែរ។ ច្បាប់ទាំងនេះសុទ្ធតែជាវិធាន ដែលជួយបង្កើនសក្តានុពលភាពដល់វិស័យហិរញ្ញប្បទាន ពោលគឺធ្វើយ៉ាងណាដើម្បីលើកស្ទួយ ជម្រុញ និងគាំពារដល់សកម្មភាពក្នុងជីវភាពរស់នៅរបស់បុគ្គលឯកជនឱ្យកាន់តែមានភាពល្អប្រសើរឡើង និងប្រកបដោយសុវត្ថិភាពក្នុងកិច្ចការជំនួញនេះផងដែរ។

ទោះបីជា សកម្មភាពការលក់ទិញដោយបង់រំលស់មើលទៅសុទ្ធតែដូចគ្នាក៏ពិតមែន តែមិនប្រាកដថា វាត្រូវបានគ្រប់គ្រងឱ្យស្ថិតនៅក្រោមវិធានដូចគ្នាទាំងអស់នោះទេ។ ដូច្នេះហើយ គូភាគី ឬប្រតិបត្តិករទាំងអស់ត្រូវស្វែងយល់ថា តើច្បាប់បានកំណត់អំពីប្រតិបត្តិការលក់ទិញចលនវត្ថុដោយបង់រំលស់នៅកម្ពុជាយ៉ាងដូចម្តេចខ្លះ? ហើយ វិធាននីមួយៗបានផ្តល់នូវផលប្រយោជន៍អ្វីខ្លះដល់គូភាគី?

ការលក់ទិញដោយបង់រំលស់នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ត្រូវបានគ្រប់គ្រងដោយសញ្ញាណគតិយុត្តផ្សេងៗគ្នា មានទាំងក្រមរដ្ឋប្បវេណី ដែលជាច្បាប់សារធាតុ និងច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ ព្រមទាំងច្បាប់ស្តីពី

ប្រតិបត្តិការដែលមានកិច្ចធានា ដែលជាបទប្បញ្ញត្តិពិសេស។ ទោះជាយ៉ាងណាក៏ដោយ ការសិក្សានៅពេលនេះ គឺផ្តោត សំខាន់តែទៅលើច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ និងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ដែលជាវិធាន ពិសេស ឯសញ្ញាណនៃក្រមរដ្ឋប្បវេណី គឺមិនត្រូវបានលើកយកមកសិក្សាលម្អិតនោះទេ ពោលគឺសិក្សាតែចំណុច ដែលមាន ទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងច្បាប់ពិសេសតែប៉ុណ្ណោះ។

ដើម្បីធ្វើការសិក្សាលើបញ្ហាគតិយុត្តទាំងអស់នេះ យើងខ្ញុំសូមជ្រើសរើសយកការស្រាវជ្រាវតាមរយៈឯក សារដែលមានដូចជា៖

- ការសិក្សាលើមាត្រានៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ និងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា
- អត្ថបទជំនួយស្មារតីជាភាសាជាតិ និងឯកសារពាក់ព័ន្ធនឹងការអនុវត្តច្បាប់ពិសេសទាំងពីរនេះ

ដោយហេតុថាប្រធានបទនេះជាប្រធានដែលមានសញ្ញាណគតិយុត្តពិសេស យើងខ្ញុំសូមធ្វើការបែងចែង ការសិក្សាលើប្រធានបទនេះជាបីជំពូក គឺ

**ជំពូកទី ១៖ សញ្ញាណទូទៅនៃលក់ទិញចលនវត្ថុដោយបង់រំលស់**

**ជំពូកទី ២៖ ការលក់ទិញដោយបង់រំលស់តាមរយៈច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ**

**ជំពូកទី ៣៖ ការលក់ទិញដោយបង់រំលស់តាមរយៈច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា**

# ជំពូកទី១
# សញ្ញាណទូទៅនៃការលក់ទិញចលនវត្ថុដោយបង់រំលស់

## ១.១ សញ្ញាណទូទៅនៃការបង់រំលស់

ទោះស្ថិតក្នុងស្ថានភាពជាប្រទេសកំពុងអភិវឌ្ឍពិតមែន ក៏កម្ពុជានៅតែបន្តការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ជាពិសេស វិស័យពាណិជ្ជកម្ម ដែលកម្ពុជាបានឈានមកដល់ការផ្តល់ហិរញ្ញប្បទានទាំងលើ បុគ្គល អចលនវត្ថុ រហូតដល់ ចលនវត្ថុទៀតផង។ ក្នុងចំណោមការផ្តល់ហិរញ្ញប្បទានខាងលើ ចលនវត្ថុ ជាសញ្ញាណថ្មីមួយសម្រាប់កម្ពុជា ហើយវាទើបមានសន្ទុះខ្លាំងនាប៉ុន្មានឆ្នាំចុងក្រោយនេះ ប៉ុន្តែនៅបណ្តាប្រទេសឧស្សាហកម្មភាគច្រើន គឺបានដំណើរការល្អជាយូរណាស់មកហើយ។ យើងឃើញថា សកម្មភាពពាណិជ្ជកម្មបែបទំនើបជាច្រើនក៏ត្រូវបានកកើតឡើងដើម្បីបំពេញ និងដណ្តើមចំណែកទីផ្សារផងដែរ។ សកម្មភាពបែបថ្មីនោះក៏មានជាការលក់ទិញទំនិញចលនវត្ថុដោយបង់រំលស់ ដែលប្រតិបត្តិការនេះបានបង្កឱ្យមានភាពងាយស្រួលក្នុងការជួញដូររវាងអ្នកលក់ និងអ្នកទិញ។ វាបានធ្វើឱ្យទំហំនៃសកម្មភាពពាណិជ្ជកម្មរបស់កម្ពុជាមានការកើនឡើងតាមរយៈការវិនិយោគពីក្រុមហ៊ុនផ្សេង ដើម្បីបំពេញតម្រូវការរបស់អ្នកប្រើប្រាស់ និងជួយដោះស្រាយនូវវិបត្តិហិរញ្ញវត្ថុកុំឱ្យមានការជាប់គាំងដោយសារពលរដ្ឋគ្មានអចលនវត្ថុគ្រប់គ្រាន់ក្នុងការដាក់ធានាកាតព្វកិច្ច មិនតែប៉ុណ្ណោះ ថែមទាំងបានជួយដល់ការអភិវឌ្ឍផ្នែកឧស្សាហកម្ម និងកសិកម្មទៀតផង។

ទន្ទឹមនឹងភាពរីកចម្រើននៃប្រតិបត្តិការពាណិជ្ជកម្មរបស់ពលរដ្ឋបែបនេះ កម្ពុជាបានបង្កើតឱ្យមានបទប្បញ្ញត្តិពិសេសផ្សេងៗដើម្បីការពារ និងធានាឱ្យបាននូវសិទ្ធិរបស់គូភាគីដែលមាននៅក្នុងទំនាក់ទំនងនៃកិច្ចការជំនួញ ព្រមទាំងធ្វើយ៉ាងណាដើម្បីឱ្យកម្ពុជាមានប្រព័ន្ធច្បាប់បែបទំនើបមួយដែលជាតម្រូវការរបស់ពាណិជ្ជករ ហើយ ក៏ជាមូលដ្ឋានមួយធ្វើឱ្យកម្ពុជាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាភាគីក្នុងអង្គការពាណិជ្ជកម្មពិភពលោកផងដែរ។ ជាទូទៅយើងឃើញថា ការបង់រំលស់ចលនវត្ថុមានភាពខុសៗគ្នា ដូចជាការបង់រំលស់ជាមួយអាជីវករដោយផ្ទាល់ ឬមានការចូលរួមពីគ្រឹះស្ថានធនាគារដើម្បីផ្តល់ហិរញ្ញប្បទាន។ ដូច្នេះហើយ សិទ្ធិនឹងកាតព្វកិច្ចរបស់គូភាគីក៏មានការប្រែប្រួលទៅតាមបទដ្ឋានគតិយុត្តនីមួយៗ។

មូលដ្ឋាននៃសកម្មភាពលក់ទិញចលនវត្ថុដោយបង់រំលស់ទាំងអស់នេះ នឹងត្រូវបានលើកយកមកសិក្សាក្នុងជំពូកនេះ ដោយផ្តោតទៅលើមូលដ្ឋានគតិយុត្ត និងការរៀបចំ ព្រមទាំងអត្ថប្រយោជន៍នៃសកម្មភាពបង់រំលស់ផងដែរ។

### ១.១.១ អត្ថន័យនៃការបង់រំលស់

ប្រសិនបើយើងគិតទៅដល់ពាក្យថា *"បង់រំលស់"* នោះយើងនឹងនឹកឃើញភ្លាមនូវអត្ថន័យថា ជាការបង់ម្តងបន្តិចៗ ដើម្បីឱ្យវារលស់អស់។ បើយើងក្រឡេកមើលអត្ថន័យនៃពាក្យថា *"បង់រំលស់"* នៅក្នុងវចនានុក្រម

សម្តេចសង្ឃរាជ ជួន ណាត គឺមិនមានភាពខុសគ្នាប៉ុន្មាននឹងការយល់ឃើញរបស់យើងទូទៅនោះទេ។ ពាក្យថា *"បង់"* មានន័យថា ចេញប្រាក់ ឬដាក់ប្រាក់តាមកំណត់។ ដូចជា យកប្រាក់ទៅបង់ពន្ធដី។ ចំណែកឯ ពាក្យ *"រំលស់"* មកពីពាក្យថា រម្លស់ មានន័យថា ធ្វើឱ្យលស់ ឬធ្វើឱ្យថយចំនួន។ សម្រាប់អត្ថន័យនៃ *"ការបង់រំលស់"* នៅក្នុងក្របខណ្ឌគតិយុត្តវិញ សំដៅដល់ការអនុវត្តកាតព្វកិច្ចតាមគ្រា ឬតាមការកំណត់របស់គូភាគី។

ជារួម អត្ថន័យនៃពាក្យថា *"បង់រំលស់"* គឺសំដៅដល់ការដាក់ប្រាក់តាមការកំណត់ ដើម្បីឱ្យថយចំនួន ឬធ្វើឱ្យលស់នូវចំនួនប្រាក់ដែលត្រូវបង់ ឬ ជាការអនុវត្តកាតព្វកិច្ចតាមដំណាក់ៗ។ ដូចដែលបានបង្ហាញខាងលើ ការលក់ទិញដោយបង់រំលស់មានលក្ខណៈខុសពី ការលក់ទិញដោយធម្មតា ដោយហេតុថាការលក់ទិញដោយបង់រំលស់ គឺកូនបំណុលត្រូវអនុវត្តកាតព្វកិច្ចម្តងបន្តិចៗ គេមិនបានយកប្រាក់ទៅបង់ដើម្បីទូទាត់ថ្លៃលក់ទិញឱ្យដាច់តែម្តងនោះទេ ពោលគឺគេគ្រាន់តែយកប្រាក់ទៅបង់ដើម្បីបន្ថយថ្លៃទំនិញ ឱ្យនៅសល់បន្តិចម្តងៗ ដើម្បីរំលត់កាតព្វកិច្ចរបស់អ្នកទិញតែប៉ុណ្ណោះ។

**១.១.២ អត្ថប្រយោជន៍នៃការបង់រំលស់**

នៅក្នុងសង្គមមួយប្រជាពលរដ្ឋមិនអាចមានលទ្ធភាពដូចគ្នាទាំងអស់នោះទេ អ្នកខ្លះមានជីវភាពធូរធារ និងអ្នកខ្លះខ្វះខាត លើកលែងតែរបបសមូហភាពប៉ុណ្ណោះ។ បើទោះបីជាយ៉ាងនេះក្តី អ្នកដែលមានជីវភាពធូរធារ ឬអ្នកមាន មិនអាចរស់នៅតែឯងដោយគ្មានការចូលរួម ឬទទួលបានផលប្រយោជន៍ក្នុងជីវភាពរស់នៅប្រចាំថ្ងៃពីអ្នកដែលខ្វះខាត ពោលគឺគេត្រូវការពឹងគ្នាទៅវិញទៅមកដើម្បីធ្វើឱ្យការរស់នៅក្នុងសង្គមមានភាពល្អប្រសើរ និងជួយឱ្យអ្នកខ្វះខាតអាចមានលទ្ធភាពរស់នៅក្នុងសង្គមដូចគ្នាផងដែរ។

ការបង់រំលស់ ជាផ្នែកមួយបានជួយដល់អ្នកដែលខ្វះខាតឱ្យពួកគេមានលទ្ធភាពអាចរស់នៅក្នុងសង្គមបាន។ អត្ថប្រយោជន៍ទាំងនោះមានទាំងចំពោះបុគ្គលឯកជន និងសង្គមទាំងមូលផងដែរ។

**១.១.២.១ អត្ថប្រយោជន៍ចំពោះបុគ្គល**

ប្រសិនបើយើងពិនិត្យមើលប្រជាជនកម្ពុជាសព្វថ្ងៃ អ្នកខ្លះបានរំលស់ម៉ូតូកង់បី គោយន្ត ត្រាក់ទ័រ និងគ្រឿងចក្រផ្សេងៗ ដើម្បីយកមកប្រកបរបរចិញ្ចឹមជីវិត ឬ អភិវឌ្ឍន៍មុខរបរដែលពួកគេមានស្រាប់។ ដូចឃ្លាមួយថា *"បង់រំលស់ម៉ូតូមកធ្វើការរកចំណូលបន្ថែមដើម្បីជីវភាពគ្រួសារ"*។

ចំណែកឯភាគីខាងអ្នកលក់ ឬម្ចាស់ហិរញ្ញប្បទានវិញ ក៏អាចទទួលបានផលចំណេញពីការលក់ ឬជាការប្រាក់ និងអត្ថប្រយោជន៍ផ្សេងៗ ហើយក៏អាចជួយបង្កើតទំហំនៃការលក់ និងការផ្តល់ហិរញ្ញប្បទានកាន់តែធំជាមុនផងដែរ។ ព្រោះការលក់កើនឡើង ប្រាក់ចំណូលខ្ពស់គឺជាអ្វីដែលពាណិជ្ជករ និងអាជីវករគ្រប់គ្នារំពឹងចង់បាន។

តើធ្វើយ៉ាងណាដើម្បីឱ្យពួកគេអាចលក់របស់បានច្រើន? បើប្រជាជនមួយចំនួនមិនសូវជាមានប្រាក់គ្រប់គ្រាន់ដើម្បីទៅទិញទំនិញរបស់ពួកគេ ឬមានហេតុផ្សេងៗដែលមិនអាចឱ្យអតិថិជនចំណាយប្រាក់របស់ខ្លួនទៅទិញរបស់ទាំងនោះបាន។ ទាំងនេះសុទ្ធតែជាកត្តាដែលនាំនូវផលវិបាកសម្រាប់អាជីវករ និងអ្នកទិញដែលពួកគេមិនអាចបង្កើនការលក់ ឯអ្នកទិញក៏មិនអាចទទួលបានទំនិញយកទៅប្រើប្រាស់ ដើម្បីទាញយកផលប្រយោជន៍ផ្សេងៗតាមតម្រូវការរបស់ខ្លួនបានដោយសារតែមិនមានប្រាក់គ្រប់ចំនួន ឬខ្វះខាតដើម្បីបង្វិលក្នុងជំនួញប្រសិនបើគេចំណាយប្រាក់ទៅទិញគ្រឿងម៉ាស៊ីនជាដើម។

ហេតុនេះហើយ ការលក់ទិញចលនវត្ថុដោយបង់រំលស់ គឺជាដំណោះស្រាយចំពោះបញ្ហាខាងលើ ដោយគេបង្កើតឱ្យមានការបង់រំលស់ ដែលជាសកម្មភាពជំនួញបែបទំនើបមួយ និងបានជួយដល់ភាគីទាំងសងខាងឱ្យទទួលបានផលប្រយោជន៍ដូចអ្វីដែលខ្លួនចង់បាន។ ក្នុងទំនាក់ទំនងបែបនេះ អាចឱ្យអ្នកទិញបង់ប្រាក់ត្រឹមតែមួយផ្នែកនៃតម្លៃកម្មវត្ថុដែលខ្លួនត្រូវការ ឬមិនចាំបាច់បង់សោះក៏អាចទទួលបានវត្ថុនោះមកប្រើប្រាស់ ដើម្បីបម្រើដល់ជីវភាពនៃការរស់នៅ ឬជួយដល់សកម្មភាពជំនួញរបស់ខ្លួនឱ្យរីកចម្រើនបន្តទៅមុខទៀត។ ជាក់ស្តែង ពលរដ្ឋមួយចំនួនគាត់បានធ្វើការបង់រំលស់ម៉ូតូរម៉ក់ ដើម្បីយកមកប្រកបរបរចិញ្ចឹមជីវិតរបស់ខ្លួន និងក្រុមគ្រួសារ ទោះបីមិនមានលទ្ធភាពទាំងស្រុងក្នុងការទិញម៉ូតូនោះភ្លាមៗក៏ដោយ។ មួយវិញទៀត សម្រាប់ផ្នែក សិប្បករ រោងចក្រ សហគ្រាស កសិករ ក៏ពួកគាត់អាចបញ្ជាទិញនូវ ឧបករណ៍ ឬគ្រឿងចក្រ ដើម្បីយកមកបម្រើដល់កិច្ចការកសិកម្ម ឬឧស្សាហកម្មរបស់ពួកគាត់ឱ្យកាន់តែមានភាពរីកចម្រើនជាងមុនដោយមិនចាំបាច់បង់ថ្លៃទំនិញទាំងស្រុងឡើយ ប្រសិនបើពួកគាត់កំពុងខ្វះខាតដើមទុនសម្រាប់ទ្រទ្រង់សកម្មភាពផ្សេងៗ។

ឆ្លងកាត់តាមរយៈឧទាហរណ៍ខាងលើ យល់ឃើញថា ការបង់រំលស់ពិតជាបានជួយដល់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ ដើម្បីឱ្យពួកគាត់អាចមានជីវភាពរស់នៅមួយដ៏សមរម្យ និងកាត់បន្ថយភាពក្រីក្រ ព្រមទាំងការធ្វើចំណាកស្រុកជាដើម។ កាលណាសកម្មភាពពាណិជ្ជកម្មរបស់ពលរដ្ឋមានភាពរីកចម្រើន ច្បាស់ណាស់គឺមិនអាចភ្លេចឡើយនូវកាតព្វកិច្ចរបស់ខ្លួនក្នុងការបង់ពន្ធជូនរដ្ឋ ដើម្បីអោយរាជរដ្ឋាភិបាលចាត់ចែងពន្ធដែលប្រមូលបាន ទៅអភិវឌ្ឍផ្នែកផ្សេងៗទៀត ជាពិសេស គឺការជួយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យមានភាពល្អប្រសើរឡើងថែមទៀត។

ហេតុនេះ ក្រៅពីអត្ថប្រយោជន៍ផ្ទាល់ខ្លួនរបស់បុគ្គល រដ្ឋក៏ជាអ្នកដែលទទួលផលប្រយោជន៍ពីការរីកចម្រើននេះផងដែរ។ ដូចបានរៀបរាប់ខាងលើ ការរបង់រំលស់ ពិតជាបានផ្តល់នូវអត្ថប្រយោជន៍ជាច្រើន ចំពោះប្រជាពលរដ្ឋ និងសង្គមទាំងផ្នែកសេដ្ឋកិច្ច សុខមាលភាព ការរស់នៅ ការអភិវឌ្ឍ និងផ្នែកផ្សេងៗជាច្រើន ពិសេសជាងនេះគឺ វិស័យសេដ្ឋកិច្ចតែម្តង។ ចំណុចខាងក្រោម នឹងបង្ហាញអំពីអត្ថប្រយោជន៍ខ្លះចំពោះសង្គម។

### ១.១.២.២ អត្ថប្រយោជន៍ចំពោះសង្គម

បុគ្គលគ្រប់រូបជាកោសិកានៃសង្គម ប្រសិនបើពលរដ្ឋមានជីវភាពធូរធារ នោះសង្គមក៏មានសេដ្ឋកិច្ចល្អប្រសើរ។ សកម្មភាពជំនួញរបស់ពលរដ្ឋប្រៀបបាននឹងសរសៃឈាមរបស់សង្គមដែលអាចដឹកនាំសង្គមទៅរកភាពរីកចម្រើន និងមានការអភិវឌ្ឍន៍គ្រប់វិស័យបានតាមរយៈចំណូលពន្ធផ្សេងៗអំពីសកម្មភាពពាណិជ្ជកម្មដែលរដ្ឋទទួលបាន ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ក្នុងការអភិវឌ្ឍន៍លើវិស័យនានា។

អ្វីដែលកាន់តែពិសេសនោះគឺ ធ្វើឱ្យការរស់នៅរបស់ប្រជាជនមានភាពល្អប្រសើរ ដើរទាន់សម័យកាលដោយបង្កើនឱ្យមានលទ្ធភាពទទួលបាននូវរបស់ប្រើប្រាស់ល្អៗ ទំនើបទាន់សម័យតាមតម្រូវការដែលជាផ្នែកមួយនាំឱ្យទទួលបានចំណេះដឹង បច្ចេកវិទ្យាថ្មីៗ ការរស់នៅប្រកបដោយគំនិតច្នៃប្រឌិតខ្ពស់ និងសុខុមាលភាព ព្រមទាំងសង្វាក់ផលិតកម្មកាន់តែមានភាពល្អប្រសើរឡើង និងស្រូបយកនូវផលប្រយោជន៍ដែលទាញបានពីវត្ថុចម្បងទាំងនោះ។ ប៉ុន្តែប្រសិនបើ មិនអាចប្រើប្រាស់វត្ថុទាំងអស់នោះបានទេ វាក៏អាចជាកត្តាមួយដែលធ្វើឱ្យពួកគេក្លាយជាអនក្ខរជននៃបច្ចេកវិទ្យា ពេលនោះហើយដែលរដ្ឋនឹងជួបប្រទះនូវការលំបាក ដោយសារប្រជាជនខ្វះការយល់ដឹងពីបច្ចេកវិទ្យាថ្មីៗដែលអាចប្រើប្រាស់ជាប្រយោជន៍ក្នុងការអភិវឌ្ឍប្រទេស ដូចនេះ រដ្ឋត្រូវចំណាយពេលវេលានឹងធនធានដើម្បីជួយអភិវឌ្ឍន៍ ចំណេះដឹង និងសមត្ថភាព ព្រមទាំងការវិវត្តផ្នែកបច្ចេកវិទ្យាដល់ពួកគេទៀតផង។

ជាក់ស្តែង បើបានប្រើប្រាស់វត្ថុទំនើបទាំងនោះហើយ ពួកគេក៏អាចយល់ដឹងបានច្រើនពីការវិវត្តរបស់សង្គម និងធ្វើឱ្យកម្រិតនៃការយល់ដឹងពួកគេមានការកើនឡើង ហើយរដ្ឋងាយស្រួលក្នុងការអភិវឌ្ឍន៍សង្គមទៅមុខបានយ៉ាងឆាប់រហ័ស។ ជាឧទាហរណ៍ ក្នុងករណីដែលពលរដ្ឋមិនមានលទ្ធភាពក្នុងការប្រើប្រាស់ ស្មាតហ្វូន (smart phone) គ្រឿងចក្រទំនើបៗ សម្រាប់វិស័យកសិកម្ម ឬឧស្សាហកម្ម នោះនឹងធ្វើឱ្យពួកគេខ្វះខាតនូវចំណេះដើម្បីបង្កើនផលិតផល ដែលជាហេតុធ្វើឱ្យទំហំនៃការនាំចូលទំនិញកើនឡើង ថ្លៃទំនិញប្រើប្រាស់ក៏កើនឡើង ការរីកលូតលាស់នៃប្រទេសជាតិក៏មានភាពយឺតយ៉ាវទៅតាមនឹងដែរ។

ឃើញថា ប្រតិបត្តិការនៃការបង់រំលស់ ពិតជាមានផលប្រយោជន៍ខ្លាំងណាស់ដែលធ្វើឱ្យរដ្ឋមានភាពងាយស្រួលចូលរួមក្នុងការអភិវឌ្ឍន៍ប្រទេស ឱ្យមានភាពរីកចម្រើនឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធិភាព។

### ១.១.២.៣ ការជម្រុញវិស័យសេដ្ឋកិច្ច

បើយើងសង្កេតមើលឱ្យបានច្បាស់ ការអនុញ្ញាតឱ្យមានកិច្ចសហប្រតិបត្តិការណ៍ជំនួញដោយបង់រំលស់ គឺវាពិតជាបានជួយយ៉ាងខ្លាំងក្លា ដល់ផ្នែកសេដ្ឋកិច្ចរបស់ពលរដ្ឋ និងសេដ្ឋកិច្ចជាតិមែន ព្រោះវាបានជួយដល់អ្នកដែលគ្មានលទ្ធភាពគ្រប់គ្រាន់ក្នុងការទិញទំនិញយកមកប្រើប្រាស់ដើម្បីជាប្រយោជន៍ក្នុងវិស័យណាមួយ ទទួលបានទំនិញមកប្រើប្រាស់ និងជួយដល់អាជីវករបង្កើនទំហំនៃការលក់របស់ពួកគេបានកាន់តែច្រើន គួបផ្សំទាំង

វិស័យហិរញ្ញវត្ថុក៏មានភាពរីកចម្រើន។ ជាងនេះទៅទៀត ទំហំនៃការនាំចេញ នាំចូលមានការកើនឡើង ចំណូលពន្ធចូលរដ្ឋក៏មានកំណើនទៅតាមសកម្មភាពទាំងនេះផងដែរ។

### ១.២ ការជ្រើសរើសគូភាគី និងការជ្រើសរើសប្រតិបត្តិការ

បើទោះបីជា សកម្មភាពនៃបង់រំលស់មានការកើនឡើងច្រើនសម្រាប់កម្ពុជានាពេលបច្ចុប្បន្នក៏ដោយ ប៉ុន្តែប្រព័ន្ធនៃការគ្រប់គ្រង និងការអនុវត្តផ្នែកច្បាប់ចំពោះការបង់រំលស់ចលនវត្ថុមិនទាន់មានភាពល្អប្រសើរខ្លាំងនោះទេ ពោលគឺនៅតែមានបញ្ហាមួយចំនួនបានកើតឡើងហើយមិនទាន់ត្រូវបានដោះស្រាយ ហើយសកម្មភាពបង់រំលស់ទាំងអស់ អាចត្រូវបានគ្រប់គ្រងដោយច្បាប់ផ្សេងៗ ដែលសារធាតុនៃសិទ្ធិ និងកាតព្វកិច្ចមានការប្រែប្រួលតាមស្មារតីនៃបទដ្ឋានគតិយុត្តនីមួយៗ រួមទាំងការប្រែប្រួលនៃឋានៈរបស់ភាគីក្នុងកិច្ចសន្យាផងដែរ។ ដូចនេះទាមទារ ឱ្យភាគីនៃកិច្ចសន្យាត្រូវធ្វើយ៉ាងណា សិក្សាឱ្យបានច្បាស់លាស់អំពី របបគតិយុត្តិនីមួយៗ ព្រមទាំងដៃគូរសហការរបស់ខ្លួន ដើម្បីទទួលការផលប្រយោជន៍ច្រើន និងសុវត្ថិភាពខ្ពស់ក្នុងកិច្ចការជំនួញ។ ខាងក្រោមនេះ ជាការជ្រើសរើសភាគី និងការជ្រើសរើសប្រតិបត្តិការសម្រាប់អនុវត្តលើសកម្មភាពលក់ទិញចលនវត្ថុដោយបង់រំលស់ដែលនឹងកើតមានឡើង។

#### ១.២.១ ការជ្រើសរើសភាគី

ក្នុងស្ថានភាពនៃការជ្រើសគូរភាគីនៃកិច្ចសន្យា យើងនឹងឈរលើជ្រុងម្ខាងជាអ្នកទិញ ដើម្បីជ្រើស ម្ចាស់បំណុលរបស់ខ្លួន ថាតើគេចង់ក្លាយជាកូនបំណុលនៃស្ថាប័នធនាគារ ឬ ជាមួយម្ចាស់ហាងផ្ទាល់។ ហើយក្នុងស្ថានភាពបែបនេះ យើងក៏អាចឆ្លុះបង្ហាញទៅកាន់ភាគីម្ខាងទៀតថា ខ្លួនចង់ក្លាយជាម្ចាស់បំណុលផ្ទាល់ ឬ បង្កើតឱ្យមានស្ថាប័នធនាគារចូលរួម។ ដូច្នេះ គូភាគីសុទ្ធតែអាចពិចារណា ថាខ្លួនចង់បានឋានៈណាមួយក្នុងកិច្ចសន្យាដែលនឹងកើតឡើងនោះ។ យោងតាមស្ថានភាពជាក់ស្តែង ក្នុងនាមយើងជាអ្នកទិញដោយបង់រំលស់ ជាទូទៅយើងអាចនឹងមានជម្រើសពីរគឺ ជ្រើសយកការបង់រំលស់ជាមួយម្ចាស់ហាងផ្ទាល់ ឬ ការបង់រំលស់ជាមួយស្ថាប័នធនាគារ។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី សមត្ថភាពតាមផ្លូវច្បាប់រវាងម្ចាស់ហាង និងស្ថាប័នធនាគារមិនដូចគ្នាទេ។ ក្នុងស្ថានភាពមួយចំនួន ម្ចាស់ហាងមិនអាចផ្តល់ហិរញ្ញប្បទានដល់អ្នកទិញបានឡើយ មានតែខាងធនាគារប៉ុណ្ណោះដែលអាចធ្វើសកម្មភាពនោះបាន។ ហើយការកំណត់ឋានៈរបស់ភាគី ក៏ប្រៀបដូចជាការកំណត់ទម្រង់បទដ្ឋានគតិយុត្តផងដែរ ព្រោះសមត្ថភាពភាគីរបស់បុគ្គលមួយចំនួន មិនអាចត្រូវបានទទួលស្គាល់ក្រោមវិធានពិសេសណាមួយឡើយ ហើយគេនឹងមិនអាចជ្រើសរើសទម្រង់នៃច្បាប់នោះមកប្រើដើម្បីការពារផលប្រយោជន៍របស់ខ្លួនបានទេ។ ដូច្នេះហើយ ការជ្រើសរើសភាគី ក៏ជាលក្ខខណ្ឌមួយក្នុងការកំណត់ប្រភេទច្បាប់ដែលអនុវត្តលើសកម្មភាពទាំងនោះផងដែរ។

### ១.២.១.១ ការរំលស់ជាមួយម្ចាស់ហាងផ្ទាល់

អាជីវករ ឬពាណិជ្ជករ តាមធម្មតាជារូបវន្តបុគ្គល ឬនីតិបុគ្គល ដែលពួកគេមួយចំនួនបានប្រកបអាជីវកម្ម ដោយមានការសហការគ្នាជាមួយនឹងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ ក្នុងការផ្តល់ហិរញ្ញប្បទានដល់អតិថិជនរបស់គេ ដើម្បីជួយដល់អតិថិជនឱ្យមានប្រាក់គ្រប់គ្រាន់ទិញចលនវត្ថុតាមរយៈកម្ចី។ ការធ្វើបែបនេះ អាចជួយឱ្យការលក់របស់គេមានភាពល្អប្រសើរឡើង អតិថិជនអាចទទួលបានរបស់ រីឯខាងហិរញ្ញវត្ថុក៏ទទួលបានប្រាក់ចំណេញខ្លះដែរ មិនតែប៉ុណ្ណោះ មានអាជីវករមួយចំនួន បានផ្តល់ហិរញ្ញប្បទានជាការបង់រំលស់ដល់អតិថិជនដោយខ្លួនឯងផ្ទាល់តែម្តងមិនចាំបាច់មានការចូលរួមពីស្ថាប័នធនាគារទេ។ ដូចអ្វីដែលបានដឹងពីខាងលើហើយថា សមត្ថភាពរបស់បុគ្គលទាំងពីរប្រភេទនេះ គឺមិនដូចគ្នានោះទេ។

ប្រសិនបើយើងជ្រើសកម្ចីជាមួយម្ចាស់ហាង ដែលគ្មានសមត្ថភាពជាប្រតិបត្តិករភតិសន្យាហិរញ្ញវត្ថុ សិទ្ធិ និងកាតព្វកិច្ចមួយចំនួនក៏អាចត្រូវបានកម្រិត ហើយប្រាកដណាស់អ្នកនឹងត្រូវបាត់បង់នូវជម្រើសមួយទៅហើយ ពោលគឺគេមិនអាចជ្រើសការអនុវត្តភតិសន្យាហិរញ្ញវត្ថុនោះទេ ហេតុនេះហើយ អ្នកគ្រាន់តែអាចអនុវត្តកិច្ចព្រមព្រៀងឱ្យស្ថិតក្រោមវិធានផ្សេងពីវិធានច្បាប់នេះប៉ុណ្ណោះ។

គ្មានទេពាក្យថា ធ្វើមិនបាននៅក្នុងវចនានុក្រមរបស់អ្នកជំនួញ។ បើទោះបីជា ច្បាប់បានហាមឃាត់រូបវន្តបុគ្គល ឬនីតិបុគ្គលធម្មតា មិនឱ្យអនុវត្តភតិសន្យាហិរញ្ញវត្ថុក៏ដោយ ក្រុមហ៊ុនដែលមានអាជីវកម្មធំៗមួយចំនួនបានបង្កើតគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុផ្ទាល់ខ្លួនតែម្តងដើម្បីធ្វើយ៉ាងឱ្យខ្លួនគេក្លាយជាបុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្លាយជាប្រធាននៃសិទ្ធិ ដូចដែលច្បាប់បានកំណត់។ ជាក់ស្តែង ដូចជាក្រុមហ៊ុន គូបូតា ខេបូឌា KUBOTA (CAMBODIA) Co.,Ltd. បានបង្កើត KUBOTA Leasing Cambodia ហៅកាត់(KLC) ចំណែកឯក្រុមហ៊ុន TOYOTA CAMBODIA មានក្រុមហ៊ុន Toyota Cambodia Finance ដើម្បីផ្តល់សេវាកម្មបង់រំលស់ដល់អតិថិជនរបស់ខ្លួនដោយផ្ទាល់។ ដោយសារតែ បុគ្គលធម្មតាមិនមានសមត្ថភាពគ្រប់គ្រប់ក្នុងការផ្តល់ហិរញ្ញប្បទានដល់អតិថិជនតាមវិធានភតិសន្យាហិរញ្ញវត្ថុនោះទេ។ ហេតុនេះ ធ្វើឱ្យក្រុមហ៊ុនធំៗខាងលើព្យាយាមធ្វើយ៉ាងណាអាចឱ្យខ្លួនក្លាយជាបុគ្គលដែលមានសមត្ថភាពក្នុងការផ្តល់ហិរញ្ញប្បទាន ដោយមិនមានការចូលរួមពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុខាងក្រៅ។ ឃើញថា សកម្មភាពបែបនេះ ជាការផ្តល់នូវហិរញ្ញប្បទានដោយម្ចាស់ហាងផ្ទាល់ក្តី ប៉ុន្តែក្នុងករណីនេះ មិនដូចទៅនឹងការផ្តល់ហិរញ្ញប្បទានដោយផ្ទាល់ពីពាណិជ្ជករទូទៅដែលគ្មានសមត្ថភាពជាប្រតិបត្តិករនោះទេ តែជាការបង់រំលស់ជាមួយម្ចាស់ហាងដែលមានសមត្ថភាពជាប្រតិបត្តិករក្នុងការផ្តល់ភតិសន្យាហិរញ្ញវត្ថុ ហើយក៏ជាអ្វីខុសគ្នាដែលយើងចង់បង្ហាញឱ្យឃើញផងដែរ។ តាមឧទាហរណ៍ខាងលើ បើយើងទិញត្រាក់ទ័រពីក្រុមហ៊ុនKUBOTA យើងក៏អាចរំលស់ត្រាទ័រនោះជាមួយក្រុមហ៊ុនKUBOTA ដោយផ្ទាល់បាន ព្រោះគេមានក្រុមហ៊ុន KUBOTA Leasing ដែលជាគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុផ្ទាល់ខ្លួន

ចំណែកឯ ក្រុមហ៊ុនលក់រថយន្តTOYOTA ក៏ដូចគ្នា។ ករណីទី២ បើយើងទិញម៉ូតូពីហាងណាមួយជាអាជីវករធម្មតា នោះរំលស់ជាមួយម្ចាស់ហាងផ្ទាល់ដោយប្រើវិធានភតិសន្យាហិរញ្ញវត្ថុមិនបានឡើយ លុះត្រាតែ មានការចូលរួមពីគ្រឹះស្ថានធនាគានិងហិរញ្ញវត្ថុណាមួយទើបបាន។

### ១.២.១.២ ការរំលស់ជាមួយ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

ស្ថាប័នធនាគារ ឬ គ្រឹះស្ថានហិរញ្ញវត្ថុវិញ ជាបុគ្គលដែលមានលក្ខណៈសម្បត្តិទូលំទូលាយជាងបុគ្គលធម្មតា មានសមត្ថភាពជាប្រតិបត្តិករក្នុងការផ្តល់ហិរញ្ញប្បទានផ្សេងៗ ដោយសារតែ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ មានការទទួលស្គាល់ និងគ្រប់គ្រងដោយធនាគារជាតិនៃកម្ពុជា ដែលជាអាជ្ញាធររូបិយវត្ថុ និងត្រួតពិនិត្យប្រព័ន្ធធនាគារនៅកម្ពុជា ជាអ្នកផ្តល់និងដកហូតអាជ្ញាប័ណ្ណ ចេញបទប្បញ្ញត្តិ ត្រួតពិនិត្យ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជា។ លើសពីនេះទៅទៀត បេសកម្មរបស់ធនាគារជាតិនៃកម្ពុជាគឺកំណត់ និងដឹកនាំគោលនយោបាយរូបិយវត្ថុ ក្នុងគោលដៅរក្សាស្ថិរភាពតម្លៃ សំដៅរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដោយពិគ្រោះជាមួយរដ្ឋាភិបាលក្នុងក្របខណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា ស្របជាមួយគ្នានឹងច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ មានគោលបំណងជួយអភិវឌ្ឍប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ និងសហគ្រាសដើម្បីឱ្យប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ស្មើភាព សុវត្ថិភាព និងប្រសិទ្ធិភាព ព្រមទាំងផលិតភាពដើម្បីស្របតាមការអភិវឌ្ឍនៃសេដ្ឋកិច្ចកម្ពុជា។[1]

ការផ្តល់ហិរញ្ញប្បទានទៅលើអាជីវកម្មបែបទំនើប ត្រូវតែធ្វើឡើងដោយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដូចដែលបានកំណត់ក្នុង ច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ ជាការគួរព្រោះវានឹងជួយឱ្យមានភាពងាយស្រួល សុវត្ថិភាព និងមានអាណាព្យាបាលត្រួតពិនិត្យត្រឹមត្រូវក្នុងការអនុវត្តសកម្មភាពទាំងនេះ ដើម្បីធ្វើយ៉ាងណាកុំឱ្យប្រព័ន្ធពាណិជ្ជកម្មបែបទំនើបនេះជួបប្រទះនូវអស្ថេរភាព ការកេងចំណេញហួសហេតុពីភាគី ទាំងទៅលើការអនុវត្តសិទ្ធិ និងអត្រាការប្រាក់ ព្រមទាំងធានាឱ្យបាននូវប្រសិទ្ធិភាពនៃប្រព័ន្ធហិរញ្ញប្បទានឱ្យមានភាពរីកចម្រើនផងដែរ។

គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ មិនត្រូវបានកម្រិតសមត្ថភាពក្នុងការផ្តល់ហិរញ្ញប្បទាននោះទេ ប្រសិនបើអ្នកជ្រើសរើសយកម្ចាស់ហិរញ្ញប្បទានជាគ្រឹះស្ថានធនាគារ អ្នកក៏មានសិទ្ធិជ្រើសរើសទម្រង់នៃប្រតិបត្តិការណាមួយក្នុងចំណោម ភតិសន្យាហិរញ្ញវត្ថុ ឬ តាមប្រតិបត្តិការដែលមានកិច្ចធានាក៏បានតាមដែលអ្នកគិតថា នឹងផ្តល់ផលប្រយោជន៍បានច្រើនជាង។

### ១.២.២ ការជ្រើសរើសប្រតិបត្តិការ

ត្បិតអី រូបភាពនៃការបង់រំលស់ សុទ្ធតែដូចគ្នាក៏ពិតមែន ប៉ុន្តែមិនមែនការបង់រំលស់ ទាំងអស់សុទ្ធតែដូចគ្នានោះទេ ពោលគឺ វាអាចត្រូវបានគ្រប់គ្រងដោយរបបគតិយុត្តផ្សេងៗគ្នា ដែលជាហេតុនាំឱ្យសិទ្ធិ និងកាតព្វកិច្ច

[1] គេហទំព័រធនាគារជាតិជាតិនៃកម្ពុជា https://www.nbc.org.kh/about_the_bank/overview_of_functions_and_operation.php

របស់ភាគីក្នុងទំនាក់ទំនងនីមួយៗមិនដូចគ្នាឡើយ។ បន្ទាប់ពីបាន ជ្រើសរើសភាគីនៃកិច្ចសន្យារួចហើយ គឺជាដំណាក់កាលដែលយើងត្រូវពិនិត្យមើល របបគតិយុត្តដែលគ្រប់គ្រងសិទ្ធិលើបំណុលរបស់យើងវិញម្តង អ្វីដែលសំខាន់នោះ ភាគីខ្លួនឯងត្រូវចេះជ្រើសរើសរបបគតិយុត្តិមួយណាដែលផ្តល់ផលប្រយោជន៍ឱ្យខ្លួនបានច្រើនជាងក្នុងនាមជាម្ចាស់បំណុល ឬកូនបំណុល។ នៅក្នុងចំណុចនេះ នឹងគ្រាន់តែបង្ហាញអ្នកជាបឋមអំពីវិធានពិសេសៗដែលអាចយកមកអនុវត្តលើការលក់ទិញដោយបង់រំលស់ប៉ុណ្ណោះ ឯចំណុចលំអិតនៃវិធាននីមួយៗ នឹងត្រូវបានបកស្រាយក្នុងជំពូកបន្តបន្ទាប់ផងដែរ។

ក្នុងស្ថានភាពអ្នកជាភាគីនៃកិច្ចសន្យា បើជាម្ចាស់បំណុល យើងគួរណាតែបង្កើតទំនាក់ទំនងគតិយុត្តដែលបានផ្តល់ឱ្យយើងនូវសិទ្ធិ និងផលប្រយោជន៍ច្រើន ឬអាចមានសិទ្ធិសង្គ្រោះកិច្ចសន្យាដែលរងការបំពានបានដោយខ្លួនឯងជាការប្រសើរ ព្រោះពាណិជ្ជករមិនចូលចិត្តភាពស្មុគស្មាញក្នុងការសង្គ្រោះកិច្ចការជំនួញទេ។ ចំណែកឯ ភាគីខាងកូនបំណុលវិញក៏ត្រូវតែពិចារណាអំពីបញ្ហានេះដូចគ្នា ពោលគឺយើងត្រូវជ្រើសរើសកាតព្វកិច្ចបែបណា ដែលមិនប៉ះពាល់ដល់ផលប្រយោជន៍របស់យើងខ្លាំង ទើបជាការល្អ។ ខាងក្រោមនេះ គឺជាវិធានមួយចំនួនដែលអាចត្រូវបានអនុវត្តលើសកម្មភាពលក់ទិញដោយបង់រំលស់។

**១.២.២.១ ភតិសន្យាហិរញ្ញវត្ថុ**

ភតិសន្យាហិរញ្ញវត្ថុ ជាច្បាប់ពិសេសមួយក្នុងវិស័យឯកជនក្រៅអំពីក្រមរដ្ឋប្បវេណី ដែលមានគោលបំណង អភិវឌ្ឍន៍ប្រព័ន្ធធនាគារ និងហិរញ្ញវត្ថុ និងសហគ្រាស ដើម្បីបង្កលក្ខណៈធ្វើប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ដោយស្មើភាព សុវត្ថិភាព ប្រសិទ្ធិភាព និងផលិតភាព ស្របតាមការវិវត្តនៃសេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា។[2] វិធាននៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ គឺបង្កើតឱ្យមានការចូលរួមពីស្ថាប័នធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមច្បាប់នេះ ដើម្បីចូលរួមផ្តល់ហិរញ្ញប្បទានក្នុងនាមជាភតិបតី និងសម្រេចគោលបំណងរបស់ភតិកៈដើម្បីទទួលបានកម្មវត្ថុដែលគេចង់បានយកទៅប្រើប្រាស់តាមតម្រូវការ។ មិនត្រឹមតែប៉ុណ្ណោះ សិទ្ធិរបស់ភតិបតីក៏មានលក្ខណៈពិសេសផងដែរ គឺគេអាចសង្គ្រោះកិច្ចសន្យាដោយខ្លួនឯងបានលើកលែងតែ ការសង្គ្រោះនោះធ្វើឡើងដោយហិង្សាទើបគេត្រូវប្តឹងទៅតុលាការ។[3]

**១.២.២.២ ប្រតិបត្តិការដែលមានកិច្ចធានា**

ប្រតិបត្តិការដែលមានកិច្ចធានាវិញ សំដៅដល់ប្រព័ន្ធប្រាតិភោគមួយដែលមានគោលបំណង លើកស្ទួយវិស័យសេដ្ឋកិច្ច តាមរយៈវិធានរួមស្តីពីការប្រើប្រាស់ទ្រព្យធានា ដូចដែលមានចែងក្នុងមាត្រា៦ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ដើម្បីធានាកាតព្វកិច្ច និងត្រូវយកច្បាប់នេះ មកដោះស្រាយក្នុងករណីដែលមាន

[2] មាត្រា២ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

[3] មាត្រា១៧ ចំណុច គ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

ភាពផ្ទុយគ្នានឹងបទប្បញ្ញត្តិដទៃទៀត លើកលែងតែច្បាប់ផ្សេងចែងដោយយោងជាក់លាក់ ឬធ្វើវិសោធន៍កម្មលើបទប្បញ្ញត្តិ ដែលផ្ទុយនឹងច្បាប់។ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ក៏ជាច្បាប់ពិសេសមួយក្នុងចំណោមច្បាប់ពិសេសផ្សេងទៀតក្រៅអំពីក្រមរដ្ឋប្បវេណីផងដែរ។ បទប្បញ្ញត្តិដែលពុំមានចែងក្នុងច្បាប់នេះ ត្រូវអនុវត្តតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។[4] វិធាននៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា គឺមានលក្ខណៈទូលាយជាង ច្បាប់ភតិសន្យាហិរញ្ញវត្ថុបន្តិច ព្រោះវិធាននេះ អនុវត្តដោយបុគ្គលធម្មតាបាន ទោះបីជាក្នុងនាមជាម្ចាស់បំណុល ឬ កូនបំណុលក៏ដោយ។ ហើយអ្វីដែលកាន់តែពិសេសដូចគ្នានោះគឺ ម្ចាស់បំណុលផ្អែកតាមវិធាននៃច្បាប់នេះ ក៏មានសិទ្ធិក្នុងការសង្គ្រោះកិច្ចសន្យាដោយខ្លួនឯង ដោយការកាន់កាប់កម្មវត្ថុនៃប្រាតិភោគ ឬការជម្រះបញ្ជីលើវត្ថុជាដើម។[5]

### ១.២.២.៣ កិច្ចសន្យាខ្ចីបរិភោគដោយមានការប្រាក់

ជម្រើសមួយផ្សេងទៀតដែលទាក់ទងនឹងការបង់រំលស់គឺ ការខ្ចីបរិភោគ ប្រសិនបើអ្នកបានធ្វើកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ វាគឺជារបបគតិយុត្តមួយដែលត្រូវបានបញ្ញត្តិ និងគ្រប់គ្រងដោយក្រមរដ្ឋប្បវេណីឆ្នាំ២០០៧[6] ហើយភាគីនៃកិច្ចសន្យាក៏អាចជាបុគ្គលធម្មតា ឬ ម្ចាស់បំណុលជាស្ថាប័នហិរញ្ញវត្ថុ ព្រោះច្បាប់នេះមិនកំណត់តម្រូវទាល់តែម្ចាស់បំណុលជាគ្រឹះស្ថានហិរញ្ញវត្ថុនោះទេ។ ទោះបីកិច្ចសន្យាខ្ចីបរិភោគ មានលក្ខណៈងាយស្រួលក៏ពិតមែន ប៉ុន្តែការអនុវត្តសិទ្ធិទាមទារក្នុងវិធាននេះ មិនមានភាពងាយស្រួលដល់ម្ចាស់បំណុល ដូចជាវិធានពិសេសដែលនឹងត្រូវបានលើកយកមកសិក្សានោះទេ។ មិនតែប៉ុណ្ណោះ ម្ចាស់បំណុលត្រូវចំណាយទាំងពេលវេលា និងថវិកាច្រើនក្នុងការចូលរួមនីតិវិធីបណ្តឹងទៀតផង។

ក្រោយពីបានបង្ហាញ និងស្វែងយល់នូវមូលដ្ឋានខ្លះៗទាក់ទងនឹងការបង់រំលស់ចលនវត្ថុ ទាំងផ្នែកសារធាតុនៃសិទ្ធិ និងទម្រង់នៃនីតិវិធីហើយ ជំពូកបន្ទាប់យើងនឹងសិក្សាលម្អិតអំពី របបគតិយុត្តនីមួយៗ ដែលនឹងត្រូវយកមកអនុវត្តព្រមទាំងសិទ្ធិ និងកាតព្វកិច្ចដែលមានចែងក្នុងវិធាននីមួយៗ ថាមានលក្ខណៈខុសគ្នាបែបណា ហើយវាបានផ្តល់ផលប្រយោជន៍ភាគីណាច្រើនជាងតាមវិធាននីមួយៗ ដែលជាមូលដ្ឋានអាចឱ្យអ្នកងាយស្រួលក្នុងការពិចារណា ប្រសិនបើអ្នកនឹងក្លាយជាភាគីនៃកិច្ចសន្យា។

[4] មាត្រា១ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

[5] មាត្រា៤៦ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

[6] មាត្រា៥៧៨ និង៥៨៣ នៃក្រមរដ្ឋប្បវេណី ប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧

# ជំពូកទី២

# ការលក់ទិញដោយបង់រំលស់តាមរយៈភតិសន្យាហិរញ្ញវត្ថុ

## ២.១ ការបង្កើតកិច្ចសន្យា

ភតិសន្យាហិរញ្ញវត្ថុ គឺជាការជួលឧបករណ៍ ឬសម្ភារៈសម្រាប់យកទៅប្រើប្រាស់ក្នុងអាជីវកម្មដែលម្ចាស់អាជីវកម្មគ្មានលទ្ធភាពទិញឧបករណ៍ ឬសម្ភារៈ។ ការជួលនេះស្រដៀងនឹងទិញដែរ ប៉ុន្តែខុសគ្នាត្រង់ថាអ្នកជួលត្រូវបង់ថ្លៃជួលជាវគ្គៗ ហើយថ្លៃជួលត្រូវគិតយកប្រាក់ដើមទំនិញបូកនឹងចុងការប្រាក់តាមវគ្គនីមួយៗហើយនៅពេលចប់ការជួលអ្នកទិញអាចបន្ថែមប្រាក់បន្តិចបន្តួចទិញផ្តាច់តែម្តង ឬជួនកាលនៅពេលចប់ការជួល ម្ចាស់របស់អាចផ្ទេរកម្មសិទ្ធិលើឧបករណ៍ទៅអ្នកជួលតែម្តង។[7] កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុសំដៅដល់ កិច្ចព្រមព្រៀងដែលភតិបតីទិញចលនវត្ថុ ដែលភតិកៈបានជ្រើសរើសពីអ្នកផ្គត់ផ្គង់ ហើយជួលចលនវត្ថុនេះទៅឱ្យភតិកៈ និងអនុញ្ញាត ឱ្យភតិកៈបង់ថ្លៃឈ្នួលតាមការកំណត់។[8] ភតិសន្យាហិរញ្ញវត្ថុ ត្រូវមានរយៈពេលយ៉ាងតិចបំផុត ១ឆ្នាំ ហើយនៅចុងបញ្ចប់នៃកិច្ចព្រមព្រៀង ភតិកៈអាច ឬ មិនអាចទិញផ្តាច់នូវចលនវត្ថុ។ ភតិបតី ផ្តល់ហិរញ្ញប្បទានសម្រាប់ភតិកៈប្រើប្រាស់ចលនវត្ថុ មិនមែនឱ្យធ្វើជាម្ចាស់កម្មសិទ្ធិលើចលនវត្ថុនោះទេ។[9]

ដូចអ្វីដែលបានបង្ហាញខាងលើប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ គឺជាប្រតិបត្តិការមួយនៃការបង់រំលស់ដែលត្រូវបានប្រើប្រាស់ជាច្រើននាពេលបច្ចុប្បន្ន ក្រោមវិធាននៃភតិសន្យាហិរញ្ញវត្ថុ អ្នកទិញអាចរកហាងលក់ទំនិញណាមួយដែលខ្លួនចង់បាន ហើយទំនាក់ទំនងទៅខាងធនាគារ ឬ គ្រឹះស្ថានហិរញ្ញវត្ថុ ដើម្បីឱ្យគេបង់ថ្លៃទំនិញទៅឱ្យម្ចាស់ហាង បន្ទាប់មក យកទំនិញនោះមកប្រគល់ឱ្យយើងកាន់កាប់ និងប្រើប្រាស់ចលនវត្ថុ ដោយបង់ថ្លៃឈ្នួលតាមការកំណត់របស់ភតិបតី។ ក្នុងរូបភាពបែបនេះ វាដូចនឹងការលក់ទិញដោយបង់រំលស់ ប៉ុន្តែបើគិតអំពីសិទ្ធិតាមផ្លូវច្បាប់វិញ គឺគ្រាន់តែជាការបង់ថ្លៃឈ្នួលនៃវត្ថុប៉ុណ្ណោះទេ ដោយអ្នកទទួលវត្ថុគ្រាន់តែជាភតិកៈនៃចលនវត្ថុ គេមិនមែនជាកម្មសិទ្ធិករនៃចលនវត្ថុឡើយ លុះត្រាតែ ចុងបញ្ចប់នៃកិច្ចសន្យាទើបគេមានសិទ្ធិយកវត្ថុដោយទិញផ្តាច់ ឬមិនទិញផ្តាច់ ឬអាចត្រូវបានភតិបតីប្រគល់ឱ្យតែម្តង។ វាមានលក្ខណៈខុសពី ការទិញលក់ធម្មតា និងការខ្ចីបរិភោគដូចដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ដែលយើងខ្ចីលុយគេហើយយកទៅទិញរបស់អ្វីមួយ ហើយរបស់នោះនឹងក្លាយជាកម្មសិទ្ធិរបស់យើង បន្ទាប់មកយើងត្រូវសងប្រាក់ទៅម្ចាស់បំណុលវិញតាម

[7] ព្រឹត្តិបត្រមេធាវី ត្រីមាសទី៣ លេខ១៤ ខែកក្កដា-កញ្ញា ឆ្នាំ២០១៧ ដោយមេធាវី កុយ គន្ធី

[8] មាត្រា៤ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

[9] មាត្រា១០ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

ការកំណត់។ ស្ថិតក្រោមរូបភាពជាការរំលស់ដូចគ្នា ប៉ុន្តែសកម្មភាពបែបនេះគឺជាការខ្ចីប្រាក់ទៅទិញធម្មតា ហើយភាគីក៏គ្មានសិទ្ធិពិសេសណាមួយដូចច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុដែលយើងបានលើកយកមកសិក្សាទេ។

ថ្វីត្បិតតែរូបរាងខាងក្រៅមើលទៅដូចគ្នាពិតមែន ប៉ុន្តែសារធាតុនៃសិទ្ធិខាងក្នុងមានដូចជា លក្ខខណ្ឌអានុភាព (២.១.១) សិទ្ធិ និងកាតព្វកិច្ចរបស់ភាគី (២.១.២) គឺមិនដូចគ្នានោះទេ។

**២.១.១ លក្ខខណ្ឌអានុភាព**

ជាគោលការណ៍ បុគ្គលគ្រប់រូបមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច។ ឯកិច្ចសន្យាវិញ ក៏ត្រូវបានបង្កើតឡើងដោយសំណើ និងស្ទីការត្រូវគ្នាប៉ុណ្ណោះ ដោយផ្អែកតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដែលជាគោលគំនិតទូទៅនៃនីតិរដ្ឋប្បវេណី។[10] ចំពោះកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុវិញ គឺមិនត្រូវបានបង្កើតឡើងដោយគ្រាន់តែមានការព្រមព្រៀងគ្នារវាងបុគ្គលនិងបុគ្គលធម្មតានោះទេ ពោលគឺសមត្ថភាពជាភាគី និងទម្រង់នៃកិច្ចសន្យា ត្រូវបានកំណត់យ៉ាងជាក់លាក់ ដើម្បីបង្កើតអានុភាពនៃភតិសន្យាហិរញ្ញវត្ថុ ដែលនឹងត្រូវបានសិក្សាក្នុងចំណុចនេះផងដែរ។

**២.១.១.១ សមត្ថភាពភាគី ក្នុងភតិសន្យាហិរញ្ញវត្ថុ**

គោលបំណងនៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ បានកំណត់ដែលថា ដើម្បីលើកស្ទួយដល់ប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ បន្ថែមពីនេះទៀត ក៏បានចែងថា ការអនុវត្តភតិសន្យាអាចធ្វើទៅបានចំពោះតែ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុតែប៉ុណ្ណោះ។ ហេតុនេះ បុគ្គលធម្មតាមិនអាចក្លាយជាភតិបតីក្នុងទំនាក់ទំនងនៃភតិសន្យាហិរញ្ញវត្ថុទេ លុះត្រាតែបុគ្គលនោះ ជាអ្នកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមច្បាប់កំណត់ ទើបការព្រមព្រៀងនាំឱ្យកិច្ចសន្យាមានអានុភាពពេញលេញ។ នេះបង្ហាញឱ្យឃើញថា ភតិសន្យាហិរញ្ញវត្ថុ គឺភាគីម្ខាងពឹងពាក់ធនាគារដើម្បីឱ្យទិញចលនវត្ថុអ្វីមួយដែលខ្លួនចង់បាន ហើយយកឱ្យខ្លួនប្រើប្រាស់វត្ថុនោះដោយភាគីម្ខាងទៀតយកប្រាក់ឈ្នួល ក្នុងនាមជាភតិបតីនៃវត្ថុ។

មាត្រា៣៤ នៃច្បាប់ភតិសន្យាហិរញ្ញវត្ថុ បញ្ញត្តិថា *ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ អាចអនុវត្តបានដោយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលទទួលបានអាជ្ញាប័ណ្ណប្រកបមុខរបរធនាគារពីធនាគារជាតិនៃកម្ពុជា ឬគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ដែលត្រូវបង្កើតឡើងស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុត្រូវសុំអាជ្ញាប័ណ្ណពីធនាគារជាតិកម្ពុជា ដើម្បីប្រកបអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ។ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុមិនត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការផ្សេងទៀតរបស់ធនាគារក្រៅពីប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុឡើយ។*

ដើម្បីធ្វើឱ្យសម្រេចបាន ភតិសន្យាហិរញ្ញវត្ថុមានតួអង្គបីដែលដើរតួគឺ អ្នកផ្គត់ផ្គង់ឧបករណ៍ ភតិបតី និងភតិកៈ។

---

[10] មាត្រា៣៣៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

**ក. ភតិបតី**

ភតិបតី សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលផ្ទេរសិទ្ធិកាន់កាប់ និងសិទ្ធិប្រើប្រាស់ចលនវត្ថុទៅឱ្យភតិក:។[11]

គ្មានបុគ្គលណាម្នាក់ ទោះជារូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវបានអនុញ្ញាតឱ្យធ្វើអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ ដោយគ្មានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជាឡើយ។[12] គ្រឹះស្ថានធនាគារ រួមមាន ធនាគារពាណិជ្ជ ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាចធ្វើអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ ដែលជាផ្នែកមួយនៃប្រតិបត្តិការរបស់ធនាគារ ដូចដែលមានចែងក្នុងមាត្រា២ ចំណុចទី១ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងមាត្រា៣៤ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុបាន ប៉ុន្តែ គ្រឹះស្ថានធនាគារត្រូវសុំអាជ្ញាបណ្ណធ្វើប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ និងការអនុញ្ញាតជាមុនពីធនាគារជាតិនៃកម្ពុជា។[13] លក្ខខណ្ឌសម្រាប់ការស្នើសុំអាជ្ញាប័ណ្ណត្រូវកំណត់ក្នុងប្រកាសលេខ ធ៧-០១១-២៤២ ប្រ.ក ស្តីពីការផ្តល់អាជ្ញាប័ណ្ណចំពោះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ។

ប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ ត្រូវបានអនុវត្តដោយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ។ គ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុដែលទទួលបានអាជ្ញាប័ណ្ណដើម្បីប្រកបអាជីវកម្មភតិសន្យាហិរញ្ញវត្ថុមិនត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការផ្សេងទៀតរបស់ធនាគារក្រៅពីប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុឡើយ។[14]

**ខ. ភតិក:**

បន្ថែមពីលើកម្លាំងពលកម្ម អាជីវកម្មត្រូវការឧបករណ៍ សម្ភារៈផ្សេងៗដើម្បីផលិតរបស់របរ ឬសេវាកម្មរបស់ខ្លួនដើម្បីធ្វើឱ្យសម្រេចបានគោលដៅរបស់ខ្លួន។ ឧបករណ៍ទាំងនោះមានដូចជា ម៉ាស៊ីន រថយន្ត ត្រាក់ទ័រ ម៉ាស៊ីនឈូស ម៉ាស៊ីនបោះពុម្ព។ល។ ឧបករណ៍ និងសម្ភារៈទាំងនេះអាចបានមកពីការទិញ ការខ្ចី ឬការជួលពីបុគ្គល ឬពីក្រុមហ៊ុនណាមួយ។ ឧបករណ៍ខ្លះមានតម្លៃខ្ពស់ ជាហេតុធ្វើឱ្យអាជីវកម្មមួយត្រូវចំណាយដើមទុនច្រើនដើម្បីទិញឧបករណ៍នោះយកមកប្រើការ។ បើចំណាយប្រាក់ច្រើនដើម្បីទិញឧបករណ៍មកប្រើប្រាស់ នោះអាជីវកម្មទាំងឡាយនឹងត្រូវខើចដើមទុនដើម្បីយកទៅចំណាយសម្រាប់ប្រតិបត្តិការផ្សេងៗ។ ដើម្បីកាត់បន្ថយការប្រើប្រាស់ដើមទុនច្រើននៅក្នុងការទិញឧបករណ៍ អាជីវករទាំងអស់អាចទិញដោយបង់ជាវគ្គៗ។ ប៉ុន្តែការទិញលក់ជាវគ្គៗនេះ ទាមទារឱ្យអាជីវកម្មមានជំហរតណាទានល្អ មានន័យថា អាជីវកម្មមានស្ថានភាពហិរញ្ញវត្ថុមួយដែលឱ្យអ្នកលក់ជឿថា អាជីវកម្មនោះអាចមានប្រាក់បង់រំលោះដល់ចប់ចុងចប់ដើមនៃការទិញឧបករណ៍។ ជំនួសឱ្យការទិញ

[11] មាត្រា៤ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

[12] ប្រការ៤ កថាខណ្ឌទី២ នៃប្រកាសលេខ ធ៧-០១១-២៤២ ប្រ.ក ស្តីពីការផ្តល់អាជ្ញាបណ្ណចំពោះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ

[13] ប្រកាស២ នៃប្រកាសស្តីពី អាជីវកម្មភតិសន្យាហិរញ្ញវត្ថុ លេខធ៧-០១១-២៤១ ប្រ.ក

[14] មាត្រា៣៤ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

ផ្ដាច់ ឬការទិញដោយបង់ថ្លៃជាវគ្គ អាជីវករនៅមានវិធីម្យ៉ាងទៀត គឺការជួលឧបករណ៍ប្រើ។[15] ដូច្នេះ គេអាចក្លាយជាអ្នកជួលវត្ថុនោះជំនួសឱ្យការទិញវាបាន ហើយឋានៈរបស់អ្នកជួលក្នុងភតិសន្យាហិរញ្ញវត្ថុក៏មិនខុសគ្នាពីការជួលក្នុងភតិសន្យាធម្មតាដែល ពោលគឺភតិកៈជារូបវន្តបុគ្គល ឬ នីតិបុគ្គលដែលទទួលសិទ្ធិកាន់កាប់ និងសិទ្ធិប្រើប្រាស់ចលនវត្ថុពីភតិបតី។[16] ប៉ុន្តែខុសត្រង់ថា ការជួលនេះ ភតិកៈមានកាតព្វកិច្ចបង់ថ្លៃឈ្នួល ហើយចុងបញ្ចប់នៃកិច្ចសន្យា អ្នកជួលអាចបន្ថែមប្រាក់ទិញផ្ដាច់ ឬ ភតិបតីអាចផ្ទេរកម្មសិទ្ធិឱ្យភតិកៈតែម្ដង។

**គ. អ្នកផ្គត់ផ្គង់**

អ្នកផ្គត់ផ្គង់ សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលភតិបតីទទួលចលនវត្ថុដែលត្រូវជួលឱ្យភតិកៈ។[17] អាចហៅម្យ៉ាងទៀតថា ម្ចាស់ហាងទំនិញដែលត្រូវបានជ្រើសរើសដោយភតិកៈ គឺជាអ្នកផ្គត់ផ្គង់ក្នុងទំនាក់ទំនងភតិសន្យាហិរញ្ញវត្ថុ ហើយអ្នកផ្គត់ផ្គង់ត្រូវប្រគល់វត្ថុដែលភតិបតីបានបង់ប្រាក់រួចទៅឱ្យភតិកៈ។ អ្នកផ្គត់ផ្គង់មិនមានជាភាគីនៅក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុនោះទេ ប៉ុន្តែអ្នកផ្គត់ផ្គង់ជាភាគីនៃកិច្ចព្រមព្រៀងលក់ទិញជាមួយនឹងភតិបតី។ ទោះជាយ៉ាងណាក្ដី កាតព្វកិច្ចរបស់អ្នកផ្គត់ផ្គង់ តាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ ក៏ត្រូវពាក់ព័ន្ធជាមួយនឹងភតិកៈផងដែរ ប្រៀបដូចជាភតិកៈជាភាគីមួយនៃកិច្ចព្រមព្រៀងផ្គត់ផ្គង់ ហើយចលនវត្ថុដែលត្រូវបានជួលហាក់ដូចត្រូវបានផ្គត់ផ្គង់ផ្ទាល់ទៅឱ្យភតិកៈ។ ប៉ុន្តែ អ្នកផ្គត់ផ្គង់មិនទទួលខុសត្រូវលើវិការៈ ចំពោះភតិកៈផង និងភតិបតីផងនោះទេ។[18]

ភតិកៈ និងអ្នកផ្គត់ផ្គង់អាចចុះហត្ថលេខាលើកិច្ចសន្យាថែទាំ ឧបករណ៍ជាមួយភតិកៈ ប្រសិនបើគេចង់ធ្វើដូច្នេះ។[19]

**២.១.១.២ ទម្រង់**

អានុភាពនៃកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ មិនត្រូវបានកើតឡើងដោយគ្រាន់តែមានការព្រមព្រៀងរបស់គូភាគីនោះទេ ច្បាប់បានកំណត់ថា *កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុត្រូវតែសរសេរជាលាយលក្ខណ៍អក្សរ ចុះហត្ថលេខាដោយភតិបតី និងភតិកៈហើយត្រូវកំណត់រយៈពេល និងលក្ខខណ្ឌនៃគ្រប់ភាគីទាក់ទងនឹងចលនវត្ថុដែលបានជួល។ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមិនចាំបាច់មានការបញ្ជាក់ពីសារការីក៏បានដែរ លើកលែងតែមានច្បាប់ណាមួយតម្រូវ។*[20] បន្ថែមពីលើ លក្ខខណ្ឌត្រង់មាត្រា៦ នៃច្បាប់នេះ បានកំណត់នូវលក្ខខណ្ឌមួយ

[15] ព្រឹត្តិបត្រមេធាវី ត្រីមាសទី៣ លេខ១៤ ខែកក្កដា-កញ្ញា ឆ្នាំ២០១៧ ដោយមេធាវី កុយ គន្ធី

[16] មាត្រា៤ នៃច្បាប់ស្ដីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

[17] មាត្រា៤ នៃច្បាប់ស្ដីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

[18] មាត្រា៣១ នៃច្បាប់ស្ដីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

[19] ព្រឹត្តិបត្រមេធាវី ត្រីមាសទី៣ លេខ១៤ ខែកក្កដា-កញ្ញា ឆ្នាំ២០១៧ ដោយមេធាវី កុយ គន្ធី

[20] មាត្រា៥ នៃច្បាប់ស្ដីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

ចំនួនដើម្បីឱ្យកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ មានលក្ខណៈពេញលេញ៖ *កិច្ចព្រមព្រៀងដែលមានលក្ខណៈជាកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ លុះត្រាតែ កិច្ចព្រមព្រៀងនោះមានចែងចំណុចសំខាន់ៗយ៉ាងតិច ដូចខាងក្រោម ៖*

*ក. ការពណ៌នាពីចលនវត្ថុដែលបានជួល*

*ខ. ចំនួនប្រាក់ ការកំណត់គ្រា និងរយៈពេលនៃការបង់ថ្លៃឈ្នួល*

*គ. កាលបរិច្ឆេទចាប់ផ្តើមភតិសន្យាហិរញ្ញវត្ថុ និង*

*ឃ. ហត្ថលេខារបស់ភតិបតី និងភតិកៈ។*

ទាំងសមត្ថភាពជាភាគី និងទម្រង់នៃកិច្ចសន្យាសុទ្ធតែជាលក្ខខណ្ឌដែលមិនអាចខ្វះបានក្នុងការបង្កើតឱ្យមានអានុភាពចំពោះកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ។ ក្រោយពីបានបំពេញលក្ខខណ្ឌអានុភាពហើយ ច្បាប់បានអនុញ្ញាតឱ្យគូភាគីចែងនូវលក្ខខណ្ឌបន្ទាប់បន្សំផ្សេងៗតាមការព្រមព្រៀងរបស់ខ្លួនដូចខាងក្រោម ៖

**ក.ការកំណត់អំពីប្រាក់ប្រាតិភោគ ឬ ការបង់ថ្លៃឈ្នួលជាមុន**

កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ អាចមានចែងពីប្រាក់ប្រាតិភោគ ឬការបង់ថ្លៃជាមុន ឬទាំងពីរតែម្តង។ សម្រាប់ភតិកៈប្រាក់ប្រាតិភោគអាច ឬមិនអាចទទួលនូវចំណូលការប្រាក់ ហើយអាចត្រូវបានបង្វិលឱ្យភតិកៈវិញ ឬអាចប្រើប្រាស់ ដោយភតិបតី ដូចមានចែងក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ។

ករណី កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមិនមានចែងអំពីការប្រើប្រាស់ប្រាតិភោគទេ ប្រាក់ប្រាតិភោគនោះ មិនត្រូវទទួលការប្រាក់ឡើយ និងត្រូវបង្វិលទៅឱ្យភតិកៈវិញ ក្រោយពេលដែលភតិកៈបានបំពេញកាតព្វកិច្ចភតិសន្យាហិរញ្ញវត្ថុបានពេញលេញ និងតាមការកំណត់។ ការបង់ថ្លៃឈ្នួលជាមុនមិនត្រូវទទួលការប្រាក់ទេ។[21] ប្រាក់ប្រាតិភោគ និងការបង់ថ្លៃឈ្នួលជាមុន អាចជាចំនួនប្រាក់ដែលបានព្រមព្រៀងគ្នារវាងភាគីទាំងពីរ។ ពោលគឺ ក្នុងកិច្ចព្រមព្រៀងភតិសន្យា ភាគីទាំងពីរ អាចព្រមព្រៀងក្នុងដោយកំណត់ចំនួនទឹកប្រាក់ណាមួយ ដើម្បីដាក់ជាប្រាក់ប្រាតិភោគ ឬការបង់ថ្លៃឈ្នួលជាមុន ហើយប្រាក់ដែលបានបង់នោះ ភតិកៈ អាចទទួលបានការប្រាក់ ឬមិនអាចទទួល និងអាចត្រូវបានប្រើប្រាស់ដោយភតិបតី អាស្រ័យលើការព្រមព្រៀងរបស់គូភាគី ដោយផ្អែកលើគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន។

**ខ.ការបិទស្លាកសម្គាល់ជាកម្មសិទ្ធិរបស់ភតិបតីលើចលនវត្ថុ**

ភាគីអាចព្រមព្រៀងគ្នាអំពីការបិទស្លាក់សម្គាល់ណាមួយនៅលើកម្មវត្ថុនៃភតិសន្យាហិរញ្ញវត្ថុ ដើម្បីធ្វើការបញ្ជាក់អំពីកម្មសិទ្ធិរបស់ភតិបតីលើចលនវត្ថុនោះ ឬបង្ហាញថាជាកម្មវត្ថុនៃភតិសន្យាហិរញ្ញវត្ថុបាន។ ប្រសិន

[21] មាត្រា៧ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

បើស្លាកត្រូវបានបិទហើយ ស្លាកនោះមិនត្រូវបានដកចេញ ឬធ្វើឱ្យមិនស្គាល់ដោយជនណាមួយ ក្រៅពី ភតិបតី ឬអ្នកតំណាងរបស់ភតិបតីឡើយ។ នៅពេលដែលបានរកឃើញការខូចខាតណាមួយនៃស្លាកសញ្ញាបណ្តាលឱ្យមើលមិនស្គាល់ ភតិកៈត្រូវជូនដំណឹងជាលាយលក្ខអក្សរជាបន្ទាន់ទៅឱ្យភតិបតី ឬបើពុំដូច្នោះទេ ភតិកៈត្រូវទទួលខុសត្រូវក្នុងកម្រិតដែលភតិកៈបានដកស្លាកសម្គាល់ចេញដោយគ្មានការអនុញ្ញាត។ ភតិកៈមិនត្រូវទទួលខុសត្រូវក្រោមមាត្រាណាមួយឡើយ ប្រសិនបើភតិបតីខកខានមិនបានផ្លាស់ប្តូរស្លាកសម្គាល់នោះ ក្រោយភតិកៈបានជូនដំណឹងទាន់ពេលវេលាឱ្យទៅភតិបតីរួចហើយ។[22]

**គ.ការចែងយន្តការសង**

បើភតិកៈ និងភតិបតី ព្រមព្រៀងគ្នាសងតាមវិធីមិនមែនរូបិយវត្ថុ ដូចជា ផលិតផលសេវាកម្ម ការដោះដូរវត្ថុ តម្លៃនៃការទូទាត់សង ក្នុងទំរង់មិនមែនជារូបិយនវត្ថុ ត្រូវកំណត់តាមថ្លៃទីផ្សារ លើកលែងតែ ភាគីទាំងពីរ បានចែងក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុនូវយន្តការណាមួយផ្សេងពីនេះ ។[23]

**២.១.២ សិទ្ធិ និងភាតព្វកិច្ចគូភាគី**

**២.១.២.១ សិទ្ធិនិងភាតព្វកិច្ចភតិបតី**

**ក. សិទ្ធិរបស់ភតិបតី**

➢ **សិទ្ធិជាកម្មសិទ្ធិករ**

ភតិបតី ជាកម្មសិទ្ធិករ នៃកម្មវត្ថុនៃកិច្ចព្រមព្រៀងភតិសន្យា ឬវត្ថុជួល លើកលែងតែ កម្មសិទ្ធិត្រូវបានផ្ទេរទៅឱ្យភតិកៈ ឬទៅឱ្យភាគីផ្សេងទៀត។[24] ដោយសារតែ កិច្ចសន្យាភតិសន្យាហិរញ្ញវត្ថុ គឺជាប្រភេទកិច្ចសន្យាជួលមិនដូចគ្នានឹងហិរញ្ញប្បទានដែលជាកិច្ចសន្យាខ្ចីបរិភោគនោះទេ ដូច្នេះ កម្មវត្ថុនៃកិច្ចសន្យា គឺនៅតែជារបស់ម្ចាស់ហិរញ្ញប្បទានដដែរ លុះត្រាតែ មានការព្រមព្រៀងគ្នាក្នុងការទិញផ្តាច់នៅចុងគ្រា ឬ ការព្រមព្រៀងណាមួយ ដែលអាចឱ្យភតិកៈទទួលបានកម្មវត្ថុលើវត្ថុ ទើបគេអាចក្លាយជាកម្មសិទ្ធិករបាន។

➢ **សិទ្ធិរួចផុតពីការទទួលខុសត្រូវ**

ភតិបតី មិនត្រូវទទួលខុសត្រូវសំណងខូចខាតដែលបានបង្កឡើងដោយចលនវត្ថុដែលបានជួលចំពោះតតិយជនឡើយ ក្នុងអំឡុងពេលនៃកិច្ចសន្យា។[25] ក្រៅពីការមិនទទួលខុសត្រូវរបស់ភតិបតី ចំពោះការខូចខាតដែលកើតឡើងដោយវត្ថុក្នុងអំឡុងពេលជួល ភតិបតីក៏មិនទទួលខុសត្រូវចំពោះការខូចខាតនៃវត្ថុផ្ទាល់ទៀតផងពោលគឺ ភតិបតីគ្រាន់មានសិទ្ធិទាមទារឱ្យអ្នកផ្គត់ផ្គង់ប្រគល់ចលនវត្ថុស្របតាមកិច្ចព្រមព្រៀងទៅឱ្យភតិកៈ ប៉ុន្តែ

[22] មាត្រា៨ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩
[23] មាត្រា៩ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩
[24] មាត្រា១១ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩
[25] មាត្រា១៦ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

ភតិបតីមិនមានកាតព្វកិច្ចទទួលខុសត្រូវលើការខូចខាតដោយសារការខកខានរបស់អ្នកផ្គត់ផ្គង់ឡើយ។[26] ដោយហេតុថា ទាំងកម្មវត្ថុ និងអ្នកផ្គត់ផ្គង់គឺសុទ្ធតែត្រូវបានជ្រើសរើសដោយឆន្ទៈរបស់ភតិកៈទាំងអស់ ហើយភតិបតីគ្រាន់តែមានកាតព្វកិច្ចក្នុងការទូទាត់ថ្លៃទំនិញតែប៉ុណ្ណោះ ដូចនេះការត្រួតពិនិត្យគុណភាព ឬចំណុចផ្សេងៗនៃវត្ថុភតិកៈសុទ្ធតែជាអ្នកធ្វើសកម្មភាពដោយខ្លួនឯង។

ម៉្យាងទៀត ក្នុងករណីដែលភតិកៈបានទទួលរងការខាតបង់ដោយសារការអន្តរាគមន៍របស់ភតិបតីក្នុងការជ្រើសរើស ឬ ក្នុងការកំណត់យថាប្រភេទនៃចលនវត្ថុ។[27] ករណីនេះ យើងឃើញថា ប្រសិនបើភតិបតីបានចូលរួមអន្តរាគមន៍ ឬបានកំណត់យថាប្រភេទក្នុងការជ្រើសរើសរបស់ភតិកៈហើយស្រាប់តែវត្ថុនោះ មានការខូចខាត ភតិបតីក៏ត្រូវតែទទួលខុសត្រូវផងដែរ ព្រោះបានចូលរួមក្នុងសកម្មភាពនៃការជ្រើសរើស។

➢ **សិទ្ធិទាមទារឱ្យសំណង**

ភតិបតី មានសិទ្ធិទាមទារឱ្យភតិកៈសងការខាតបង់បំណុល ការខូចខាត ឬផលវិបាកផ្សេងណាមួយ ឬទាំងអស់ ដែលកើតចេញពីការប្រើប្រាស់ និងការកាន់កាប់របស់ភតិកៈលើចលនវត្ថុដែលបានជួល។[28] ក្នុងនាមជាអ្នកជួលភតិកៈ ត្រូវមានករណីកិច្ចថែរក្សា និងប្រើប្រាស់វត្ថុជួលឱ្យបានត្រឹមត្រូវផងដែរ ជៀសវាងការប្រើប្រាស់ ឬការមិនបានថែរក្សានាំឱ្យមានការខូចខាតដល់វត្ថុដែលខ្លួនបានកាន់កាប់។ ប្រសិនបើការកាន់កាប់ និងប្រើប្រាស់របស់ភតិកៈបានបង្កឱ្យមានការខូចខាតនោះ ភតិកៈក៏ត្រូវសងការខូចខាតតាមការទាមទាររបស់ភតិបីផងដែរ។ ដើម្បីការពារដល់បញ្ហាទាំងនេះ ឃើញថា ក្នុងប្រតិបត្តិការខ្លះមានការទាមទារឱ្យភតិកៈទិញធានារ៉ាប់រងលើចលនវត្ថុដែលបានជួលទៀតផង។

➢ **សិទ្ធិទាមទារឱ្យបង់ថ្លៃធានារ៉ាប់រង**

ភតិបតីអាចទាមទារឱ្យភតិកៈទិញ និងបង់ថ្លៃធានារ៉ាប់រងលើចលនវត្ថុដែលបានជួលនៅក្នុងអំឡុងពេលដែលភតិកៈកាន់កាប់ ឬគ្រប់គ្រងចលនវត្ថុ ទោះបីជារយៈពេលអនុវត្តភតិសន្យាហិរញ្ញវត្ថុ បានឈានដល់ទីបញ្ចប់ហើយ ឬកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុត្រូវបានរំលាយមុនពេលក៏ដោយ។ ជារួម ភតិកៈត្រូវទិញធានារ៉ាប់រងរហូតដល់ពេលដែលចលនវត្ថុនោះត្រូវបានប្រគល់ឱ្យភតិបតីកាន់កាប់ និងគ្រប់គ្រងវិញ។ គ្រប់ពេលដែលភតិកៈកាន់កាប់ចលនវត្ថុមិនថាការកាន់កាប់នោះស្ថិតក្នុងអំឡុងពេលនៃភតិសន្យាហិរញ្ញវត្ថុ ឬ ក្រោយការរំលាយភតិសន្យាហិរញ្ញវត្ថុក៏ដោយ ឱ្យតែមានការកាន់កាប់ចលនវត្ថុ ភតិបតីមានសិទ្ធិទាមទារឱ្យភតិកៈទិញធានារ៉ាប់រងតែម្តង។ ប្រសិនបើ ភតិកៈខកខានមិនបានទិញតាមការទាមទារ ភតិបតីមានសិទ្ធិទិញតែមិនមានភារកិច្ចតែមិនត្រូវ

[26] មាត្រា ២៣ កថាខណ្ឌទី២ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

[27] មាត្រា ១៥ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

[28] មាត្រា ១៨ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

ទិញធានារ៉ាប់រងនេះទេ ភតិកៈត្រូវសងរាល់ការចំណាយទៅឱ្យភតិបតីវិញភ្លាម ប្រសិនបើភតិបតីបានចំណាយរួចហើយ។[29] មានន័យថា ប្រសិនបើភតិកៈដែលជាបុគ្គលត្រូវមានកាតព្វកិច្ចទិញធានារ៉ាប់រងលើវត្ថុជួល ប៉ុន្តែបែរជាមិនបានទិញធានារ៉ាប់រង ភតិបតីមានសិទ្ធិទិញជំនួសភតិកៈជាមុន ដោយសារតែភតិបតីមិនមែនជាបុគ្គលមានកាតព្វកិច្ចត្រូវទិញធានារ៉ាប់រងទេ។ ដូច្នេះ ភតិបតីមានសិទ្ធិទាមទាររាល់ការចំណាយទិញធានារ៉ាប់រងពីភតិកៈវិញនៅពេលក្រោយ។

- **សិទ្ធិចាត់ចែងលើកម្មវត្ថុនៃភតិសន្យាហិរញ្ញវត្ថុ**

ភតិបតីមានសិទ្ធិចាត់ចែង ផ្ទេរ ឬបែងចែកសិទ្ធិទាំងអស់ ឬមួយផ្នែករបស់ខ្លួនលើចលនវត្ថុដែលជួល ទៅឱ្យភាគីណាមួយបាន ដោយមិនបាច់មានការយល់ព្រមពីភតិកៈឡើយ។ ការផ្ទេរបែបនេះ មិនត្រូវធ្វើឱ្យភតិបតីរួចផុតពីកាតព្វកិច្ចណាមួយ ឬ ផ្លាស់ប្តូរភាពដើមនៃកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុទេ។ ពោលគឺ សិទ្ធិ និងកាតព្វកិច្ចរបស់គូភាគីនៅរក្សាភាពដើមដដែរ។ ក្នុងករណីនេះ គូភាគីក៏អាចចែងបន្ថែមនៅក្នុងកិច្ចព្រមព្រៀងថា ភតិកៈយល់ព្រមមិនទាមទារការកាត់កង ការពារ ឬទាមទារប្រឆាំងនឹងអ្នកដែលត្រូវបានប្រគល់សិទ្ធិ ឬអនុប្បទានិករបស់ភតិបតីឡើយ។[30]

ម៉្យាងទៀត ករណីដែលភតិបតីក្ស័យធន ឥណទាយករបស់ភតិបតី និងភាគីពាក់ព័ន្ធផ្សេងទៀតមិនមានសិទ្ធិច្រើនជាងសិទ្ធិដែលភតិបតីមានតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុនោះទេ។[31]

- **សិទ្ធិទាមទារក្នុងករណីរងការបំពានកិច្ចសន្យា**

នៅពេលដែលមានការបំពានកិច្ចសន្យាកើតឡើង គឺត្រូវតែមានករណីសង្គ្រោះកិច្ចសន្យាកើតឡើងស្រប ជាមួយគ្នា គ្រាន់តែការសង្គ្រោះនោះម្ចាស់សិទ្ធិអាចអនុវត្តសិទ្ធិសង្គ្រោះបានដោយខ្លួនឯង ឬត្រូវប្រើសិទ្ធិពឹងពាក់តុលាការដើម្បីសង្គ្រោះប្រយោជន៍ពីការបំពាន។ សិទ្ធិទាមទារចំពោះការបំពានក្នុងចំណុចនេះ ច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុបានកំណត់ លក្ខខណ្ឌនៃការបំពាន និងផ្តល់សិទ្ធិឱ្យភតិបតីអាចទាមទារដូចមានខាងក្រោម៖

- **សិទ្ធិទាមទារឱ្យបង់ថ្លៃឈ្នួល**

ភតិបតី អាចទាមទារឱ្យភតិកៈបង់ថ្លៃឈ្នួលដែលមិនទាន់បង់ រួមទាំងសំណងការខូចខាត និងការប្រាក់ ឬអាចទាមទារឱ្យពន្លឿនការបង់ថ្លៃឈ្នួលអនាគត។ មានន័យថា ប្រសិនបើភតិកៈបានបំពានកិច្ចសន្យា ភតិបតីអាចទាមទារឱ្យភតិកៈ បង់ថ្លៃឈ្នួលរួម និងការខូចខាតបន្ត ឬអាចទាមទារឱ្យភតិកៈត្រូវពន្លឿនការបង់ថ្លៃឈ្នួលនោះតែម្តង វាអាស្រ័យតាមឆន្ទៈរបស់ភតិបតីថាចង់ទាមទារបែបណា។

---

[29] មាត្រា១៩ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

[30] មាត្រា២១ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

[31] មាត្រា២២ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

- **សិទ្ធិរំលាយកិច្ចព្រមព្រៀង ទាមទារឱ្យប្រគល់ត្រលប់**

ភតិបតីអាចរំលាយកិច្ចព្រមព្រៀង ទាមទារឱ្យប្រគល់វត្ថុដែលបានជួលមកវិញ ប្រសិនបើភតិកៈបានបំពានក្នុងករណីដូចខាងក្រោម [32]៖

- ភតិកៈមិនបានបង់ថ្លៃឈ្នួលតាមកិច្ចសន្យារយៈពេលពីរគ្រា ជាបន្តបន្ទាប់
- ភតិកៈបំពានខណាមួយនៃកិច្ចសន្យា និងខកខានមិនបានដោះស្រាយតាមការជូនដំណឹងជាលាយលក្ខណ៍អក្សរពីភតិបតីរយៈពេល១០ថ្ងៃ គិតពីថ្ងៃទទួលការជូនដំណឹង។
- ភតិកៈមានអ្នកធានាដែលគ្មានសាធនភាព ក្ស័យធន ឬ ត្រូវបានរំលាយ ហើយមិនអាចរកអ្នកធានាជំនួសណាម្នាក់ដែលភតិបតីអាចទទួលយកបាន ក្នុងរយៈពេល៣០ថ្ងៃ តាមការស្នើសុំឱ្យរកអ្នកជំនួសជាលាយលក្ខណ៍អក្សរពីភតិបតី។
- ភតិកៈគ្មានសោធនភាព ក្ស័យធន ត្រូវបានរំលាយ ឬមរណភាពហើយពុំមានអ្នកស្នងបន្ត។

ប្រសិនបើមានហេតុដូចដែលបានកំណត់ខាងលើនេះ ភតិបតីអាចទាមទារយកចលនវត្ថុដែលបានជួលមកកាន់កាប់វិញដោយមិនចាំបាច់ប្ដឹងទៅតុលាការ ប្រសិនបើបានធ្វើឡើងដោយអហិង្សា[33] ឬភតិបតីអាចដាក់ពាក្យសុំដីកាសម្រេចពីតុលាការឱ្យភតិកៈប្រគល់វត្ថុជួលបើសិនជាចាំបាច់។[34] ក្រៅពីនេះ ភតិបតីក៏អាចទាមទារសំណងខូចខាត ដែលភតិបតីត្រូវទទួលរាប់រងទាំងការចំណាយបន្ថែម ដែលបណ្ដាលមកពីកំហុសរបស់ភតិកៈផងដែរ។[35] នៅក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ គូភាគីអាចចែងអំពីវិធីគណនាការខូចខាត ហើយវិធីនេះអាចអនុវត្តបានដោយភាគីសងខាង លើកលែងតែ វិធីគណនានោះ បណ្ដាលឱ្យមានវិការៈធ្ងន់ធ្ងរលើលពីសំណងការខូចខាតដែលភតិបតីអាចនឹងទទួលបាន ប្រសិនបើភតិកៈអនុវត្តតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ។

**ខ.ភាតព្វកិច្ចរបស់ភតិបតី**

- **កាតព្វកិច្ចទូទាត់ថ្លៃទំនិញ**

ភតិបតី ត្រូវទូទាត់ថ្លៃទិញចលនវត្ថុឱ្យទៅអ្នកផ្គត់ផ្គង់នៅពេលដែលភតិកៈបានយល់ព្រមទទួលចលនវត្ថុដោយគ្មានលក្ខខណ្ឌ។[36] ឧទាហរណ៍ កសិករម្នាក់ចង់ទិញម៉ាស៊ីនកិនស្រូវធំមួយដើម្បីទទួលបានភតិសន្យាហិរញ្ញវត្ថុ តើគេត្រូវធ្វើដូចម្ដេចខ្លះ? ចម្លើយគឺ មានបុគ្គលបីនាក់ដែលពាក់ព័ន្ធ ទី១ គឺអ្នកជួល(ហៅថា ភតិកៈ) ទី២ អ្នកឱ្យជួល(ហៅថាភតិបតី) និងទី៣ ជាអ្នកផ្គត់ផ្គង់។ អ្នកជួល ឬកសិករនោះត្រូវទាក់ទងជាមួយក្រុមហ៊ុនភតិសន្យា

[32] មាត្រា១៧ ចំណុច ខ នៃច្បាប់ស្ដីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

[33] មាត្រា១៧ ចំណុច គ នៃច្បាប់ស្ដីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

[34] មាត្រា១៧ ចំណុច ឃ នៃច្បាប់ស្ដីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

[35] មាត្រា នៃច្បាប់ស្ដីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

[36] មាត្រា១៣ នៃច្បាប់ស្ដីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

ហិរញ្ញវត្ថុ ដើម្បីប្រាប់ថាខ្លួនចង់ជួលម៉ាស៊ីនកិនស្រូវនោះ។ ក្រុមហ៊ុនប្រាប់អ្នកជួលឱ្យទៅក្រុមហ៊ុនផ្គត់ផ្គង់ដើម្បីជ្រើសរើសដោយខ្លួនឯងនូវម៉ាក ប្រភេទ ស៊េរីម៉ាស៊ីនកិនស្រូវណាមួយដែលខ្លួនចង់បាន រួចយកព័ត៌មានស្តីពីម៉ាក ប្រភេទ ស៊េរីម៉ាស៊ីនកិនស្រូវនោះមកប្រាប់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ។ បន្ទាប់មកអ្នកទាំងពីរត្រូវចុះហត្ថលេខាលើភតិសន្យា។ បន្ទាប់មកទៀត ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុចុះកិច្ចសន្យាទិញ និងផ្គត់ផ្គង់ម៉ាស៊ីនកិនស្រូវនោះទៅកសិករ។ ដូច្នេះ យើងឃើញថា ក្រុមហ៊ុនបានចេញប្រាក់ថ្លៃទិញឧបករណ៍ជំនួសឱ្យកសិករដែលគ្មានប្រាក់ដុលទៅទិញម៉ាស៊ីនកិនស្រូវ។

- **កាតព្វកិច្ចបង់ពន្ធ**

ភតិបតី ត្រូវទទួលខុសត្រូវបង់ពន្ធនាំចូល និងកាតព្វកិច្ចសារពើពន្ធផ្សេងទៀតដែលច្បាប់កំណត់ ព្រមទាំង សោហ៊ុយចុះបញ្ជី លើកលែងតែមានការកំណត់ផ្សេង។[37] ភតិសន្យាហិរញ្ញវត្ថុ មិនបានកំណត់ថាកម្មវត្ថុត្រូវនៅកន្លែងណានោះទេ ហេតុនេះ ប្រសិនបើកម្មវត្ថុនៃភតិសន្យាហិរញ្ញវត្ថុជាទំនិញដែលនៅក្រៅប្រទេស ហើយត្រូវមានការនាំចូល ជាគោលការណ៍ ភតិបតីជាអ្នកដែលមានកាតព្វកិច្ចក្នុងការបង់ពន្ធនាំចូល ប៉ុន្តែ ភាគីក៏អាចព្រមព្រៀងផ្សេងពីនេះបាន។

- **កាតព្វកិច្ចធានាដល់ការប្រើប្រាស់របស់ភតិកៈ**

ត្រូវធានាយ៉ាងណាឱ្យភតិកៈប្រើប្រាស់ និងកាន់កាប់វត្ថុដែលបានជួលដោយគ្មានការរំខាននៅក្នុងអំឡុងពេលនៃកិច្ចសន្យា លើកលែងតែ ភតិកៈបំពានកិច្ចសន្យា។[38] ទោះបីជាមានសិទ្ធិជាកម្មសិទ្ធិករក្តី ក៏ភតិបតីមិនអាចរំខានដល់ការប្រើប្រាស់ និងអាស្រ័យផលរបស់ភតិកៈដែលជាអ្នកដែលកាន់កាប់វត្ថុជួលដោយស្របច្បាប់ និងត្រឹមត្រូវនោះទេ លុះត្រាណាតែ ភតិកៈបានប្រើប្រាស់វត្ថុនោះដោយផ្ទុយពីការកំណត់ក្នុងកិច្ចសន្យា ឬមានហេតុណាមួយដែលបានកើតឡើងដែលធ្វើឱ្យភតិបតីត្រូវតែដកហូតវត្ថុនោះត្រលប់មកវិញ បើមិនដូច្នេះទេ សកម្មភាពផ្សេងៗរបស់ភតិបតី ដែលធ្វើឱ្យមានការលំបាក ឬរំខានដល់ការប្រើប្រាស់វត្ថុរបស់ភតិកៈ ត្រូវចាត់ទុកថាជាការបំពាន ហើយភតិបតីត្រូវទទួលខុសត្រូវចំពោះការខូចខាតដែលកើតឡើងដោយអំពើនោះ។

- **កាតព្វកិច្ចទទួលខុសត្រូវលើសំណង**

ភតិបតី ត្រូវទទួលខុសត្រូវចំពោះភតិកៈលើការខូចខាតនៃចលនវត្ថុ ករណីភតិបតីបានធ្វើអន្តរាគមន៍ក្នុងការជ្រើសរើស ឬ ក្នុងការកំណត់យថាប្រភេទនៃវត្ថុជួល។[39] ក្រៅពីករណីនេះ ភតិបតី ក៏ត្រូវទទួលរងការខូចខាតទាំងឡាយដែលកើតឡើងដល់ភតិកៈ ក្នុងករណីដែលភតិបតី បានប្តឹងទាមទារឱ្យភតិកៈប្រគល់ត្រលប់នូវកម្មវត្ថុ

[37] មាត្រា១២ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

[38] មាត្រា១៤ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

[39] មាត្រា១៥ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

នៃកិច្ចសន្យា ដោយមានភស្តុតាងបញ្ជាក់ថា ការទាមទារចលនវត្ថុដែលបានជួលមកវិញរបស់ភតិបតី ជាការរំលោភលើកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ។[40]

### ២.១.២.២ សិទ្ធិនិងភាតព្វកិច្ចភតិកៈ

### ក.សិទ្ធិរបស់ភតិកៈ

- **សិទ្ធិបដិសេធទទួលវត្ថុ**

ភតិកៈមានសិទ្ធិបដិសេធទទួលយកចលនវត្ថុ ហើយទាមទារឱ្យអ្នកផ្គត់ផ្គង់ជួសជុលវិការៈ ឬរំលាយភតិសន្យាហិរញ្ញវត្ថុបាន ប្រសិនបើចលនវត្ថុនោះមិនត្រូវបានប្រគល់ ឬប្រគល់យឺតពេល ឬមិនត្រូវតាមកិច្ចព្រមព្រៀងផ្គត់ផ្គង់។ ប៉ុន្តែ ភតិកៈគ្មានសិទ្ធិរំលាយ ដកហូត ឬ កែប្រែកិច្ចព្រមព្រៀងផ្គត់ផ្គង់ ដោយពុំមានការយល់ព្រមពីភតិបតីនោះទេ។[41] ភតិកៈ ជាភាគីនៃកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ដែលមានគូភាគី ជាភតិបតី ហេតុនេះ គេគ្មានទំនាក់ទំនងជាមួយនឹងអ្នកផ្គត់ផ្គង់ក្នុងកិច្ចសន្យាលក់ទិញនោះទេ ដូច្នេះ ប្រសិនបើ ចលនវត្ថុមានវិការៈ ឬមិនបានប្រគល់តាមការកំណត់ គេគ្រាន់តែអាចទាមទារឱ្យអ្នកផ្គត់ផ្គង់នោះ ជួសជុលវិការៈ ឬ រំលាយកិច្ចព្រមព្រៀងភតិសន្យាតែប៉ុណ្ណោះ គេមិនអាចទៅរំលាយកិច្ចសន្យារវាងអ្នកផ្គត់ផ្គង់ និងភតិបតីឡើយ។ ប្រសិនបើ ចលនវត្ថុមានវិការៈ ហើយភតិកៈបានទាមទារឱ្យអ្នកផ្គត់ផ្គង់ជួសជុលវិការៈ ប៉ុន្តែ អ្នកផ្គត់ផ្គង់មិនបានជួសជុលតាមការស្នើសុំទេ ភតិកៈអាចជូនដំណឹងទៅភតិបតីបាន ដើម្បីឱ្យភតិបតីទាមទារទៅអ្នកផ្គត់ផ្គង់បន្ត។ ប្រសិនបើ មិនអាចដោះស្រាយបានទេ ភតិកៈមានសិទ្ធិរំលាយកិច្ចសន្យាភតិសន្យា។ ភតិបតីក៏មានសិទ្ធិរំលាយកិច្ចព្រមព្រៀងផ្គត់ផ្គង់បានដែរ។

ការបញ្ជាក់អំពីការយល់ព្រមទទួលយកចលនវត្ថុដោយភតិកៈ អាចធ្វើឡើងតាមរយៈមធ្យោបាយផ្សេងៗ ដូចជា៖ ក្រោយពេលដែលភតិកៈបានពិនិត្យចលនវត្ថុដែលត្រូវជួលរួចហើយ ហើយបានបញ្ជាក់ថា អាចទទួលយកបាន ទោះបីជា ចលវត្ថុនោះស្រប ឬមិនស្របតាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ក៏ដោយ ឬ ក្នុងករណីដែល ភតិកៈមិនបានជូនដំណឹងទាន់ពេលវេលាដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងផ្គត់ផ្គង់ ពីភាពមិនស្របតាមកិច្ចព្រមព្រៀងផ្គត់ផ្គង់ទៅភតិបតី និង អ្នកផ្គត់ផ្គង់ដើម្បីឱ្យអ្នកផ្គត់ផ្គង់ ឬភតិបតី ដោះស្រាយទាន់ពេលវេលាក្រោយពេលបានទទួលដំណឹងនោះ។

ហើយនៅក្នុងកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុអាចចែងថា ភតិកៈត្រូវចាត់ទុកថាយល់ព្រមទទួលចលនវត្ថុ លើកលែងតែ ភតិបតីបានទទួលសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធរបស់ភតិកៈដែល

[40] មាត្រា ១៧ ចំណុច ឃ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

[41] មាត្រា ២៣ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

មានរាយលម្អិតពីមូលហេតុច្បាស់លាស់ក្នុងរយៈពេលកំណត់១០ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីភតិកៈបានទទួលចលនវត្ថុនោះ។

➢ **សិទ្ធិទាមទារសំណង**

មិនមែនមានតែភតិបតីដែលទទួលរងការបំពាននោះទេ ក្នុងករណីដែលភតិកៈទទួលរងការខូចខាតផលប្រយោជន៍ដោយសារភតិបតី គេក៏អាចទទួលបានសិទ្ធិសង្គ្រោះដូចគ្នា។ កាលណាមានការបំពានកិច្ចសន្យាពីភាគីម្ខាងទៀត ភាគីម្ខាងដែលរងការបំពានអាចមានសិទ្ធិសង្គ្រោះកិច្ចសន្យាបាន ដោយការរំលាយកិច្ចសន្យាទាមទារសំណងខូចខាត ឬ អនុវត្តដោយបង្ខំបាន។[42]

ក្នុងករណីដែលភតិបតី បានទាមទារឱ្យប្រគល់ត្រលប់ ដោយមូលហេតុមិនត្រឹមត្រូវ ហើយបានធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភតិកៈ ក្នុងនាមជាអ្នករងការខូចខាត ភតិកៈអាចទាមទារឱ្យភតិបតីទទួលខុសត្រូវចំពោះខ្លួនបាន។

ច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ មានគោលបំណងក្នុងការអភិវឌ្ឍប្រព័ន្ធធនាគារ និងភតិសន្យាហិរញ្ញវត្ថុ ហេតុនេះ ភតិបតីដែលជាម្ចាស់ហិរញ្ញប្បទានក៏អាចមានច្រើននឹងពិសេសជាងភតិកៈ ហើយជាធម្មតា ការខូចខាតមិន ជាកើតមានឡើងដោយសារម្ចាស់បំណុលទេ ព្រោះក្នុងនាមជាម្ចាស់បំណុលគ្រាន់តែចង់ធ្វើយ៉ាងណាឱ្យកិច្ចសន្យាត្រូវបានអនុវត្តទៅបានល្អប្រសើរតែប៉ុណ្ណោះ ដោយមិនបង្កឱ្យមានបញ្ហាណាមួយកើតឡើង។ ការលើកឡើង នេះ មិនមែនមានន័យថា ម្ចាស់បំណុលមិនអាចបង្កការខូចខាតដល់កូនបំណុលទេ ពោលគឺ ភតិបតីនៅតែអាចបង្កឱ្យមានការខូចខាតណាមួយកើតឡើងចំពោះភតិកៈ គ្រាន់តែសកម្មភាពដែលនាំឱ្យមានការបំពានមិនមានច្រើន។ ដូច្នេះហើយ ភតិកៈត្រូវត្រួតពិនិត្យនូវឧបករណ៍ដែលខ្លួនចង់បានឱ្យច្បាស់លាស់ មុននឹងទទួលយកទៅប្រើប្រាស់ និងត្រូវបង់ថ្លៃឈ្នួលទៅភតិបតីតាមការកំណត់ ហើយប្រសិនបើក្នុងអំឡុងពេលកាន់កាប់ភតិបតីប្រើប្រាស់សិទ្ធិដោយបំពាន ឬរំខានដល់ការប្រើប្រាស់របស់ខ្លួនវិញ ភតិកៈក៏អាចអនុវត្តសិទ្ធិទាមទាររបស់ខ្លួនដែលច្បាប់បានផ្តល់ឱ្យ។

ចំណុចបន្ទាប់មកទៀត យើងនឹងសិក្សាអំពី កាតព្វកិច្ចរបស់ភតិកៈវិញម្តង ថាតើគេត្រូវមានករណីកិច្ចអ្វីខ្លះចំពោះភតិបតី។

**ខ.កាតព្វកិច្ចភតិកៈ**

➢ **កាតព្វកិច្ចទទួលចលនវត្ថុ**

ភតិកៈ មានកាតព្វកិច្ចត្រូវយល់ព្រមទទួលចលនវត្ថុដែលខ្លួនបានជួល បើចលនវត្ថុនោះ ត្រូវបានប្រគល់ទាន់ពេលវេលាកំណត់ និងត្រឹមត្រូវតាមកិច្ចព្រមព្រៀងផ្គត់ផ្គង់។

[42] មាត្រា ៣៩០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

➢ **កាតព្វកិច្ចបង់ថ្លៃឈ្នួល**

ក្រោយពីបានចរចារជ្រើសរើសទំនិញពីអ្នកផ្គត់ផ្គង់ និងបានទទួលការយល់ព្រមជួលឧបករណ៍ពីភតិបតីហើយ។ ភតិបតី និងអ្នកផ្គត់ផ្គង់ត្រូវចុះកិច្ចសន្យាលក់ទិញឧបករណ៍សម្រាប់ជួលឱ្យភតិកៈ បន្ទាប់មក ភតិកៈត្រូវចុះហត្ថលេខាទទួលយកឧបករណ៍ រួចធ្វើសេចក្តីបញ្ជាក់ថាខ្លួនបានទទួលឧករណ៍នោះ។

ភតិកៈត្រូវបង់ថ្លៃឈ្នួលតាមកិច្ចព្រមព្រៀងដោយមិនអាចបដិសេធបាន នៅពេលដែលខ្លួនបានយល់ព្រមទទួលចលនវត្ថុជាផ្លូវការហើយ។[43] មានន័យថា ក្រោយពីមានកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ភតិកៈមិនអាចបដិសេធក្នុងការមិនទទួលយកឧបករណ៍នោះវិញជាដាច់ខាត ព្រោះភតិបតីគ្មានមូលហេតុណាមួយក្នុងការទិញឧបករណ៍ឡើយ ក្រៅពីយកមកជួលឱ្យភតិកៈ។ ដូច្នេះ ប្រសិនបើភតិកៈប្រែក្រឡាស់មិនជួលវិញនឹងធ្វើឱ្យភតិបតីខាតបង់ផលប្រយោជន៍ជាក់ជាមិនខាន។ ហេតុនេះ ច្បាប់បានកំណត់ថា ភតិកៈមិនអាចបដិសេធក្នុងការបង់ថ្លៃឈ្នួលដាច់ខាត ក្រោយពេលដែលខ្លួនយល់ព្រមទទួលយកឧបករណ៍ជាផ្លូវការ។

ថ្លៃឈ្នួលដែលភតិកៈបង់ ត្រូវគិតរួមជាមួយនឹងអត្រាការប្រាក់ដែលភាគីបានព្រមព្រៀងគ្នា ហើយអត្រាការប្រាក់ដែលកំណត់នេះ ត្រូវកម្រិតត្រឹម ១៨% ក្នុងមួយឆ្នាំ ដោយអនុលោមតាមប្រកាសស្តីពី អត្រាការប្រាក់ដែលត្រូវបានកម្រិត ដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[44] បន្ថែមពីលើការបង់ថ្លៃឈ្នួលធម្មតា មានករណីមួយចំនួនភតិកៈត្រូវបង់ប្រាក់ប្រាតិភោគ ឬបង់ថ្លៃឈ្នួលជាមុន ឬបង់ទាំងពីរតែម្តង ផ្អែកតាមការព្រមព្រៀងរបស់គូភាគី។ ប្រសិនបើ មានការបង់ប្រាក់ប្រាតិភោគភតិកៈអាច ឬ មិនអាចទទួលការប្រាក់ ហើយត្រូវបង្វិលទៅភតិកៈ ឬ ត្រូវបានប្រើប្រាស់ដោយភតិបតី ដោយមានចែងក្នុងកិច្ចព្រមព្រៀង។ ករណី ដែលកិច្ចព្រមព្រៀងមិនបានចែងអំពីការប្រើប្រាស់ការប្រាក់ទេ ប្រាក់ប្រាតិភោគនោះមិនត្រូវទទួលការប្រាក់ឡើយ ហើយត្រូវបង្វិលទៅភតិកៈវិញ ក្រោយពេលដែលភតិកៈបានបំពេញកាតព្វកិច្ចពេញលេញតាមការកំណត់។ ការបង់ថ្លៃឈ្នួលជាមុននេះ មិនត្រូវទទួលបានការប្រាក់នោះទេ មានតែប្រាក់ប្រាតិភោគប៉ុណ្ណោះដែលអាចទទួលបានការប្រាក់ ហើយទំហំនៃប្រាក់ដែលត្រូវបង់ក៏អាស្រ័យលើការកំណត់របស់គូភាគីដូចគ្នា។[45] របៀបនៃការបង់ប្រាក់ឈ្នួលនៃភតិសន្យាហិរញ្ញវត្ថុ យើងនឹងលើកយកការអនុវត្តជាក់ស្តែងរបស់ស្ថាប័នធនាគារធំៗពីរ ដែលបាននឹងកំពុងអនុវត្តជាក់ស្តែងលើបញ្ហានេះ ព្រមទាំងការបង់ប្រាក់របស់ក្រុមហ៊ុន តូយូតា ខេមបូឌា ដូចដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធផងដែរ។

---

[43] មាត្រា២៥ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

[44] ប្រកាស ស្តីពី អត្រាការប្រាក់ដែលត្រូវបានកម្រិត លេខ ១២៨កយ.ប្រក/១១. ២១ ធ្នូ ២០១១

[45] មាត្រា៧ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ. លេខ នស/រតម/០៦០៩/០០៨ .២០ មិថុនា ២០០៩

ចំពោះ របៀប នៃការបង់ប្រាក់ឈ្នួលត្រឡប់ នៃសេវាភតិសន្យាហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា វិញ អតិថិជនអាចបង់ប្រាក់តាម បីរបៀប ៖

១. បង់ការប្រាក់ និងប្រាក់ដើមរំលស់ (liner) ជារៀងរាល់ខែ

២. បង់រំលស់ប្រាក់ដើមបូកការប្រាក់ថេរ (Annuity) ជារៀងរាល់ខែ

៣. បង់ការប្រាក់ និងប្រាក់ដើមមួយចំនួនតាមការព្រមព្រៀងរៀងរាល់ខែ ហើយប្រាក់ដើមនៅសល់បង់ចុងវគ្គ។ ការបង់ប្រាក់ដូចចំណុចទាំងបី ខាងលើ ប្រាក់ដើមដែលនៅសល់បង់ចុងវគ្គ ត្រូវតិចជាង ៣០% នៃទំហំភតិសន្យាហិរញ្ញវត្ថុ។ ចំណែកឯ របៀបនៃការបង់រំលស់នៅខាងធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី (CIMB Plc.) គឺការបង់ឥណទានរថយន្តអាចបង់រំលស់ថេរប្រចាំខែ។ តាមពាក្យបច្ចេកទេស គឺការបង់រំលស់ថេរប្រចាំខែ ឬហៅថា EMI។ ចំនួនទឹកប្រាក់បង់រំលស់ប្រចាំខែ គឺអាស្រ័យលើទំហំទឹកប្រាក់ឥណទាន រយៈពេលឥណទាន និងអត្រាការប្រាក់នៃឥណទាន។ អតិថិជនបង់រំលស់ប្រាក់ដើម និងការប្រាក់(EMI) ទៅធនាគារនៅថ្ងៃដំបូង រៀងរាល់ខែនីមួយៗ។ ប្រសិនបើខែដំបូងមិនបានពេញមួយខែទេនោះ អតិថិជននឹងត្រូវបង់តែការប្រាក់ប៉ុណ្ណោះ។ រយៈពេលបង់រំលស់តែអត្រាការប្រាក់នេះ ហៅថា Pre-EMI។ ការបង់រំលស់ប្រាក់ដើម និងការប្រាក់(EMI) នឹងចាប់ផ្ដើមនៅខែបន្ទាប់។ EMI = ប្រាក់ដើម + ការប្រាក់។ ប្រាក់ដើមឥណទាន ត្រូវបានថយចុះ បន្ទាប់ពីមានការបង់រំលស់ជារៀងរាល់ខែ។ ការប្រាក់ត្រូវបានគណនា លើសមតុល្យប្រាក់ដើមនៅសល់។ ក្នុងរយៈពេលផ្ដើមដំបូង EMI នឹងគិតលើការប្រាក់ ជាចម្បង។ គិតរហូតដល់ចប់ឥណទាន EMI នឹងគិតលើប្រាក់ដើម ជាចម្បង។

- **កាតព្វកិច្ចថែរក្សាវត្ថុ**

ភតិកៈ ត្រូវប្រើប្រាស់ចលនវត្ថុឱ្យបានត្រឹមត្រូវតាមមុខសញ្ញាប្រើប្រាស់តាមច្បាប់ វិធាន និងបទបញ្ជាជាធរមាន និងតាមលក្ខណៈបច្ចេកទេស និងត្រូវចំណាយលើការថែទាំ និងជួសជុលចលនវត្ថុឱ្យនៅល្អ និងអាចប្រើប្រាស់បាន លើកលែងតែ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមានចែងផ្សេង។[46]

- **កាតព្វកិច្ចប្រគល់វត្ថុ**

ភតិកៈ ត្រូវប្រគល់វត្ថុទៅឱ្យភតិបតីវិញដោយរក្សានូវលក្ខណៈដើម លើកលែងតែ ការសឹករេចរឹលធម្មតានៅពេលផុតរយៈពេល ឬពេលរំលាយកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ប្រសិនបើ ខ្លួនមិនបានទិញ ឬ មិនបានជួលបន្តទេ។[47] ភតិកៈត្រូវទទួលខុសត្រូវចំពោះការបាត់បង់ចលនវត្ថុដែលបានជួលចាប់ពីពេលទទួលរហូតដល់ពេលប្រគល់ចលវត្ថុទៅភតិបតីវិញ។[48]

---

[46] មាត្រា២៦ នៃច្បាប់ស្ដីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

[47] មាត្រា២៧ នៃច្បាប់ស្ដីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

[48] មាត្រា២៨ នៃច្បាប់ស្ដីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

➢ **កាតព្វកិច្ចទទួលខុសត្រូវចំពោះភតិបតី**

ក្រៅពីកាតព្វកិច្ចដូចដែលបានរៀបរាប់ខាងលើ ភតិកៈត្រូវទទួលខុសត្រូវក្នុងករណីមួយចំនួនទៀតចំពោះភតិបតីផងដែរ។ ភតិកៈមិនត្រូវដាក់ហ៊ីប៉ូតែក បញ្ចាំ ឃាត់ទុក ចលនវត្ថុដែលបានជួល ឬបង្កើតឱ្យមានបន្ទុកផ្សេងទៀតលើចលនវត្ថុដែលបានជួលឡើយ។[49] ព្រោះ ភតិកៈមិនមែនជាកម្មសិទ្ធិករលើចលនវត្ថុនោះទេ ហេតុនេះ គេគ្មានសិទ្ធិចាត់ចែងណាមួយលើវត្ថុនោះឡើយ។ មិនតែប៉ុណ្ណោះ ភតិកៈក៏ត្រូវមានកាតព្វកិច្ចផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរទៅភតិបតីអំពីទីតាំងបច្ចុប្បន្ន និងការផ្លាស់ប្តូរទីតាំងថ្មីនៃចលនវត្ថុដែលបានជួល លើកលែងតែ កិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុមានចែងផ្សេងពីនេះ។[50] កាតព្វកិច្ចចុងក្រោយគឺ ភតិកៈមិនត្រូវជួលបន្តចាត់ចែង ផ្ទេរសិទ្ធិកាន់កាប់ ឬប្រើប្រាស់ចលនវត្ថុដែលបានជួល ឬសិទ្ធិណាមួយផ្សេងទៀតក្រោមភតិសន្យាហិរញ្ញវត្ថុ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីភតិបតីនោះទេ និងមិនត្រូវចំណុះសិទ្ធិរបស់តតិយជនឡើយ។ ការជួលបន្ត ការចាត់ចែង ឬការផ្ទេរ របស់ភតិកៈដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីភតិបតីត្រូវចាត់ទុកជាមោឃៈ និងត្រូវចាត់ទុកថាល្មើសច្បាប់នេះ និងច្បាប់ផ្សេងទៀត។ [51]

ក្រោយពីបានយល់ដឹងអំពី សិទ្ធិ និងកាតព្វកិច្ចរបស់គូភាគីនៃភតិសន្យាហិរញ្ញវត្ថុរួចហើយ ផ្នែកបន្ទាប់យើងនឹងត្រូវសិក្សាអំពីការបំពាន (ចំណុច២.២.១) និង ការសង្គ្រោះរបស់ភាគីនីមួយៗ (ចំណុច២.២.២) ក្នុងការការពារផលប្រយោជន៍របស់ខ្លួនផងដែរ។

## ២.២ ការបំពាន និងការសង្គ្រោះកិច្ចសន្យា

### ២.២.១ ការបំពានកិច្ចសន្យា

ការមិនអនុវត្តកាតព្វកិច្ច សំដៅលើករណីយកិច្ចដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដែលកើតឡើងពីកិច្ចសន្យា។ ទម្រង់នៃការមិនអនុវត្តកាតព្វកិច្ច មានដូចជា ៖

ក. កូនបំណុលមិនអាចអនុវត្តកាតព្វកិច្ចឱ្យទាន់ពេលវេលាតាមការកំណត់ ត្រូវអនុវត្តដោយសារការយឺតយ៉ាវក្នុងការអនុវត្ត

ខ. អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច

គ. កូនបំណុលមិនបានអនុវត្តឱ្យបានពេញលេញ តាមខ្លឹមសារនៃកាតព្វកិច្ច

ឃ. ករណីផ្សេងទៀតដែលគ្មានការអនុវត្តតាមខ្លឹមសារកាតព្វកិច្ច។[52]

---

[49] មាត្រា២៩ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

[50] មាត្រា៣០ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

[51] មាត្រា៣២ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

[52] មាត្រា៣៨៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

**២.២.១.១ ការចំពានរបស់ភតិក:**

ក្នុងទំនាក់ទំនងនៃភតិសន្យាហិរញ្ញវត្ថុ ភតិកៈជាកូនបំណុលដែលមានកាតព្វកិច្ចច្រើនត្រូវគោរព ហេតុនេះ ហានិភ័យដែលកើតចេញពីកូនបំណុលក៏មានច្រើនជាងម្ចាស់បំណុលផងដែរ។ ចំណុចនេះនឹងបង្ហាញអំពីហានិភ័យដែលបង្កឡើងដោយភតិកៈ និង ហានិភ័យផ្សេងៗដែលអាចកើតឡើងចំពោះភតិបតី។

ហានិភ័យមានន័យច្រើននៅក្នុងធុរកិច្ច និងជីវិតរស់នៅប្រចាំថ្ងៃ ហើយអាចកើតឡើងបានគ្រប់ពេលគ្រប់កាលទេសៈ មិនថាការវិនិយោគតិច ឬច្រើន។ ហានិភ័យ គឺជាការជះឥទ្ធិពលអវិជ្ជមាន ដោយកត្តាផ្សេងៗដែលធ្វើឱ្យមានលក្ខណៈខុសគ្នារវាងលទ្ធផលជាក់ស្តែង និងការរំពឹងទុក រួមមាន ហានិភ័យសន្ទនីយ និង កាលវសាន្ត[53] ហានិភ័យឥទាន ហានិភ័យប្រតិបត្តិការ ហានិភ័យទីផ្សារ ហានិភ័យទ្រព្យសកម្ម ហានិភ័យឯកសារ ហានិភ័យប្រមូលផ្តុំ និងហានិភ័យផ្សេងៗដែលអាចកើតឡើង ចំពោះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ នៅពេលធ្វើប្រតិបត្តិការភតិសន្យាហិរញ្ញវត្ថុ តាមផែនការអាជីវកម្ម។

- **ហានិភ័យឥណទាន**

ហានិភ័យនេះកើតឡើង ដោយសារតែ ការខកខានមិនបានគោរពកិច្ចសន្យាមួយផ្នែក ឬទាំងមូល ដោយសាមីភាគីណាមួយ ឬសមភាគីច្រើនរួមគ្នា ជាអត្តគាហគ។ ជាចំណុចយ៉ាងក្តៅ សម្រាប់អ្នកគ្រប់គ្រងភតិសន្យាហិរញ្ញវត្ថុ ដែលត្រូវគិត វិភាគ អោយបានច្បាស់លាស់ លើគុណភាពឥណទាន មុននឹងសម្រេចចិត្តផ្តល់សេវាភតិសន្យាហិរញ្ញវត្ថុ ដើម្បីធានាគុណភាពភតិសន្យាហិរញ្ញវត្ថុ។

- **ហានិភ័យទីផ្សារ**

ហានិភ័យទីផ្សារ ជាហានិភ័យនៃការខកខានបង់ហិរញ្ញវត្ថុបណ្តាលមកពីបម្រែបម្រួលថ្លៃទ្រព្យសកម្មលើទីផ្សាររូបិយវត្ថុ ទីផ្សារទុន និងហិរញ្ញវត្ថុ។ ហានិភ័យទីផ្សារ រួមបញ្ចូលទាំងហានិភ័យអត្រាការប្រាក់ អត្រាប្តូរ ប្រាក់ ហានិភ័យដើមទុន និងហានិភ័យពាក់ព័ន្ធនឹងទំនិញ។

- **ហានិភ័យប្រតិបត្តិការ**

ហានិភ័យប្រតិបត្តិការ ជាហានិភ័យដែលកើតឡើងពីភាពមិនគ្រប់គ្រាន់ ឬកំហុសឆ្គងពីនីតិវិធីគ្រប់គ្រងផ្ទៃក្នុងបុគ្គល ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ឬកត្តាក្រៅផ្សេងទៀត។

[53] ប្រកាសស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ លេខ ធ៧-០១១-២៤២ ប្រ.ក .២៧ ធ្នូ ២០១១ ហានិភ័យសន្ទនីយ និងកាលវសាន្ត គឺ ការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម

- **ហានិភ័យគតិយុត្ត**

ហានិភ័យគតិយុត្ត ជាហានិភ័យមួយប្រភេទដែលនៅក្រោមហានិភ័យប្រតិបត្តិការ។ ហានិភ័យនេះ កើតឡើងពីវិវាទសមភាគី ណាមួយដែលបណ្តាលមកពីភាពមិនច្បាស់លាស់ ភាពមិនត្រឹមត្រូវ ភាពទន់ខ្សោយ ឬអ្វីផ្សេងទៀត ដែលអាចកើតឡើងចំពោះគ្រឹះស្ថាន ឬក្រុមហ៊ុន នៅពេលធ្វើប្រតិបត្តិការ។

- **ហានិភ័យសន្ទនីយភាព**

ហានិភ័យសន្ទនីយភាព គឺជាហានិភ័យក្នុងលក្ខខណ្ឌទីផ្សារមួយ ដែលគ្រឹះស្ថាន ឬក្រុមហ៊ុនពុំមានលទ្ធភាពបំពេញកាតព្វកិច្ចរបស់ខ្លួន ឬគ្មានលទ្ធភាពដោះស្រាយ ឬកាត់កងស្ថានភាពបំណុលមួយដែលជាលទ្ធផលគ្រឹះស្ថាន ឬក្រុមហ៊ុននោះ ត្រូវបានខកខានមិនគោរពកិច្ចសន្យាដោយអ្នកចូលរួមទីផ្សារដទៃទៀត។ ហានិភ័យសន្ទនីយភាព ឬសាច់ប្រាក់ងាយស្រួល ត្រូវគិតទាំងសាច់ប្រាក់ជារូបិយប័ណ្ណ និងរូបិយវត្ថុ និងទ្រព្យសកម្មទាំងចុះបញ្ជី ឬជួញដូរផ្សេងៗដែលគ្រឹះស្ថាន ឬក្រុមហ៊ុនកំពុងមានប្រតិបត្តិការ។

- **ហានិភ័យឯកសារ**

ហានិភ័យឯកសារ គឺជាហានិភ័យដែលកើតឡើងជាញឹកញាប់ចំពោះសកម្មភាពអាជីវកម្ម និងការរស់នៅប្រចាំថ្ងៃ។ ហានិភ័យនេះ កើតឡើងដោយសារតែភាពមិនស្របច្បាប់នៃឯកសារ ភាពមិនពេញលេញនៃការបំពេញពត៌មាន ដែលនាំឱ្យឯកសារមួយមិនមានសុពលភាពចំពោះមុខច្បាប់។

- **ហានិភ័យចំពោះវត្ថុជួល**

ក្រៅពីហានិភ័យទាំងអស់ដែលបានរៀបរាប់ខាងលើ បញ្ហាដែលអាចកើតមានឡើងចំពោះវត្ថុជួល គឺជារឿងមួយដែលសំខាន់ផងដែរ ព្រោះថាការកាន់កាប់របស់ភតិកៈអាចបង្កឱ្យមានការខូចខាតដោយប្រការណាមួយ ឬមានការចាត់ចែងវត្ថុនោះដោយមិនត្រឹមត្រូវ បើទោះបីជា ច្បាប់បានបញ្ញត្តិអំពីបញ្ហាទាំងនេះក៏ដោយ។ ជាក់ស្តែង ដូចជា ការប្រើប្រាស់វត្ថុជួលដែលជួបគ្រោះថ្នាក់ណាមួយធ្វើឱ្យមានការខូចខាតកើតឡើង ឬការយកឧបករណ៍ទៅជួលបន្តដោយមិនបានជូនដំណឹង និងគ្មានការយល់ព្រមពីភតិបតីជាដើម ទាំងនេះហើយសុទ្ធតែជាកត្តាដែលអាចកើតឡើងខ្ពស់ពីការកាន់កាប់ឧបករណ៍ជាក់ស្តែងរបស់ភតិកៈ។

**២.២.១.២ ការបំពានរបស់ភតិបតី**

ជាទូទៅ ភតិបតី គឺជាក្រុមពាណិជ្ជករ គោលដៅរបស់គេគឺរកប្រាក់ចំណេញ ហេតុនេះ គេមិនសូវជាចង់ឱ្យមានវិវាទកើតឡើងនោះទេ ប៉ុន្តែការរំពឹងទុកនិងស្ថានភាពជាក់ស្តែងគឺមិនដូចគ្នាឡើយ ព្រោះពេលខ្លះក្នុងស្ថានភាពមួយ កូនបំណុលមិនបានបង់ប្រាក់មកឱ្យខ្លួនទេ ហើយម្ចាស់បំណុលតែងតែរិះរកវិធីណាផ្សេងដើម្បីសង្គ្រោះការខាតបង់របស់ខ្លួន ហើយការអនុវត្តវិធីទាំងអស់នោះ ជាធម្មតា តែងមានវិធីសមរម្យតាមរយៈការចរចារសម្របសម្រួល។ ករណីខ្លះទៀត គឺត្រូវតែមានការប្រើប្រាស់កម្លាំងបង្ខំទើបអាចសង្គ្រោះកិច្ចសន្យាបាន។ មិនមានន័យ

ថា គ្រប់ពេលដែលអនុវត្តសិទ្ធិរបស់ខ្លួន ភតិបតីសុទ្ធតែត្រឹមត្រូវទាំងអស់ឡើយ ករណីដែលមានភស្តុតាងបញ្ជាក់ ភតិបតីបានអនុវត្តសិទ្ធិដោយបំពាន ភតិបតីត្រូវទទួលខុសត្រូវការខូចខាតដែលកើតឡើងចំពោះភតិកៈផងដែរ។

ដោយមើលឃើញពីស្ថានភាពនេះ ច្បាប់ក៏បានព្យាករទុកជាមុនចំពោះករណីនេះរួចហើយដែរ។ នៅពេលភតិបតីរំខានដល់ការសិទ្ធិប្រើប្រាស់វត្ថុរបស់ភតិកៈ ឬដកហូតវត្ថុនោះដោយមិនត្រឹមត្រូវ និងគ្មានភស្តុតាងបញ្ជាក់ច្បាស់លាស់ទេ ភតិបតីក៏ត្រូវទទួលខុសត្រូវចំពោះភតិកៈផងដែរ។[54]

**២.២.២ ការសង្គ្រោះកិច្ចសន្យា**

ការសង្គ្រោះកិច្ចសន្យា គឺជាការអនុវត្តសិទ្ធិរបស់គូភាគី ដើម្បីការពារផលប្រយោជន៍របស់ខ្លួនដែលទទួលរងការខូចខាតដោយការបំពានមិនត្រឹមត្រូវ។ ជាធម្មតា មុននឹងឈានដល់ការអនុវត្តសិទ្ធិតាមផ្លូវច្បាប់ ភាគីតែងមានការអនុគ្រោះព្រមទាំងចរចារគ្នា ក្នុងការរកដំណោះស្រាយដោយសន្តិវិធី មុននឹងឈានដល់ការអនុវត្តសិទ្ធិតាមផ្លូវតុលាការ។ ក្នុងវិស័យជំនួញវិញ ការជួញមិត្តប្រសើរជាងជួញសត្រូវ ដូច្នេះ នៅពេលមានបញ្ហាកើតឡើង ទោះបីជាបានដឹងថាខ្លួនមានសិទ្ធិដែលច្បាប់ផ្តល់ឱ្យ ជាទូទៅ ភតិបតីមិនបានជ្រើសរើសការអនុវត្តសិទ្ធិរបស់ខ្លួនភ្លាមៗដែរ។ តាមធម្មតា ភតិបតីតែងរិះរកវិធីយ៉ាងណាដើម្បីដោះស្រាយរាល់បញ្ហាដែលកើតមានឡើងដោយសន្តិវិធីជាមុនជាជាងការអនុវត្តសិទ្ធិ និងរហូតឈានដល់ផ្លូវតុលាការ។ ហើយក្នុងចំណុចខាងក្រោម យើងនឹងបង្ហាញអំពីការសង្គ្រោះ និងដោះស្រាយបញ្ហាតាមការសម្របសម្រួល ព្រមទាំង ការដោះស្រាយ ការអនុវត្តសិទ្ធិតាមផ្លូវច្បាប់របស់ភាគីដែលរងការខូចខាត។

**២.២.២.១ ការដោះស្រាយភតិសន្យាហិរញ្ញវត្ថុដែលមានបញ្ហាដោយភតិបតី**

កាលណាមានភតិសន្យាហិរញ្ញវត្ថុមានបញ្ហាច្រើន នឹងធ្វើឱ្យសាខា ឬ គ្រឹះស្ថានទាំងមូលប្រឈមនឹងការខាតបង់ ក្ស័យធន ព្រមទាំងអស្ថិរភាពនៃប្រព័ន្ធប្រតិបត្តិភតិសន្យាហិរញ្ញវត្ថុ។ ការដោះស្រាយភតិសន្យាហិរញ្ញវត្ថុដែលមានបញ្ហា គឺជាការទទួលខុសត្រូវរបស់បុគ្គលិកនៅក្នុងសាខានីមួយៗ ដែលត្រូវបំពេញយ៉ាងយកចិត្តទុកដាក់ ដើម្បីស្តារភតិសន្យាហិរញ្ញវត្ថុដែលមានបញ្ហាឱ្យសងត្រលប់មកវិញ។

សមាសភាពសំខាន់ៗ ដែលត្រូវចូលរួមក្នុងការដោះស្រាយភតិសន្យាហិរញ្ញវត្ថុដែលមានបញ្ហា រួមមាន ៖ មន្ត្រីឥណទាន ប្រធានមន្ត្រីឥណទាន ប្រធានសាខា និងមន្ត្រីស្តារបំណុល។

ភតិបតីមិនចង់អនុវត្តសិទ្ធិដោយលក្ខខណ្ឌតឹងរឹង ចំពោះអតិថិជនរបស់ខ្លួនពេកនោះទេ ហើយការដោះស្រាយបញ្ហា មានគោលបំណងដើម្បីជម្រុញឱ្យមានដំណោះស្រាយជាមួយអតិថិជនដែលមានបញ្ហាដូចជា ៖

- ដើម្បីស្តារភតិសន្យាហិរញ្ញវត្ថុ ដែលមានបញ្ហាឱ្យសងប្រាក់ទាន់ពេលវេលាវិញ
- ដើម្បីពង្រឹងការសងប្រាក់ត្រលប់របស់អតិថិជន

[54] មាត្រា១៧ ចំណុចឃ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

- ដើម្បីទប់ស្កាត់ នូវភតិសន្យាហិរញ្ញវត្ថុដែលបាត់បង់
- ដើម្បីបង្កើតនូវនិរន្តភាព នៃប្រាក់ចំណេញ
- ដើម្បីទទួលបានលទ្ធផលការងារល្អក្នុងសាខាទាំងមូល

**ក. នីតិវិធីនៃការដោះស្រាយបញ្ហាអតិថិជនមានបញ្ហាជំណាក់កាលដំបូង**

| ល.រ | រយៈពេលយឺត | សមាសភាពដែលត្រូវទទួលខុសត្រូវ | ការងារចម្បងផ្សេងៗ |
|---|---|---|---|
| ១. | ២ ដល់៩ថ្ងៃ | មន្រ្តីឥណទាន និង ប្រធានមន្រ្តីឥណទាន | ចុះជួបផ្ទាល់ ឬទាក់ទងតាមទូរស័ព្ទះ<br>១.ចុះពិភាក្សាពីបញ្ហាដែលនាំឱ្យមានការយឺតយ៉ាវ<br>២.រំលឹកពីផលវិបាកនៃការសងប្រាក់យឺតរបស់អតិថិជន<br>៣.ធ្វើកិច្ចព្រមព្រៀងផ្ទាល់មាត់<br>៤.ផ្តល់ពត៌មានទៅប្រធានមន្រ្តីឥណទានដោយផ្ទាល់មាត់ពីបញ្ហាដែលអតិថិជនយឺត<br>៥.ត្រូវធ្វើរបាយការណ៍ជូនទៅប្រធានសាខាជាប្រចាំ នូវរាល់ការដោះស្រាយបញ្ហាអតិថិជនមានការយឺតយ៉ាវ |
| ២. | ១០ ដល់ ២៩ថ្ងៃ | ក្រុមដោះស្រាយបញ្ហាកម្រិតសាខា | ចុះជួបអតិជនដល់ផ្ទះ និងកំណត់រយៈពេលសងសម្រាប់ការបង់ប្រាក់(លើកទី២)។<br>ប្រធានសាខាត្រូវចុះវាយតម្លៃ និងប្រមូលពត៌មានដោយផ្ទាល់ពីអតិថិជនដែលមានបញ្ហា។<br>១. ចុះពិភាក្សាអំពីបញ្ហាម្តងទៀត។<br>២.ចុះទៅជួបអតិថិជននៅកន្លែងធ្វើអាជីវកម្ម ការងារ ឬនៅផ្ទះរបស់អតិថិជន។<br>៣.ជូនលិខិតជូនដំណឹងអំពីការសងយឺត និងកំណត់រយៈពេលសងចុងក្រោយ។<br>៤.ប្រាប់អតិថិជនអំពីការចាត់វិធានការពិន័យធ្ងន់ធ្ងរជាងមុន។<br>៥.អាចពិចារណាក្នុងការធ្វើសម្រួលការសង ក្នុងករណីដែលអតិថិជនមានប្រាក់សងមិនគ្រប់ចំនួន (ប្រធាន |

| | | | |
|---|---|---|---|
| | | | សាខា/ ប្រធានមន្ត្រីឥណទាន ដែលជាក្រុមដោះស្រាយបំណុលមានសិទ្ធិអនុម័តទៅលើការសម្របសម្រួល។<br>៦.ធ្វើកិច្ចព្រមព្រៀងកំណត់សងក្នុង រយៈពេល០៣ថ្ងៃ។<br>៧.ត្រូវធ្វើរបាយការណ៍ រាយការណ៍ទៅប្រធានសាខា ជាប្រចាំនៅរាល់ពេលចុះដោះស្រាយ។ |
| ៣ | ៣០ ដល់ ៦០ថ្ងៃ | ក្រុមដោះស្រាយបញ្ហាកម្រិតសាខា | ដំណាក់កាលនេះ ត្រូវមានការចូលរួមពីប្រធានសាខា ឬអនុប្រធានសាខាក្នុងការចុះវាយតម្លៃ និងប្រមូលពត៌មានដោយផ្ទាល់ពីបញ្ហាទាំងអស់នៅតាមសាខាដែលមានបញ្ហា៖<br>១.ធ្វើរបាយការណ៍ជាលាយលក្ខអក្សរ ជូនប្រធានផ្នែកឥណទានពីស្ថានភាពអតិថិជនដើម្បីរកវិធីសាស្ត្រស្តារបំណុលឡើងវិញ។<br>២.រៀបចំលិខិតអញ្ជើញដើម្បីកោះអញ្ជើញអតិថិជន និងអ្នកធានាអោយចូលខ្លួនដោះស្រាយនៅសាខា ឬអនុសាខា។<br>៣.ពន្យល់ និងពិភាក្សាអំពីច្បាប់ដែលទាក់ទងនឹងកិច្ចសន្យា ឬកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ ឬការខាតបង់ផ្សេងៗនៅពេលធ្វើបណ្តឹងទៅតុលាការ។<br>៤.កំណត់លក្ខខណ្ឌសងចុងក្រោយ ដើម្បីតាមដានអំពីប្រសិទ្ធិភាពសង។<br>៥.ប្រធានមន្ត្រីឥណទាន ត្រូវដាក់ពាក្យបណ្តឹងទប់ស្កាត់ភូមិ ឃុំ និងបុស្តិ៍ប៉ូលីស។ |
| ៤. | ៦១ ដល់ ១២០ថ្ងៃ | មន្ត្រីស្តាបំណុល និងក្រុមដោះស្រាយបំណុលកម្រិតសាខា | ដំណាក់កាលនេះ ត្រូវមានការចូលរួមពីប្រធានផ្នែកភតិសន្យាហិរញ្ញវត្ថុ ក្នុងការចុះវាយតម្លៃ និងប្រមូលពត៌មានដោយផ្ទាល់ ពីបញ្ហាទាំងអស់ទៅតាមសាខាដែលមាន៖<br>១.បន្តធ្វើរបាយការណ៍សង្ខេបជាលាយលក្ខអក្សរ ជូនមន្ត្រីប្រធានផ្នែកភតិសន្យាហិរញ្ញវត្ថុ អំពីស្ថានភាពសងយឺតយ៉ាវ ដើម្បីរកវិធិដោះស្រាយ។ |

| | | | |
|---|---|---|---|
| | | | ២.ផ្តល់មតិយោបល់អំពីលទ្ធភាព និងឆន្ទៈសងរបស់អតិថិជន និងអ្នកធានា ត្រូវទៅជួបអតិថិជន ដើម្បីធ្វើការសម្របសម្រួលក្នុងការលក់ទ្រព្យធានារបស់អតិថិជន ឬអ្នកធានាដោយមានជំនួយពីអនុប្រធានសាខា ឬប្រធានផ្នែកភតិសន្យាហិរញ្ញវត្ថុ។ |
| ៥ | ១២១ ថ្ងៃឡើងទៅ | មន្ត្រីស្តារបំណុល និងក្រុមដោះស្រាយបំណុលកម្រិតសាខា | ១.ទ្រព្យដែលអតិថិជនប្រគល់អោយទៅមន្ត្រីភតិសន្យាហិរញ្ញវត្ថុ ត្រូវរក្សាទុកនៅទីកន្លែងមានសុវត្ថិភាព។<br>២.ត្រូវទាក់ទងទៅអតិថិជនបង់យឺត និងអ្នកធានាដើម្បីឱ្យពួកគាត់ពិចារណាក្នុងការសងត្រលប់មកវិញ នូវសមតុល្យដែលនៅសល់ ទាំងអស់មុនពេលដែលក្រុមហ៊ុនប្រកាសលក់ទ្រព្យទាំងនោះ។ |
| ៦ | អតិថិជនលុបបំណុល | មន្ត្រីស្តារបំណុល និងក្រុមដោះស្រាយបំណុលកម្រិតសាខា | ក.ដំណើរការនៃដោះស្រាយអតិថិជនដែលបានលុបបំណុល ៖<br>១. មន្ត្រីភតិសន្យាហិរញ្ញវត្ថុ និងមន្ត្រីស្តារបំណុល<br>• ធ្វើផែនការចុះដោះស្រាយជាមួយអតិថិជនឡើងវិញ។<br>• ចុះជួបអតិថិជននៅកន្លែងធ្វើអាជីវកម្ម ឬផ្ទះអតិថិជន។<br>• សម្របសម្រួលជាមួយអតិថិជនឱ្យធ្វើការបង់សងទៅតាមលទ្ធភាព។ |

**ខ. ការដោះស្រាយបញ្ហាដោយអនុវត្តសិទ្ធិទាមទារ**

ជាគោលការណ៍ គូភាគីនៃកិច្ចសន្យាត្រូវប្រើប្រាស់សិទ្ធិ និងអនុវត្តករណីយកិច្ច ធ្វើឡើងដោយសុចរិតផ្អែកតាមភាពស្មោះត្រង់។[55] កូនបំណុលមានតួនាទីក្នុងការគោរពកាតព្វកិច្ចរបស់ខ្លួនឱ្យបានល្អ រីឯម្ចាស់បំណុលមិនត្រូវប្រើប្រាស់សិទ្ធិរបស់ខ្លួនដោយបំពានឡើយ ហេតុនេះ ប្រសិនបើ កូនបំណុលមិនគោរពកាតព្វកិច្ចរបស់ខ្លួនឱ្យបានល្អដោយសុចរិត និងស្មោះត្រង់ ហើយបានបង្កឱ្យមានការបំពានដល់សិទ្ធិរបស់ម្ចាស់បំណុលដែលមានចែងក្នុងកិច្ចសន្យា ម្ចាស់បំណុលអាចអនុវត្តសិទ្ធិទាមទាររបស់ខ្លួនបានដូចដែលមានចែងក្នុងចំណុចដែលបង្ហាញអំពី

[55] មាត្រា៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នស/ រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

សិទ្ធិរបស់ភតិបតី ខាងលើនេះឯង។ ដើរមកដល់ចំណុចនេះ មានន័យថា ការសម្របសម្រួលរវាងគូភាគីមិនមានប្រសិទ្ធិភាពឡើយ ពោលគឺ ជាដំណាក់កាលដែលភតិកៈនៅតែមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដូចដែលមានចែងក្នុងកិច្ចសន្យារវាងភាគី។

ប្រសិនបើនៅតែបន្តស្ថានភាពបែបនេះនឹងធ្វើឱ្យភតិបតីខាតបង់ផលប្រយោជន៍កាន់តែច្រើនឡើង ដូច្នេះ ភតិបតីមានសិទ្ធិពិចារណាក្នុងការទាមទារឱ្យកូនបំណុលបង់ថ្លៃឈ្នួលនោះបន្ត រួមទាំងការខូចខាត ឬពន្លឿនការបង់ថ្លៃឈ្នួល ហើយជាចុងក្រោយបំផុតគឺ ភតិបតីអាចឈានដល់ការរំលាយកិច្ចសន្យាភតិសន្យាហិរញ្ញវត្ថុ និងទាមទារឱ្យភតិកៈប្រគល់វត្ថុនោះត្រលប់មកវិញ ប្រសិនបើភតិកៈមិនបានបង់ថ្លៃឈ្នួលរយៈពេល ២(ពីរ)គ្រារ ជាប់គ្នា ឬមិនបានដោះស្រាយបញ្ហាក្នុងរយៈពេល ១០(ដប់)ថ្ងៃ បន្ទាប់ពីបានទទួលសេចក្ដីជូនដំណឹងជាលាយលក្ខអក្សរពីភតិបតី។ ករណី កូនបំណុលមិនយល់ព្រមតាមការទាមទារឱ្យប្រគល់វត្ថុត្រលប់ដោយភតិបតីទេ ភតិបតីអាចទាមទារទៅតុលាការសុំចេញដីកាសម្រេចឱ្យភតិកៈប្រគល់ចលនវត្ថុជួលនោះមកវិញ ដោយភ្ជាប់នូវរាល់ឯកសារភស្តុតាងដែលបង្ហាញថាភតិកៈមិនបានគោរពតាមកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុ។[56]

**១.២.២.២ ការសង្គ្រោះរបស់ភតិកៈ**

ក្នុងករណីដែលភតិកៈបានទទួលរងនូវការបំពានណាមួយ ភតិកៈក៏មានសិទ្ធិក្នុងការសង្គ្រោះកិច្ចសន្យារបស់ខ្លួនដែលរងនូវការបំពានផងដែរ។ ដូចដែលយើងបានសិក្សាពីចំណុចខាងលើរួចហើយ ការខូចខាតដែលភតិកៈអាចត្រូវបានទទួលរងពីភតិបតី មិនសូវជាកើតមានឡើងច្រើនទេ ដែលនាំឱ្យសិទ្ធិសង្គ្រោះលើការបំពានរបស់ភតិកៈក៏មិនសូវជាមានច្រើនប៉ុន្មានដែរ។ ប្រសិនបើភតិកៈបានទទួលរងនូវការបំពានណាមួយពីភតិបតី ដូចនឹងលក្ខខណ្ឌខាងលើ ភតិកៈអាចទាមទារឱ្យភតិបតីសងនូវសំណងនៃការខូចខាតដែលកើតឡើងដោយអំពើរបស់ភតិបតី និងទាមទារឱ្យភតិបតី ឬអ្នកផ្គត់ផ្គង់ជុសជុលវិការៈមុនពេលដែលខ្លួនទទួលវត្ថុ ក្នុងករណីដែលរកឃើញថា កម្មវត្ថុនៃភតិសន្យាហិរញ្ញវត្ថុមានវិការៈ ហើយបើមិនមានដំណោះស្រាយក្នុងការជួសជុលវិការៈទេ ភតិកៈអាចរំលាយកិច្ចព្រមព្រៀងភតិសន្យាហិរញ្ញវត្ថុជាមួយភតិបតីតែម្ដង ប៉ុន្តែមិនមែនរំលាយកិច្ចព្រមព្រៀងផ្គត់ផ្គង់នោះទេ។[57]

---

[56] មាត្រា១៧ ចំណុចយ នៃច្បាប់ស្ដីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

[57] មាត្រា២៣ នៃច្បាប់ស្ដីពីភតិសន្យាហិរញ្ញវត្ថុ លេខ នស/រកម/០៦០៩/០០៨, ២០ មិថុនា ២០០៩

# ជំពូកទី៣

## ការលក់ទិញដោយបង់រំលស់តាមរយៈប្រតិបត្តិការដែលមានកិច្ចធានា

ប្រតិបត្តិការដែលមានកិច្ចធានា គឺជាប្រតិបត្តិការមួយដែលជួយសម្រួលដល់ការប្រើប្រាស់ចលនទ្រព្យដើម្បីធានាកាតព្វកិច្ច។ ប្រតិបត្តិការនេះបង្កើតឡើងក្នុងគោលដៅ អភិវឌ្ឍសកម្មភាពហិរញ្ញវត្ថុ និងពាណិជ្ជកម្ម ដោយផ្តល់នូវវិធានមានលក្ខណៈងាយស្រួលដល់ការអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីម្ចាស់បំណុល និងកូនបំណុល។ ក្រៅពីនេះ ប្រតិបត្តិការដែលមានកិច្ចធានា ក៏ជាចំណែកក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រតាមរយៈការប្រើប្រាស់ចលនវត្ថុដើម្បីដាក់ធានាបំណុល។ ដូចនេះ ការយល់ដឹងអំពីការប្រើប្រាស់ និងការអនុវត្តសិទ្ធិឱ្យមានប្រសិទ្ធិភាព ជាចំណេះដឹងដែលមិនអាចខ្វះបានសម្រាប់កូនបំណុល និងម្ចាស់បំណុលដើម្បីទទួលបាននូវដំណោះស្រាយក៏ដូចជា វិធីសាស្ត្រក្នុងការសង្គ្រោះដ៏ល្អប្រសើរ ដែលមានលក្ខណៈសមស្របទៅនឹងគោលបំណងនៃការធានាកាតព្វកិច្ច ជាពិសេសគឺស្ថានភាពជាក់ស្តែងក្នុងការអនុវត្ត។

អ្នកនីតិនិពន្ធបានប្រើប្រាស់យុទ្ធសាស្ត្រចំនួនបួន ដើម្បីធានាឱ្យបានថា ការធ្វើប្រតិបត្តិការតាមរយៈច្បាប់ស្តីប្រតិបត្តិការដែលមានកិច្ចធានា ពិតជាបានបម្រើផលប្រយោជន៍យ៉ាងប្រាកដដល់វិស័យពាណិជ្ជកម្ម និងតម្រូវការរបស់ពាណិជ្ជករ ព្រមទាំង ពង្រីកលទ្ធភាពនៃការប្រើប្រាស់ឥណទានអាជីវកម្មយ៉ាងពិតប្រាកដមែន។ យុទ្ធសាស្ត្រចំនួនបួនដែលបានរៀបរាប់ខាងលើរួមមាន៖ ការប្រើប្រាស់វិធានសាមញ្ញជាជាងច្បាប់សារធាតុ (ក្រមរដ្ឋប្បវេណី) ការបញ្ជាក់ច្បាស់លាស់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនៃកិច្ចសន្យារួមផ្សំជាមួយ ការផ្តល់ជូនបច្ចេកទេសថ្មីស្តីពីការតម្កល់ និងការបង្កើនប្រសិទ្ធិភាពក្នុងវិស័យប្រាតិភោគ។[58]

ដោយឡែក ប្រតិបត្តិការនីមួយៗមានសញ្ញាណគតិយុត្តមិនដូចគ្នាទេ ចំណែកឯប្រតិបត្តិការដែលមានកិច្ចធានាក៏មិនខុសអ្វីពីប្រតិបត្តិការដទៃទៀតដែរ។ ដូច្នេះ ការសិក្សាប្រតិបត្តិការដែលមានកិច្ចធានានៅជំពូកនេះ នឹងផ្តោតសំខាន់ទៅលើ ការបង្កើតប្រតិបត្តិការដែលមានកិច្ចធានា(៣.១) អនុភាពនៃប្រតិបត្តិការដែលមានកិច្ចធានា(៣.២) ព្រមទាំងការបកស្រាយអំពីការអនុវត្តសិទ្ធិរបស់គូភាគី(៣.៣) និងកត្តានានាដែលនាំឱ្យមានការរំលត់សិទ្ធិតាមរយៈប្រតិបត្តិការដែលមានកិច្ចធានាខាងលើ(៣.៤)។

ច្បាប់នេះជាច្បាប់ពិសេស ប៉ុន្តែលក្ខខណ្ឌនៃការបង្កើតប្រតិបត្តិការនេះមិនត្រូវបានកំណត់ជាក់លាក់ទេ តម្រូវឱ្យលើកយកបទបញ្ញត្តិទូទៅដែលមានវត្តមាននៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មកបំពេញបន្ថែម និងដើម្បីអនុវត្តក្នុងការកំណត់អំពីលក្ខខណ្ឌនៃការបង្កើតប្រតិបត្តិការដែលមានកិច្ចធានា ជំនួសអ្វីដែលមិនបានចែងក្នុង

[58] ក្រសួងពាណិជ្ជកម្ម, ឯកសារបណ្តុះបណ្តាល ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ទំព័រ ១៥,១៦។

ច្បាប់ពិសេស ដោយស្របទៅតាមច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ ត្រង់ជំពូកទី៦ ស្តីពីការសម្រប សម្រួលរវាងក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។

## ៣.១ ការបង្កើតប្រតិបត្តិការដែលមានកិច្ចធានា

ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ជាច្បាប់ពិសេសដែលមានកំណើតនៅក្នុងប្រព័ន្ធច្បាប់ខមមិនឡ(Common Law) ឬនិយាយដោយចំពោះថា កើតចេញពីក្រមឯកភាពពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក។ [59] មានមូលហេតុជាច្រើន ដែលជំរុញឱ្យប្រទេសកម្ពុជាទទួលយកប្រតិបត្តិការខាងលើ ដូចជា ការចូលជាសមាជិកអង្គការអន្តរជាតិនានា ជាពិសេសអង្គការពាណិជ្ជកម្មពិភពលោក និងការរីកចម្រើនលើវិស័យហិរញ្ញវត្ថុជាដើម។

នៅក្នុងឆ្នាំ២០០០ ធនាគារអភិវឌ្ឍន៍អាស៊ី បានធ្វើប្រតិបត្តិការហិរញ្ញវត្ថុយ៉ាងទូលំទូលាយរបស់ខ្លួននៅប្រទេសកម្ពុជា។ ក្នុងការពិគ្រោះយោបល់យ៉ាងជិតស្និតជាមួយរដ្ឋាភិបាល និងដៃគូវិស័យឯកជនសំខាន់ៗធនាគារអភិវឌ្ឍន៍អាស៊ី បានធ្វើសេចក្តីព្រាងផែនការហិរញ្ញវត្ថុវិស័យឯកជនឆ្នាំ២០០១ ដល់២០១០ រហូតត្រូវបានអនុម័តដោយរដ្ឋាភិបាលនៅខែសីហា ឆ្នាំ២០០១ ជាគម្រោងដែលមានរយៈពេលវែងសម្រាប់អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ។ កត្តាចម្បងបំផុតក្នុងផែនការនេះ គឺសំដៅលើការកែលំអហេដ្ឋារចនាសម្ព័ន្ធច្បាប់ក្នុងវិស័យហិរញ្ញវត្ថុ ដោយសង្កត់ធ្ងន់លើការបង្កើតប្រព័ន្ធប្រតិបត្តិការដែលមានកិច្ចធានានៅក្នុងប្រទេសកម្ពុជា។[60] គំរូចម្បង សម្រាប់សេចក្តីព្រាងច្បាប់ស្តីពីការប្រតិបត្តិការដែលមានកិច្ចធានារបស់ប្រទេសកម្ពុជា ជាគោលការណ៍ណែនាំរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ស្តីពីការតម្កល់ចលនទ្រព្យ និងក្រមឯកភាពពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក។ លើសពីនេះ សេចក្តីព្រាងច្បាប់ខាងលើ បានកំណត់អំពីតម្រូវការអាជីវកម្ម អ្នកប្រើប្រាស់ និងជាសេចក្តីត្រូវការរបស់រដ្ឋាភិបាលដែលនឹងជំរុញដល់សកម្មភាពសេដ្ឋកិច្ចផងដែរ នោះគឺសេចក្តីព្រាងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។

ជាក់ស្តែង កម្ពុជានាពេលបច្ចុប្បន្នជាប្រទេសកំពុងអភិវឌ្ឍន៍ ជាហេតុបណ្តាលឱ្យអាជីវករមួយចំនួនខ្វះខាតដើមទុនដើម្បីពង្រីកអាជីវកម្ម ដែលយើងឃើញថា ការធ្វើប្រតិបត្តិការដោយដាក់សិទ្ធិប្រាតិភោគលើចលនទ្រព្យក៏កាន់តែទទួលបានប្រជាប្រិយភាព។ ករណីជាច្រើនដូចជា ការសន្យារបស់បុគ្គលដើម្បីសងបំណុលទៅឱ្យម្ចាស់បំណុលវិញនោះ នៅពុំទាន់គ្រប់គ្រាន់ដែលអាចឱ្យម្ចាស់បំណុលផ្តល់ប្រាក់កម្ចីឡើយ អាស្រ័យលើអនាគតកូនបំណុលត្រូវតែផ្តល់អ្វីមួយបន្ថែម ដើម្បីឱ្យម្ចាស់បំណុលមានជំនឿថា ថ្លៃចំណាយរបស់កូនបំណុលមានទំហំធំជាងបំណុលរបស់ខ្លួន។ ការធ្វើបែបនេះ ត្រូវបានឱ្យឈ្មោះថា ជាការភ្ជាប់សិទ្ធិប្រាតិភោគ។ "*ការភ្ជាប់សិទ្ធិប្រាតិភោគ*"ជាពាក្យបច្ចេកទេសមានន័យថា ការបង្កើតសិទ្ធិប្រាតិភោគ។ រីឯ "*សិទ្ធិប្រាតិភោគ*" គឺសិទ្ធិប្រត្យ័ក្សលើទ្រព្យ

---

[59] ធនាគារពិភពលោក, Secure Translations Systems and Collateral Registers(សហរដ្ឋអាមេរិក,២០១០),៦-១៣

[60] សៀវភៅពន្យល់ និងឧទាហរណ៍នៃប្រតិបត្តិការដែលមានកិច្ចធានា, ទំព័រ ១៣

ធានាដែលដាក់ការបំពេញកាតព្វកិច្ច[61] ឬជាកិច្ចសន្យារវាងគូភាគីដែលមានភាគីម្ខាង ជាកូនបំណុល បានប្រគល់ចលនទ្រព្យឱ្យទៅភាគីម្ខាងទៀត ជាម្ចាស់បំណុល ធ្វើជាទ្រព្យធានា ដើម្បីជាថ្នូរទៅនឹងការយល់ព្រមរបស់ម្ចាស់បំណុល ដើម្បីផ្តល់ប្រាក់កម្ចី ឬឥណទានហិរញ្ញវត្ថុ ក្នុងរូបភាពផ្សេងទៀតឱ្យទៅកូនបំណុល។ ប៉ុន្តែ បញ្ហាស្ថិតត្រង់ថា តើគ្រប់ចលនវត្ថុទាំងអស់នឹងអាចក្លាយជាកម្មវត្ថុនៃការធានាកាតព្វកិច្ចតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ឬមានការកម្រិតនូវវិសាលភាពនៃទ្រព្យធានា? ដូច្នេះ ដើម្បីស្រាយចម្ងល់ខាងលើ ជំហានបន្ទាប់យើងនឹងធ្វើការសិក្សាស៊ីជម្រៅអំពី លក្ខខណ្ឌនៃការបង្កើតកិច្ចព្រមព្រៀងប្រាតិភោគ(៣.១.១) និងកម្មវត្ថុនៃទ្រព្យធានា(៣.១.២)។

### ៣.១.១. លក្ខខណ្ឌនៃការបង្កើតកិច្ចព្រមព្រៀងប្រាតិភោគ

លក្ខខណ្ឌចម្បងនៃការបង្កើតកិច្ចព្រមព្រៀងប្រាតិភោគចាំបាច់ត្រូវធ្វើការភ្ជាប់សិទ្ធិប្រាតិភោគ ទើបម្ចាស់បំណុលអាចអនុវត្តសិទ្ធិបាន។ ការភ្ជាប់សិទ្ធិប្រាតិភោគខាងលើនេះ តម្រូវឱ្យមានលក្ខខណ្ឌចំនួន០៣សំខាន់ៗ ដូចជា៖ អត្ថិភាពកិច្ចព្រមព្រៀងប្រាតិភោគ និងកូនបំណុលទទួលបានតម្លៃតប ព្រមទាំងសិទ្ធិដែលកូនបំណុលមានលើទ្រព្យធានា។

#### ៣.១.១.១ អត្ថិភាពកិច្ចព្រមព្រៀងប្រាតិភោគ

កិច្ចព្រមព្រៀងប្រាតិភោគត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សររវាងគូភាគី ដែលកូនបំណុលផ្ទេរសិទ្ធិប្រាតិភោគលើទ្រព្យធានាទៅឱ្យម្ចាស់បំណុល។ កិច្ចព្រមព្រៀងប្រាតិភោគនេះ ត្រូវអធិប្បាយអំពីព័ត៌មានសំខាន់ៗនៃទ្រព្យធានា ដែលមិនអាចធ្វើឡើងដោយផ្ទាល់មាត់បានទេ ព្រោះពិបាកក្នុងការបង្ហាញភស្តុតាងពីសិទ្ធិប្រាតិភោគ និងជាហេតុចាំបាច់ សម្រាប់គូភាគីក្នុងការអនុវត្តសិទ្ធិប្រាតិភោគ ដើម្បីបំពេញលក្ខខណ្ឌសុពលភាព ដូចនេះ កិច្ចព្រមព្រៀងប្រាតិភោគត្រូវតែមានសុពលភាព ទើបសិទ្ធិប្រាតិភោគត្រូវបានភ្ជាប់ទៅនឹងទ្រព្យធានា។ លក្ខខណ្ឌកំណត់ថា ការបង្កើតកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរនេះហើយ ជាលក្ខខណ្ឌសុពលភាពនៃកិច្ចព្រមព្រៀងដាក់ប្រាតិភោគដែលច្បាប់តម្រូវ។ លើសពីនេះ ក្នុងកិច្ចព្រមព្រៀងប្រាតិភោគត្រូវមានធាតុផ្សំសំខាន់ៗចំនួន០៣៖

-**ធាតុផ្សំទីមួយ៖** កិច្ចព្រមព្រៀងត្រូវមានសុពលភាពតាមច្បាប់ ឬតាមស្មារតីនៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ដែលកំណត់អំពីលក្ខខណ្ឌអានុភាពនៃកិច្ចសន្យា គឺសំណើ និងស្ទីការត្រូវគ្នា និងលក្ខខណ្ឌបីទៀតដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ដូចជា កម្មវត្ថុស្របច្បាប់ ការព្រមព្រៀងរបស់ភាគីគ្មានវិការៈ និងសមត្ថភាពភាគី។

-**ធាតុផ្សំទីពីរ៖** ការបញ្ជាក់ឯកភាព ចំណុចនេះសំខាន់ដែលចាំបាច់មានក្នុងការភ្ជាប់សិទ្ធិប្រាតិភោគទៅលើកម្មវត្ថុ។ *"ការបញ្ជាក់ឯកភាព"* សំដៅទៅលើ ការបញ្ជាក់ដោយការចុះហត្ថលេខា ឬការបញ្ជាក់លើឈ្មោះ ឬ

[61] មាត្រា៤ កថាខណ្ឌទី១ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

និមិត្តសញ្ញាផ្សេងៗ ដែលធ្វើឡើងដោយផ្ទាល់ដៃរបស់កូនបំណុល មិនតម្រូវហត្ថលេខារបស់ម្ចាស់បំណុលទេ។ ច្បាប់ក៏ពុំបានតម្រូវឱ្យធ្វើកិច្ចព្រមព្រៀងនៅមន្ទីរសារការី ឬធ្វើឡើងនៅចំពោះមុខសាក្សីនោះដែរ។

-**ធាតុផ្សំទីបី៖** កិច្ចព្រមព្រៀងត្រូវមានការអធិប្បាយអំពីទ្រព្យធានា ប៉ុន្តែមិនចាំបាច់លម្អិតពេកទេ ធ្វើយ៉ាងណាកុំឱ្យមានការភ័ន្តច្រឡំទៅលើអត្តសញ្ញាណនៃទ្រព្យធានា និងទ្រព្យធានារបស់បុគ្គលដទៃទៀតបានហើយ ដោយគ្រាន់តែប្រើពាក្យថា ទ្រព្យសកម្មទាំងអស់ ឬចលនវត្ថុទាំងអស់គឺគ្រប់គ្រាន់ហើយ។[62]

ទោះបីជាមានបទបញ្ញត្តិបែបនេះក្តី មានករណីពីរដែលគួរកត់ចំណាំ *យានយន្តដែលមានលេខសេរី* ដូចជា ឡាន ម៉ូតូ កាណូតជាអាទិ៍ តម្រូវទាមទារឱ្យដាក់លេខសេរីភ្ជាប់ជាមួយ រីឯ*ទំនិញប្រើប្រាស់* ក៏ដូចគ្នាដែរ។

ដោយឡែក ការពិពណ៌នាមិនគួរប្រើពាក្យទំនិញប្រើប្រាស់ តែមួយមុខនោះទេ ព្រោះពិបាកក្នុងការវិនិច្ឆ័យនៅពេលអនុវត្ត ដូចនេះ ការពិពណ៌នាអំពីទំនិញប្រើប្រាស់ គឺត្រូវបញ្ជាក់ពីមុខទំនិញរបស់កូនបំណុលនីមួយៗឱ្យបានច្បាស់លាស់ ដែលនឹងសិក្សាលម្អិតនៅផ្នែកខាងក្រោម។

### ៣.១.១.២ កូនបំណុលទទួលបានតម្លៃតប

កិច្ចព្រមព្រៀងប្រាតិភោគនឹងមិនមានអានុភាពទេ បើប្រតិបត្តិការនោះមិនបានធ្វើឱ្យកូនបំណុលទទួលបានតម្លៃតបជាប្រាក់ ឬវត្ថុណាមួយ។ យោងតាមនិយមន័យក្នុងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា *"តម្លៃ"* មានន័យថា ជាថ្នូរនឹងការសន្យាក្នុងការផ្តល់ឥណទានហើយវាអាចជាទ្រព្យធានា ឬសិទ្ធិដែលទទួលពីការប្រគល់ដោយអនុលោមតាមកិច្ចសន្យាលក់ទិញ ឬក៏សិទ្ធិជាថ្នូរនឹងការសន្យាការដោះដូរ។[63] ដូច្នេះ យើងអាចសន្និដ្ឋានថា ការបង្កើតសិទ្ធិប្រាតិភោគអាចអនុវត្តបានទាល់តែម្ចាស់បំណុលដែលមានកិច្ចធានាផ្តល់នូវតម្លៃអ្វីមួយឱ្យទៅកូនបំណុល។ ការកំណត់បែបនេះគឺមិនមានអ្វីប្លែកទេ ព្រោះថាគោលបំណងនៃការបង្កើតប្រាតិភោគដើម្បីទទួលបាននូវតម្លៃតបអ្វីមួយក្នុងការប្រើប្រាស់មកបង្កើនផលប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិនៃទ្រព្យធានា ឬកូនបំណុល។

ផ្ទុយទៅវិញ បើសិនជាកិច្ចព្រមព្រៀងប្រាតិភោគបង្កើតឡើង មិនមែនជាការធានាតម្លៃអ្វីមួយដែលម្ចាស់បំណុលនឹងផ្តល់ឱ្យកូនបំណុលទេ ប្រតិបត្តិការនោះ មិនមែនជាប្រតិបត្តិការដែលមានកិច្ចធានាទេ ព្រោះគ្មានកិច្ចណាមួយដែលអាចឱ្យឈ្មោះថាជា កិច្ចធានាបានឡើយ។ ដូចជាកូនបំណុលបានយកគ្រឿងសង្ហារឹមក្នុងផ្ទះរបស់ខ្លួន ទៅដាក់ធានាកាតព្វកិច្ច ដើម្បីជាតម្លៃតបនឹងទឹកប្រាក់ចំនួន ១០០,០០០ដុល្លារអាមេរិក។ កិច្ចព្រមព្រៀងនេះមានសុពលភាព ដោយសារកូនបំណុលទទួលបានតម្លៃតបជាទឹកប្រាក់ចំនួន ១០០,០០០ដុល្លារអាមេរិក នៃការយកគ្រឿងសង្ហារឹមទៅដាក់ធានា។ ផ្ទុយមកវិញ បើកូនបំណុលយកគ្រឿងសង្ហារឹមទៅដាក់ប្រាតិភោគជូនម្ចាស់

[62] សៀវភៅពន្យល់ និងឧទាហរណ៍នៃប្រតិបត្តិការដែលមានកិច្ចធានា, ទំព័រ ៦៣។

[63] មាត្រា៣ កថាខណ្ឌទី១៤ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

បំណុល ដោយមិនមានតម្លៃតបអ្វីទេ កិច្ចព្រមព្រៀងនោះមិនត្រូវបានចាត់ទុកថា ជាការបង្កើតប្រតិបត្តិការដែលមានកិច្ចធានាឡើយ។

**៣.១.១.៣ សិទ្ធិដែលកូនបំណុលមានលើទ្រព្យធានា**

ដើម្បីឱ្យប្រតិបត្តិការមានសុពលភាព កូនបំណុលត្រូវមានសិទ្ធិលើទ្រព្យធានា ឬមានអំណាចផ្ទេរសិទ្ធិលើទ្រព្យធានានោះទៅកាន់ម្ចាស់បំណុល។ សិទ្ធិក្នុងន័យនេះ សំដៅទៅលើសិទ្ធិកម្មសិទ្ធិ ទោះជាមិនបានកំណត់នៅក្នុងច្បាប់ក៏ដោយ តែគោលគំនិតនៃការប្រើប្រាស់សិទ្ធិនេះ គឺដើម្បីចាត់ចែងទ្រព្យធានា ដែលមានតែកម្មសិទ្ធិករតែប៉ុណ្ណោះអាចធ្វើបាន។ មូលហេតុដែលតម្រូវកូនបំណុលត្រូវតែមានសិទ្ធិ ពីព្រោះប្រតិបត្តិការដែលមានកិច្ចធានាអាចអនុញ្ញាតឱ្យម្ចាស់សិទ្ធិកាន់កាប់ និងអនុវត្តសិទ្ធិរបស់ខ្លួនលើទ្រព្យធានាបាន ដូចនេះ សិទ្ធិរបស់កូនបំណុលមានសារៈសំខាន់ណាស់ក្នុងការចាត់ចែង។ ផ្ទុយមកវិញ បើកូនបំណុលមិនមានសិទ្ធិលើទ្រព្យធានា នោះម្ចាស់បំណុលនឹងជួបការលំបាក ទាមទារឱ្យម្ចាស់បំណុលស្វែងរកមូលដ្ឋានជាក់លាក់ពីអត្ថិភាពនៃសិទ្ធិកម្មសិទ្ធិរបស់កូនបំណុលលើវត្ថុធានាដោយផ្ទាល់។ វាអាចជាបន្ទុករបស់ម្ចាស់បំណុលក្នុងការស្វែងរកអំណះអំណាងពីកូនបំណុលដើម្បីបញ្ជាក់ថា កូនបំណុលមានសិទ្ធិអំណាចដើម្បីដាក់ទ្រព្យដែលខ្លួនមានទៅបញ្ចាំ ឬអត់។ ការទាមទារឱ្យមានសិទ្ធិលើទ្រព្យធានាជាកត្តាចម្បងដែលគួរពិចារណា តែប្រសិនបើកូនបំណុលមានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលតាមកិច្ចសន្យាជួល ផលុបភោគ ឬកិច្ចព្រមព្រៀងដទៃទៀត ការផ្តល់សិទ្ធិប្រាតិភោគមិនត្រូវបានហាមឃាត់នោះទេ។ នៅក្នុងច្បាប់ស្តីពីប្រតិបត្តិមានកិច្ចធានា "*ការមានសិទ្ធិលើទ្រព្យធានា*" មិនចាំបាច់ត្រូវតែជាសិទ្ធិដែលអាចផ្ទេរទ្រព្យធានាឡើយ ព្រោះក្នុងស្ថានភាពខ្លះ កូនបំណុលមិនមានសិទ្ធិលើទ្រព្យធានា តែមានសិទ្ធិប្រើប្រាស់ ឬកាន់កាប់ទ្រព្យធានាតាមរយៈកិច្ចសន្យាជួលជាអាទិ៍។

**៣.១.២ កម្មវត្ថុនៃទ្រព្យធានា**

ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា មានវិសាលភាពគ្របដណ្តប់ចំពោះតែចលនវត្ថុប៉ុណ្ណោះ ដោយមាត្រា២ និងមាត្រា៦ មិនបានកំណត់អំពីអចលនវត្ថុធ្វើជាទ្រព្យធានានោះទេ។ ដូច្នេះ ការសិក្សាពីប្រតិបត្តិការដែលមានកិច្ចធានានៅទីនេះ គឺមានតែប្រាតិភោគចលនវត្ថុ។

ជាទូទៅ ចលនវត្ថុមានច្រើនបែបច្រើនសណ្ឋានណាស់បញ្ហាដែលចោទឡើង តើគ្រប់ចលនវត្ថុនឹងអាចក្លាយជាកម្មវត្ថុនៃការធានាកាតព្វកិច្ចតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ឬត្រូវមានការកម្រិតអំពីទំហំនៃចលនវត្ថុដែលនឹងក្លាយជាទ្រព្យធានា? ចំណុចបន្ទាប់ យើងនឹងធ្វើការបែងចែកអំពីប្រភេទនៃកម្មវត្ថុ ដែលស្ថិតនៅក្រោមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និងប្រភេទនៃវត្ថុដែលត្រូវបានកម្រិតមិនអនុញ្ញាតឱ្យធ្វើជាកម្មវត្ថុនៃការធានា។

### ៣.១.២.១ កម្មវត្ថុជាទ្រព្យធានារូបិយ

ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា មានវិសាលភាពគ្របដណ្តប់សឹងតែលើចលនវត្ថុគ្រប់ប្រភេទ។ ដើម្បីសម្រួលដល់ការសិក្សា តទៅនឹងត្រូវបង្ហាញថា ចលនវត្ថុណាខ្លះដែលស្ថិតនៅក្រោមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។ ដោយយោងតាមមាត្រា៣ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា បានកំណត់យកប្រភេទទ្រព្យដូចខាងក្រោម៖

- **ទំនិញ**

ទំនិញ គឺជាវត្ថុ(ចលនវត្ថុ) នៅពេលដែលសិទ្ធិប្រាតិភោគត្រូវបានភ្ជាប់[64] លើកលែងតែ គណនី កិច្ចសន្យាលក់ដែលមានកិច្ចធានា រូបិយវត្ថុ ឯកសារ ឬលិខិតស្នាម ដែលមិនត្រូវបានចាត់ទុកជាទំនិញ។ បើទោះបីជា មានការកម្រិតនូវដែននៃទំនិញយ៉ាងនេះក្តី ប៉ុន្តែ វិសាលភាពនៃទំនិញនៅមានលក្ខណៈទូលំទូលាយ តម្រូវឱ្យមានការបែងចែកជាបន្តបន្ទាប់នូវប្រភេទនៃទំនិញ ដើម្បីបង្ហាញអំពីលក្ខណៈជាក់លាក់នៃទ្រព្យធានា។ ទំនិញ គឺត្រូវបានបែងចែកជាប្រាំប្រភេទផ្សេងទៀតដូចជា សារពើភណ្ឌ កសិករ ឧបករណ៍ ទំនិញប្រើប្រាស់ និងចលនវត្ថុតាំងភ្ជាប់ជាដើម។

- សារពើភណ្ឌ៖ គឺជាទំនិញដែលបុគ្គលកាន់កាប់សម្រាប់លក់ ជួល ឬ ជាវត្ថុធាតុដើម គម្រោងដែលកំពុងដំណើរ ឬ សម្ភារៈប្រើប្រាស់ក្នុងអាជីវកម្ម។[65] ដូចជា នៅក្នុងការប្រតិបត្តិជាក់ស្តែងឃើញថា ក្រុមហ៊ុនផលិតម៉ូតូមួយកន្លែង បានផលិតម៉ូតូសម្រាប់ធ្វើអាជីវកម្មដើម្បីចែកចាយបន្ត និងមានឃ្លាំងជាច្រើនកន្លែងសម្រាប់ទុកដាក់ម៉ូតូដែលបានផលិតរួចរាល់។ ដោយមើលឃើញអំពីការរីកចម្រើនខាងផ្នែកអាជីវកម្មរបស់ខ្លួន ក្រុមហ៊ុននេះមានបំណងចង់ពង្រីកអាជីវកម្ម ទើបបានទៅស្នើសុំប្រាក់កម្ចីពីធនាគារមួយ ដោយដាក់ម៉ូតូមានក្នុងឃ្លាំងរបស់ខ្លួនទាំងអស់ធ្វើជាទ្រព្យធានា។ ករណីខាងលើ ទ្រព្យធានាដែលជាម៉ូតូនៅក្នុងឃ្លាំងគឺជា សារពើភណ្ឌ ព្រោះម៉ូតូជាចលនវត្ថុដែលម្ចាស់ក្រុមហ៊ុន ឬកូនបំណុលនៃប្រតិបត្តិការធានាកាន់កាប់ក្នុងគោលបំណងទុកលក់។
- កសិផល៖ ទំនិញដែលកើតឡើងពីកសិកម្ម លើកលែងតែឈើឈរ។[66] ដូចជា ផលដំណាំដែលដាំដុះ កំពុងដុះលូតលាស់ ឬផលដំណាំដែលត្រូវដាំដុះ ជាដើម។

---

[64] មាត្រា៣ កថាខណ្ឌទី១៥ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

[65] មាត្រា៣ កថាខណ្ឌទី២៧ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

[66] មាត្រា៣ កថាខណ្ឌទី១ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

- ឧបករណ៍៖ ទំនិញដែលមិនត្រូវបានរាប់បញ្ចូលនូវកសិផល សារពើភណ្ឌ ទំនិញប្រើប្រាស់ ឬយានយន្តដែលមានលេខសេរី។[67] ឧទាហរណ៍ ត្រាក់ទ័រដែលប្រើប្រាស់ក្នុងគោលបំណងបំពេញកិច្ចប្រតិបត្តិការខាងផ្នែកកសិកម្មនោះគឺ ឧបករណ៍ មិនមែនជាសារពើភណ្ឌទេ។
- ទំនិញប្រើប្រាស់៖ ទំនិញគ្រប់ប្រភេទដែលបម្រើតម្រូវការផ្ទាល់ខ្លួន ឬក្រុមគ្រួសារតែប៉ុណ្ណោះ។ លើកលែងតែយានយន្តដែលមានលេខសេរីដែលអាចបង្កើតសិទ្ធិប្រាតិភោគបាន។[68] ឧទាហរណ៍ កុំព្យូទ័រ ដែលជាវត្ថុចំបងសម្រាប់ប្រើប្រាស់ជាលក្ខណៈបុគ្គល គ្រួសារ ឬគោលបំណងក្នុងផ្ទះសម្បែង។
- ចលនវត្ថុតាំងភ្ជាប់៖ ជាទំនិញដែលត្រូវបានតាំងភ្ជាប់ទៅនឹងអចលនវត្ថុ ដែលនាំឱ្យកើតឡើងនូវសិទ្ធិប្រត្យក្ស ប៉ុន្តែវានៅតែជាកម្មវត្ថុនៃប្រតិបត្តិការដែលមានកិច្ចធានា។[69] ដូចជា ទូរទស្សន៍ដែលភ្ជាប់ទៅនឹងអគារ។

➢ **កិច្ចសន្យាលក់ដែលមានការធានា**

គឺជាកំណត់ត្រាដែលបង្កើតកាតព្វកិច្ចបង់ប្រាក់ ឬសិទ្ធិប្រាតិភោគ។[70] ឧទាហរណ៍៖ ក បានទៅរក ខ ដើម្បីទិញត្រាក់ទ័ ដោយសន្យាថានឹងបង់ប្រាក់ជូន ខ ក្នុងរយៈពេលមួយខែៗ ដោយយកទំនិញក្នុងហាងរបស់ ក មកដាក់ជាទ្រព្យធានា តាមរយៈឯកសារកំណត់ត្រាជាលាយលក្ខណ៍អក្សរ។ ឯកសារនោះ ត្រូវបានចាត់ទុកថាជាកិច្ចសន្យាលក់ដែលមានកិច្ចធានា។ ពីព្រោះ គោលបំណងនៃកិច្ចសន្យានេះ គឺដើម្បីបម្រើនូវផលប្រយោជន៍ក្នុងការធ្វើជំនួញជាជាងប្រតិបត្តិការធម្មតា។

➢ **ឯកសារកម្មសិទ្ធិ**

សំដៅទៅលើបង្កាន់ដៃឃ្លាំង បង្កាន់ដៃដឹកជញ្ជូន ឬបង្កាន់ដៃរ៉ាប់រងកំពង់ផែ ដែលចេញដោយបុគ្គលធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ ឬស្តុកទំនិញ។[71] ឧទាហរណ៍៖ បង្កាន់ដៃដឹកជញ្ជូនទំនិញពីទីតាំងមួយ ទៅទីតាំងមួយដែលមានតម្លៃជាថ្នូរ។

➢ **លិខិតស្នាម**

ជាកំណត់ត្រាមួយដែលបង្ហាញថាបុគ្គលមានសិទ្ធិទទួលប្រាក់ ក៏មិនមែនជាកិច្ចព្រមព្រៀងប្រាតិភោគ ឬកិច្ចសន្យាជួល។ ឧទាហរណ៍៖ មូលប្បទានប័ត្រផ្ទាល់ខ្លួន ប័ណ្ណដែលអាចទូទាត់បាន ប័ណ្ណភាគហ៊ុន។

---

[67] មាត្រា៣ កថាខណ្ឌទី១៦ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

[68] មាត្រា៣ កថាខណ្ឌទី៣១ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

[69] មាត្រា៣ កថាខណ្ឌទី១៣ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

[70] មាត្រា៣ កថាខណ្ឌទី៦ នៃច្បាប់ស្តីពីប្រតិបត្តិការមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

[71] ក្រសួងពាណិជ្ជកម្ម, ឯកសារបណ្តុះបណ្តាល ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា, ៣០។

➢ **រូបិយប័ណ្ណបរទេស**

ក្នុងស្ថានភាពដែលយករូបិយប័ណ្ណបរទេស ធ្វើជាទ្រព្យអាចកើតឡើងបាន ក្នុងលក្ខខណ្ឌដែលភាគីម្ខាង ជាជនបរទេស ហើយគេយករូបិយប័ណ្ណដែលគេមានមកធ្វើជាទ្រព្យធានាសម្រាប់ការដោះដូរនៅរូបិយប័ណ្ណជាតិ ទៅប្រើប្រាស់ ទោះបីជាយ៉ាងណាក៏ដោយ ការចែងបែបនេះដើម្បីឱ្យច្បាប់មានលក្ខណៈគ្រប់ជ្រុងជ្រោយប៉ុណ្ណោះ ដោយឡែក សាច់ប្រាក់ក៏រាប់ចូលជាប្រភេទមួយនៃទ្រព្យធានាបានដែរ។[72] ដូចជា ករណីលោក ស បានយកសាច់ប្រាក់របស់ខ្លួនចំនួន ៥ម៉ឺនដុល្លារអាមេរិក ដាក់តម្កល់ក្នុងធនាគារមួយនៅអាមេរិក ដើម្បីធានាកូនច្បងរបស់លោក ទៅសិក្សាបន្តនៅសហរដ្ឋអាមេរិករយៈពេល៣ឆ្នាំ។ ប្រាក់តម្កល់ ជាលក្ខខណ្ឌតម្រូវរបស់ស្ថានទូតអាមេរិកដែល លោក ស មិនអាចដកប្រាក់មកចាយវាយផ្តេសផ្តាសឡើយ ប៉ុន្តែគាត់អាចយកទៅធ្វើជាទ្រព្យធានាបាន។

➢ **កិច្ចសន្យាជួលដែលមានរយៈពេលវែង**

គឺជាប្រតិបត្តិការដែលអ្នកជួលយល់ព្រមឱ្យអ្នកទទួលជួល មានសិទ្ធិកាន់កាប់សម្រាប់រយៈកំណត់មួយ ជាក់លាក់ ដោយមានការដាក់ទ្រព្យធានា។[73] កិច្ចសន្យានេះមានរយៈពេលលើសពី១ឆ្នាំ ឬអាចជាកិច្ចសន្យាដែល មិនមានកំណត់រយៈពេលច្បាស់លាស់ ដែលច្បាប់កំណត់ថាតិចជាងរយៈ១ឆ្នាំ។ ដូចនេះ នាពេលអនាគតកូន បំណុលអាចប្រគល់ឧបករណ៍ ឬទំនិញផ្សេងទៀតធ្វើជាទ្រព្យធានា និងតម្កល់លិខិតជូនដំណឹង។

**៣.១.២.២ កម្មវត្ថុជាទ្រព្យអរូបិយ**

ក្រៅពីប្រភេទទ្រព្យធានារូបិយដែលបានរៀបរាប់ខាងលើ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា មាន វិសាលភាពលើប្រភេទទ្រព្យធានាអរូបិយមួយចំនួនផងដែរនាពេលបច្ចុប្បន្ន ឬនឹងកើតឡើងនាពេលអនាគតដែល សំដៅទៅលើសិទ្ធិត្រូវទទួលបានតម្លៃពីជនទីបី។ វត្ថុអរូបិយត្រូវបានបែងចែកជាពីរគឺ គណនី និងទ្រព្យអរូបិយ ផ្សេងទៀតដែលមានរួមមាន៖

➢ **គណនី**

គឺសិទ្ធិទូទាត់លើទំនិញដែលលក់ ជួល ឬផ្តល់សេវាកម្មរួចហើយតែវាមិនមែនជាលិខិតស្នាម ឬកិច្ចសន្យា លក់ដែលមានកិច្ចធានានោះទេ។[74] ឧទាហរណ៍ គ ទទួលម៉ាស៊ីនច្រូតស្រូវពី ក ដោយសន្យាថានឹងទូទាត់ប្រាក់ នាពេលអនាគត ដោយ ក មានគណនីផ្ទាល់ខ្លួន។ ដូចនេះ ពួកគេបានព្រមព្រៀងថានឹងទូទាត់តាមរយៈគណនី របស់ ក។

---

[72] មាត្រា៣ កថាខណ្ឌទី១៥ និងកថាខណ្ឌទី២ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

[73] មាត្រា៣ កថាខណ្ឌទី២ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

[74] មាត្រា៣ កថាខណ្ឌទី១១ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

➢ **សិទ្ធិ**

សិទ្ធិរបស់កូនបំណុលក៏អាចក្លាយជាទ្រព្យធានាបានដែរ។ សិទ្ធិទាំងនោះមានដូចជា សិទ្ធិប្រត្យក្ស ឬសិទ្ធិផ្សេងទៀតដែលគាត់មាន។[75] ឧទាហរណ៍បន្ថែម កម្មសិទ្ធិបញ្ញា(ប័ណ្ណប៉ាតង់) គណនី ឯកសារកម្មសិទ្ធិ សិទ្ធិក្នុងការរុករករ៉ែជាដើម ទាំងនេះសុទ្ធតែជាប្រភេទទ្រព្យធានាអរូបិយ ដែលអាចបង្កើតជាប្រតិបត្តិការដែលមានកិច្ចធានា។

**៣.១.២.៣ ប្រតិបត្តិការដែលមិនស្ថិតនៅក្រោមប្រតិបត្តិការដែលមានកិច្ចធានា**

ថ្វីត្បិតច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាមានអានុភាពលើចលនវត្ថុ និងប្រតិបត្តិការជាច្រើន ប៉ុន្តែមានចលនវត្ថុ និងប្រតិបត្តិការមួយចំនួន ច្បាប់មិនអនុញ្ញាតឱ្យក្លាយជាប្រតិបត្តិការដែលមានកិច្ចធានានោះទេ។ មាត្រា២ ចំណុចទី៤ នៃច្បាប់នេះដដែរ បានកំណត់នូវប្រតិបត្តិការដែលមិនត្រូវបានអនុវត្តដោយយោងតាមច្បាប់នេះ រួមមាន៖

➢ **ការផ្ទេរសិទ្ធិទាមទារប្រាក់បៀវត្សរបស់និយោជិត**

ប្រាក់បៀវត្សរបស់និយោជិត មិនអាចក្លាយជាកម្មវត្ថុនៃទ្រព្យធានា ឬធ្វើការរឹបអូសដើម្បីបង្កើតសិទ្ធិប្រាតិភោគបានទេ ទោះបីជាការផ្ទេរនោះទទួលបានការយល់ព្រមពីនិយោជិតក៏ដោយ ព្រោះច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាពុំមានអានុភាពអនុវត្តលើចំណុចនេះទេ។ ឯការរឹបអូសប្រាក់ខែដោយមិនស្ម័គ្រចិត្ត ឬស្ម័គ្រចិត្តត្រូវអនុលោមនៅក្រោមច្បាប់ស្តីពីការងារ។[76]

➢ **ការបញ្ចាំអចលនវត្ថុ ឬសិទ្ធិដទៃទៀតលើអចលនវត្ថុ**

ចំពោះ អគារ ដី កាលណាបើយើងយកទៅប្រើប្រាស់ធ្វើជាទ្រព្យធានា គឺវាស្ថិតនៅក្រៅវិសាលភាពនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។ ផ្ទុយទៅវិញ ប្រតិបត្តិការដែលពាក់ព័ន្ធអចលនវត្ថុ ត្រូវស្ថិតនៅក្រោមវិសាលភាពនៃច្បាប់ភូមិបាលឆ្នាំ២០០១ និងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ តែទោះជាយ៉ាងនេះក្តី ចំពោះចលនវត្ថុតាំងភ្ជាប់ដែលជាផ្នែកមួយនៃអចលនទ្រព្យវិញ គឺត្រូវបានយកមកអនុវត្តក្នុងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ដែលនឹងធ្វើការពន្យល់នៅខាងក្រោម។[77]

---

[75]មាត្រា៤ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

[76]មាត្រា១ វាក្យខណ្ឌទី១ និងមាត្រា៤ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

[77]មាត្រា១ កថាខណ្ឌទី១ និងមាត្រា៣ កថាខណ្ឌទី១៣ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

- **ការលក់គណនី ឬកិច្ចសន្យាលក់ដែលមានកិច្ចធានា ដែលជាផ្នែកនៃការលក់អាជីវកម្ម**

សំដៅលើ ការលក់កិច្ចសន្យាដែលមានកិច្ចធានា នៅពេលដែលម្ចាស់អាជីវកម្មបានធ្វើការលក់អាជីវកម្ម របស់ខ្លួន រួមទាំងកិច្ចសន្យាលក់ដែលមានកិច្ចធានា ទៅអនាគតម្ចាស់អាជីវកម្ម។

- **អនុប្បទានគណនី កិច្ចសន្យាលក់ដែលមានកិច្ចធានា ឬលិខិតស្នាម សម្រាប់តែប្រមូលប្រាក់ដែលជំពាក់។**
- **ការប្រាក់លើប្រាក់បញ្ញើ គណនីមូលប្បទានបត្រ គណនីសញ្ញ័យ គណនីសាច់ប្រាក់ ដទៃទៀត។**
- **កិច្ចសន្យាជួលទំនិញរយៈពេលខ្លីដែលតិចជាង១ឆ្នាំ ដែលមានកំណត់ជាក់លាក់។**

## ៣.២ អានុភាពនៃប្រតិបត្តិការដែលមានកិច្ចធានា

ការភ្ជាប់សិទ្ធិប្រាតិភោគទៅនឹងទ្រព្យធានា គឺផ្តល់ឱ្យម្ចាស់បំណុលនូវសុក្រឹត្យភាព ដែលទទួលបានការការពារពេញលេញ ប៉ុន្តែដើម្បីទទួលបានការការពារ ភាគីម្ចាស់បំណុលត្រូវបំពេញលក្ខខណ្ឌទៅតាមកំណត់ដោយច្បាប់ ពីព្រោះការធ្វើសុក្រឹត្យគឺដើម្បីធានានូវសិទ្ធិរបស់ម្ចាស់បំណុលជាអតិបរមាក្នុងការតតាំងទៅនឹងតតិយជន។ ខាងក្រោមនេះនឹងសិក្សាលម្អិតអំពី មធ្យោបាយក្នុងការធ្វើសុក្រឹត្យកម្ម(៣.២.១) និងអាទិភាពនៃសុក្រឹត្យកម្ម (៣.២.២)។

### ៣.២.១ មធ្យោបាយក្នុងការធ្វើសុក្រឹត្យកម្ម

សុក្រឹត្យកម្ម គឺជាការដែលពង្រីកសិទ្ធិភាគីដែលមានកិច្ចធានា ឱ្យដល់កម្រិតអតិបរមាដើម្បីតទល់នឹងតតិយជន។ បើនិយាយឱ្យងាយយល់ពាក្យថាសុក្រឹត្យកម្ម គឺជាលក្ខខណ្ឌតតាំង ដែលអាចធ្វើឱ្យភាគីជាម្ចាស់បំណុលតតាំងសិទ្ធិជាមួយតតិយជនបាន ក្នុងករណីដែលមានវិវាទលើកម្មវត្ថុតែមួយនៃប្រតិបត្តិការកំពុងប្រព្រឹត្តនោះ។[78] ដោយអនុលោមតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា មធ្យោបាយនៃការធ្វើសុក្រឹត្យកម្មមានបីយ៉ាងគឺៈ សុក្រឹត្យកម្មដោយការតម្កល់លិខិតជូនដំណឹង ការផ្ទេរការកាន់កាប់ទ្រព្យធានា និងសុក្រឹត្យកម្មដោយស្វ័យប្រវត្តិ។

#### ៣.២.១.១ សុក្រឹត្យកម្មដោយការតម្កល់លិខិតជូនដំណឹង

ការតម្កល់លិខិតជូនដំណឹង គឺជាមធ្យោបាយមួយក្នុងការធ្វើសុក្រឹត្យកម្មលើសិទ្ធិប្រាតិភោគ។ បន្ទាប់ពីម្ចាស់បំណុលតម្កល់លិខិតជូនដំណឹង ម្ចាស់បំណុលដែលមានកិច្ចធានានឹងមានសិទ្ធិទាំងអស់ទៅលើអ្នកកាន់កាប់ទ្រព្យធានាដែលមិនបានធ្វើសុក្រឹត្យកម្ម ប្រសិនបើលិខិតជូនដំណឹងនេះមិនបានបាត់បង់ប្រសិទ្ធិភាព។[79]

[78] មាត្រា១២ កថាខណ្ឌទី១ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

[79] មាត្រា១០ កថាខណ្ឌទី២ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

## ➢ ការតម្កល់លិខិតជូនដំណឹង

ការតម្កល់លិខិតជូនដំណឹង ត្រូវធ្វើឡើងនៅការិយាល័យតម្កល់លិខិតជូនដំណឹងដែលត្រូវបានបង្កើតដោយក្រសួងពាណិជ្ជកម្ម ហើយការិយាល័យតម្កល់លិខិត ស្ថិតនៅក្រោមការត្រួតត្រារបស់នាយកដ្ឋាននីតិកម្មនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងស្រុក។[80] ផលប្រយោជន៍ដែលទទួលបានពីការតម្កល់គឺ ដើម្បីរើកដល់ម្ចាស់បំណុលពីសិទ្ធិទាមទារលើបំណុល និងកាលបរិច្ឆេទអាទិភាព ពោលអ្នកតម្កល់មុននឹងទទួលបានសិទ្ធិអាទិភាពមុនលើទ្រព្យធានាតែមួយ។ ករណី ម្ចាស់បំណុលពីរនាក់មានសិទ្ធិប្រាតិភោគលើទ្រព្យធានាតែមួយ ដោយពុំបានតម្កល់ ឬកាន់កាប់ទ្រព្យធានា នាំឱ្យសិទ្ធិប្រាតិភោគដែលភ្ជាប់នឹងទ្រព្យធានាដែលមានកាលបរិច្ឆេទមុនគេ មានអាទិភាពជាងគេ។ ជាទូទៅ ការតម្កល់លិខិតជូនដំណឹងត្រូវធ្វើឡើងតាមរយៈគេហទំព័រផ្លូវការដែលបង្កើតឡើងដោយក្រសួងពាណិជ្ជកម្មផ្ទាល់។ ដោយហេតុថា ការិយាល័យខាងលើនេះ ជាការិយាល័យរដ្ឋបាល ដែលបង្កឱ្យមានលក្ខណៈងាយស្រួល និងឆាប់រហ័ស ព្រមទាំងមានតម្លាភាព។ ជាពិសេស យើងអាចទាក់ទងសាកសួរព័ត៌មានប្រតិបត្តិការតម្កល់លិខិតនេះបានតាមរយៈប្រព័ន្ធស្វ័យប្រវត្តតែម្តង។ ចំណែកឯខ្លឹមសារនៃលិខិតជូនដំណឹងមានលក្ខណៈសាមញ្ញគឺតម្រូវឱ្យមានតែអត្តសញ្ញាណរបស់ម្ចាស់បំណុល និងកូនបំណុល ព្រមទាំងការអធិប្បាយអំពីទ្រព្យធានាតែប៉ុណ្ណោះ ចំពោះកំណត់ត្រាទាំងឡាយត្រូវបានអនុញ្ញាតឱ្យសាធារណៈជនចូលទៅសាកសួរបានដោយមិនមានការរើសអើងអ្វីឡើយ។ ប្រភេទលិខិតជូនដំណឹងអំពីសិទ្ធិប្រាតិភោគមាន ៥សំខាន់ៗ៖

- **លិខិតជូនដំណឹងដំបូង៖** មានសុពលភាពរយៈពេល៥ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការតម្កល់។ លិខិតជូនដំណឹងត្រូវចុះអត្តសញ្ញាណរបស់អ្នកតម្កល់ ម្ចាស់បំណុលដែលមានកិច្ចធានា ម្ចាស់ឥណទាន កូនបំណុល និងការអធិប្បាយអំពីទ្រព្យធានា។
- **លិខិតសុំកែប្រែ៖** អនុញ្ញាតឱ្យមានការផ្លាស់ប្តូរព័ត៌មាននៅក្នុងលិខិតជូនដំណឹងដំបូង ឬនៅក្នុងលិខិតសុំកែប្រែពីមុន។
- **លិខិតសុំបន្ត៖** គឺជាលិខិតដែលត្រូវតម្កល់ក្នុងកំឡុងពេល៦ខែ មុនកំណត់នៃលិខិតជូនដំណឹងដំបូង លិខិតសុំបន្តនេះមានអានុភាពបន្តរយៈពេល៥ឆ្នាំបន្ថែមទៀត។
- **លិខិតសុំកែតម្រូវ៖** គឺជាលិខិតដែលត្រូវបំពេញ ដើម្បីកែតម្រូវព័ត៌មានដែលយល់ថាលែងជាព័ត៌មានត្រឹមត្រូវ។
- **លិខិតសុំបញ្ចប់៖** ជាលិខិតដែលបញ្ចប់នូវលិខិតជូនដំណឹងទាក់ទងនឹងបុគ្គលដែលបានតម្កល់លិខិតជូនដំណឹង។

[80] មាត្រា៥, ១៦, ១៧ និង១៨ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្មឆ្នាំ២០១៤។

ចំណែកឯអាជ្ញាធរដែលមានសមត្ថកិច្ចលើកិច្ចការរដ្ឋបាលនេះ ត្រូវបានបង្កើតឡើងដើម្បីទទួលការតម្កល់ និងរក្សាគណនីសម្រាប់អតិថិជន។ ហើយការិយាល័យនេះ ក៏ត្រូវធ្វើការប្រមូលទិន្នន័យប្រាតិភោគ និងទិន្នន័យនានាពាក់ព័ន្ធនឹងការតម្កល់ផងដែរ។ ករណីយកិច្ចសំខាន់របស់ការិយាល័យតម្កល់លិខិត គឺត្រូវចុះលេខពិសេសលើលិខិតជូនដំណឹងនីមួយៗ កំណត់ពីកាលបរិច្ឆេទនៃការតម្កល់ កំណត់កាលបរិច្ឆេទកន្លងផុតទៅរបស់លិខិតជូនដំណឹងដំបូង រក្សាកំណត់ត្រាប្រសិនបើមានការសុំកែប្រែ និងការតម្កល់ដទៃទៀតដែលពាក់ព័ន្ធនឹងការតម្កល់លិខិតជូនដំណឹងដំបូងដែលមិនត្រឹមត្រូវ។ ក្រៅពីនេះត្រូវរក្សាបញ្ជីរាយនាមតាមអក្ខរក្រមនៃឈ្មោះកូនបំណុល។ ករណីយកិច្ចដែលត្រូវរក្សាទុកនូវលិខិតជូនដំណឹងមានរយៈពេល១០ឆ្នាំក្រោយកាលបរិច្ឆេទផុតរយៈពេលរបស់លិខិតជូនដំណឹង។ លិខិតបទដ្ឋានទាំងអស់ជាការទទួលខុសត្រូវចេញដោយ ក្រសួងពាណិជ្ជកម្ម ដែលស្របទៅតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា រួមមានដូចជា៖

- ថ្លៃងការណ៍បញ្ជាក់ចំពោះកំណត់ត្រាដែលបានតម្កល់នីមួយៗ។ ដូចជា ប្រាប់ពីអត្តសញ្ញាណរបស់អ្នកតម្កល់ រាយការណ៍អំពីទិន្នន័យទាំងអស់ដែលផ្តល់ទៅឱ្យការិយាល័យតម្កល់ ផ្តល់នូវលេខពិសេសសម្រាប់លិខិតជូនដំណឹងដំបូង។ ករណីមានការតម្កល់លិខិតបន្តបន្ទាប់ នឹងចុះនូវពេលវេលា ព្រមទាំងកាលបរិច្ឆេទតម្កល់។
- របាយការណ៍គណនីលើថ្លៃដែលបានជំពាក់។
- វិក័យប័ត្រលើថ្លៃបានដែលបង់រួច។
- របាយការណ៍ស្រាវជ្រាវលើពាក្យសុំដែលពឹងផ្អែកតាមលក្ខខណ្ឌច្បាប់ ដែលរួមមានព័ត៌មាននៅលើលិខិតជូនដំណឹងទាំងអស់ រួមទាំងការកែប្រែ បន្ត និងបញ្ចប់។
- លិខិតបដិសេធ នៅក្នុងករណីដែលក្រសួងបដិសេធមិនធ្វើការតម្កល់ដល់អ្នកស្នើសុំដែលមិនបំពេញលក្ខខណ្ឌនៃពាក្យសុំ។

ដោយឡែកការិយាល័យតម្កល់លិខិតជូនដណឹងបានផ្តល់នូវគុណសម្បត្តិ និងសម្របសម្រួលលក្ខខណ្ឌច្រើនយ៉ាងចំពោះវិស័យពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជា ដូចជា ផ្តល់ភាពងាយស្រួលដោយគ្រាន់តែបញ្ចូលនូវព័ត៌មានតិចតួចបំផុតក្នុងការតម្កល់លិខិតជូនដណឹង មានតម្លាភាព ចំពោះម្ចាស់បំណុលនូវភាពច្បាស់លាស់ក្នុងការធ្វើប្រតិបត្តិការមួយដែលគ្មានហានិភ័យនាពេលអនាគត ចំណាយតិច ព្រមទាំងផ្តល់គុណប្រយោជន៍ដល់ពាណិជ្ជករក្នុងការទទួលបានការសន្សំផ្នែកហិរញ្ញវត្ថុជាងប្រតិបត្តិការនៅក្នុងច្បាប់ផ្សេងៗ។

### ៣.២.១.២ ការផ្ទេរការកាន់កាប់ទ្រព្យធានា

ការផ្ទេរការកាន់កាប់ទ្រព្យធានាទៅម្ចាស់បំណុល ក៏ជាមធ្យោបាយមួយក្នុងការធ្វើសុក្រឹត្យកម្មផងដែរ។ ការផ្ទេរការកាន់កាប់នេះ មានលក្ខណៈស្រដៀងទៅនឹងវិធាននៃការបញ្ចាំចលនវត្ថុដែលតម្រូវឱ្យម្ចាស់បំណុលកាន់

កាប់ទ្រព្យធានាដើម្បីតតាំងនិងតតិយជន។ ដោយឡែក មធ្យោបាយកាន់កាប់នៅក្នុងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា មិនមែនអាចអនុវត្តបានលើគ្រប់កម្មវត្ថុនៃប្រតិបត្តិការឡើយ។ ការកាន់កាប់អាចធ្វើបាន ប្រសិនបើទ្រព្យធានាជា ទំនិញ លិខិតស្នាម ឯកសារ ប័ណ្ណភាគហ៊ុនជាដើម ដែលមានភាពស្រដៀងគ្នាទៅនឹងកម្មវត្ថុនៃការធ្វើសុក្រឹត្យកម្មតាមការតម្កល់លិខិតជូនដំណឹងដែរ។

គួរកត់ចំណាំថា ករណីម្ចាស់បំណុលជ្រើសរើសវិធីតាមរយៈការផ្ទេរការកាន់កាប់ដើម្បីធ្វើសុក្រឹត្យកម្មនោះ សុក្រឹត្យភាពនឹងកើតមានតែខណៈដែលម្ចាស់បំណុលកាន់កាប់លើទ្រព្យធានាតែប៉ុណ្ណោះ ផ្ទុយមកវិញ នៅពេលដែលម្ចាស់បំណុលលែងកាន់កាប់ហើយ សុក្រឹត្យកម្មនឹងត្រូវបានបញ្ឈប់។[81] ជំរើសដ៏ប្រសើរ ម្ចាស់បំណុលគួរតែពិចារណាធ្វើការតម្កល់លិខិតជូនដំណឹងដែលអាចធានាសុក្រឹត្យភាពបានគ្រប់ពេលវេលា ដរាបណាលិខិតជូនដំណឹងនោះនៅតែមានប្រសិទ្ធិភាព។

ដូចករណីខាងលើផងដែរ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាមិនបានបញ្ញត្តិជាក់លាក់អំពីការផ្ទេរការកាន់កាប់នោះទេ យោងតាមមាត្រា៧២ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី បានចែងអំពីការសម្របសម្រួលនៃច្បាប់ទាំងពីរនេះ យើងអាចយកបញ្ញត្តិស្តីពីការកាន់កាប់នៅក្នុងច្បាប់សារធាតុ មកអនុវត្តក្នុងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាបានដែរ។ ការផ្ទេរការកាន់កាប់ត្រូវបានបែងចែកជាបួន ដូចជា ការផ្ទេរការកាន់កាប់ដោយជាក់ស្តែង ការផ្ទេរដោយប្តូរលក្ខណៈនៃការកាន់កាប់ ការផ្ទេរដោយការសង្ខេប និងការផ្ទេរដោយការបញ្ជា។

- **ការផ្ទេរដោយជាក់ស្តែង៖** គឺជាការប្រគល់វត្ថុដោយផ្ទាល់។
- **ការផ្ទេរដោយប្តូរលក្ខណៈនៃការកាន់កាប់៖** គឺជាការផ្ទេរកាន់កាប់ដោយផ្ទាល់ គ្រាន់តែមានការព្រមព្រៀងរវាងគូភាគី ពោលគឺមិនមានការប្រគល់វត្ថុជាក់ស្តែងទេ។ ប៉ុន្តែអាចនាំឱ្យអ្នកទទួលបានការកាន់កាប់ពីការផ្ទេរ ក្លាយជាអ្នកដែលធ្វើការកាន់កាប់ដោយប្រយោល។
- **ការផ្ទេរការកាន់កាប់ដោយសង្ខេប៖** ជាការផ្ទេរដែលអ្នកនឹងទទួលបានសិទ្ធិកាន់កាប់តាមរយៈអនុប្បទាន ដែលអ្នកបានក្តាប់ទុកវត្ថុនោះដោយចំពោះតាមការជាក់ស្តែងមុនរួចជាស្រេចមកហើយ ចុងក្រោយគ្រាន់តែមានការព្រមព្រៀងរវាងគូភាគីតែប៉ុណ្ណោះ។
- **ការផ្ទេរការកាន់កាប់ដោយបញ្ជា៖** គឺជាការផ្ទេរដែលវត្ថុស្ថិតនៅក្នុងដៃតតិយជន ទៅឱ្យតតិយជនម្នាក់ទៀត ដោយអ្នកកាន់កាប់ដោយប្រយោល។ ការផ្ទេរមានសុពលភាព លុះត្រាតែ មានការព្រមព្រៀងពីអនុប្បទានិក និងធ្វើការជូនដំណឹងទៅអ្នកកាន់កាប់ដោយចំពោះ។

[81] មាត្រា១០ កថាខណ្ឌទី៥ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

ជាក់ស្តែង ការផ្ទេរកាន់កាប់ខាងលើនេះ មានតែការផ្ទេរការកាន់កាប់បីប្រភេទប៉ុណ្ណោះ ដែលអាចយកមកអនុវត្តនៅក្នុងការធ្វើសុក្រឹត្យកម្មបាន គឺការផ្ទេរការកាន់កាប់ដោយផ្ទាល់ ការផ្ទេរការកាន់កាប់ដោយសង្ខេប និងការផ្ទេរការកាន់កាប់ដោយបញ្ជា។ យោងតាមមាត្រា៨១៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ គឺមិនអនុញ្ញាតឱ្យកូនបំណុលធ្វើការកាន់កាប់វត្ថុធានាដោយផ្ទាល់ឡើយ ជាមូលហេតុ ធ្វើឱ្យការផ្ទេរការកាន់កាប់ដោយប្តូរលក្ខណៈនៃការកាន់កាប់មិនអាចយកមកអនុវត្តបាននៅក្នុងប្រតិបត្តិការនេះ។

**៣.២.១.៣ ការធ្វើសុក្រឹត្យកម្មដោយស្វ័យប្រវត្តិ**

ករណីដែលសិទ្ធិប្រាតិភោគមួយចំនួនត្រូវបានភ្ជាប់ទៅនឹងវត្ថុធានា នោះសុក្រឹត្យភាពនឹងកើតមានដោយឯកឯងទៅលើសិទ្ធិប្រាតិភោគនោះ ដោយមិនចាំបាច់មានសកម្មភាពអ្វីពីគូភាគីឡើយ ដែលគេហៅថា សុក្រឹត្យកម្មដោយស្វ័យប្រវិត្ត។ ក្រៅពីមធ្យោបាយនៃការធ្វើសុក្រឹត្យកម្មតាមរយៈការតម្កល់លិខិតជូនដំណឹង និងការកាន់កាប់សុក្រឹត្យកម្មដោយស្វ័យប្រវត្តិ មានករណីខ្លះទៀតដែលសិទ្ធិប្រាតិភោគត្រូវបានភ្ជាប់ទៅនឹងទំនិញប្រើប្រាស់ផងដែរ។

សិទ្ធិប្រាតិភោគលើទំនិញប្រើប្រាស់ ត្រូវបានធ្វើសុក្រឹត្យកម្មដោយស្វ័យប្រវត្តិនៅពេលដែល សិទ្ធិភ្ជាប់ទៅនឹងទំនិញប្រើប្រាស់ ពីព្រោះថា ទំនិញប្រើប្រាស់តែងតែមានតម្លៃទាប។ ដូច្នេះ ដើម្បីកាត់បន្ថយម្ចាស់បំណុលការចំណាយច្រើនចំពោះថ្លៃចុះបញ្ជីលើទំនិញប្រើប្រាស់។ ច្បាប់ក៏ពុំបានហាមឃាត់ម្ចាស់បំណុលអំពីការតម្កល់លិខិតជូនដំណឹងសិទ្ធិប្រាតិភោគដើម្បីបង្កើតសិទ្ធិលើទំនិញប្រើប្រាស់នោះដែរ ប្រសិនបើអ្នកទិញចង់ទិញទំនិញពីកូនបំណុល ហើយសិទ្ធិប្រាតិភោគលើទំនិញប្រើប្រាស់របស់កូនបំណុលពុំមានការតម្កល់ អាចផ្តល់ហានិភ័យសម្រាប់អ្នកទិញទំនិញប្រើប្រាស់ដែលជាប់នូវសិទ្ធិប្រាតិភោគពីមុន។ យ៉ាងណាមិញ ការតម្កល់លិខិតជូនដំណឹងនៅតែផ្តល់ការធានាខ្ពស់ជាងការមិនតម្កល់។

**៣.២.២ អាទិភាពនៃសុក្រឹត្យកម្ម**

ជាគោលការណ៍ ការភ្ជាប់សិទ្ធិប្រាតិភោគលើទ្រព្យធានាដោយការតម្កល់លិខិតជូនដំណឹងមុនគេ គឺជាការបញ្ជាក់នូវអាទិភាពលើសិទ្ធិផ្សេងទៀតដែលតម្កល់ក្រោយ។ ការតម្កល់លិខិតជូនដំណឹងមុនគេនេះហើយ នាំឱ្យសិទ្ធិប្រាតិភោគត្រូវបានភ្ជាប់នឹងទំនិញប្រើប្រាស់គ្រប់ពេល មិនថាទ្រព្យធានាស្ថិតក្នុងដៃបុគ្គលណាឡើយ។[82] ដោយឡែក អាទិភាពអាចកើតឡើងលើប្រភេទទ្រព្យធានាតែមួយ(៣.២.២.១) រួមផ្សំ អាទិភាពគាហកៈនៃសិទ្ធិឃាត់ទុក(៣.២.២.២) និងអាទិភាពនៃអ្នកទិញទ្រព្យធានាក្នុងប្រតិបត្តិការដែលមានកិច្ចធានា(៣.២.២.៣)។

[82] មាត្រា១០ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

### ៣.២.២.១ អាទិភាពលើប្រភេទទ្រព្យធានាតែមួយ

ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាបានបញ្ញត្តិរួចជាស្រេច ក្នុងការដោះស្រាយបញ្ហានានាដែលអាចកើតមានឡើងកាលណាកម្មវត្ថុដែលជាទ្រព្យធានាបានភ្ជាប់ទៅនឹងប្រតិបត្តិការពីរ ឬច្រើនក្នុងពេលតែមួយ។ ពេលខ្លះអាចជាផលវិបាកសម្រាប់គូភាគីក្នុងការស្វែងរកភស្តុតាងដែលច្បាប់នេះតម្រូវ។ ដូចនេះ តាមមាត្រា១២ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ក្នុងករណី មានសិទ្ធិប្រាតិភោគច្រើនលើទ្រព្យធានាតែមួយ ត្រូវមានអាទិភាពដោយយោងទៅតាមពេលវេលានៃការតម្កល់លិខិតជូនដំណឹង ឬការធ្វើសុក្រឹត្យភាព។ លើកលែងច្បាប់ផ្សេងចែងពីនេះ។ ក្នុងករណីដែលសិទ្ធិប្រាតិភោគទាំងអស់មិនបានធ្វើការតម្កល់លិខិតជូនដំណឹង ឬធ្វើសុក្រឹត្យភាពទេ អាទិភាពនឹងកើតមានចំពោះតែសិទ្ធិប្រាតិភោគណាដែលបានភ្ជាប់ទៅនឹងទ្រព្យធានាមុនគេប៉ុណ្ណោះ។

### ៣.២.២.២ អាទិភាពនៃគាហកៈនៃសិទ្ធិឃាត់ទុក

ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាបានចែងអំពី ការប្រឈមមុខគ្នារវាងម្ចាស់បំណុលដែលមានកិច្ចធានា និងម្ចាស់បំណុលពិសេសផ្សេងទៀត ដូចជា គាហកៈនៃសិទ្ធិឃាត់ទុកជាដើម។ ករណីគាហកៈនៃសិទ្ធិឃាត់ទុកមានអាជ្ញាធរពន្ធ ឬអ្នកទទួលបានសេចក្តីសម្រេច មានសិទ្ធិក្នុងការដកហូតយកទ្រព្យធានា។ តាមច្បាប់ប្រតិបត្តិការដែលមានកិច្ចធានា មន្ត្រីក្នុងនីតិវិធីក្ស័យធន គឺជាគាហកៈនៃសិទ្ធិឃាត់ទុក។ ជាមួយគ្នានេះ គាហកៈនៃសិទ្ធិឃាត់ទុកអាចជាបុគ្គលដែលមានសិទ្ធិទូទៅ ឬសិទ្ធិពិសេសក្រោមច្បាប់ផ្សេងទៀត។ គាហកៈនៃសិទ្ធិឃាត់ទុក ត្រូវបានតម្រូវឱ្យចុះបញ្ជីតម្កល់លិខិតជូនដំណឹងក្នុងការធ្វើសុក្រឹត្យកម្ម ដូចជាម្ចាស់បំណុលនៃទ្រព្យធានា។[83] ជាគោលការណ៍ គាហកៈនៃសិទ្ធិឃាត់ទុកមានអាទិភាពមុនគេ ប្រសិនបើបានតម្កល់លិខិតជូនដំណឹងមុនគេ។

### ៣.២.២.៣ អាទិភាពនៃអ្នកទិញទ្រព្យធានា

សិទ្ធិប្រាតិភោគនៅតែភ្ជាប់ទៅនឹងទ្រព្យធានា ទោះបីទ្រព្យធានានោះត្រូវបានលក់ ឬប្តូរក៏ដោយ។ ដោយឡែក ចំពោះការបង្កើតសិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញទំនិញប្រើប្រាស់ ជាប្រតិបត្តិការមួយត្រូវបានស្គាល់ថា ការលក់ទិញ "*ជឿ*" ធ្វើឱ្យមានផលវិបាកសម្រាប់អ្នកទិញក្នុងការវិនិច្ឆ័យថា ទំនិញនេះមានជាប់សិទ្ធិប្រាតិភោគ ឬអត់ដែលកើតឡើងដោយសារតែ សុក្រឹត្យកម្មដោយស្វ័យប្រវត្តិ ដូចដែលបានរៀបរាប់ខាងដើម។ ហេតុដូច្នេះ អ្នកទិញទំនិញប្រើប្រាស់ ដែលជាអ្នកទិញទំនិញអាជីវកម្មធម្មតាពីកូនបំណុលមិនជាប់សិទ្ធិប្រាតិភោគឡើយ ពោលទោះបីជាទំនិញនោះស្ថិតនៅក្នុងដៃជនទីបីហើយក៏ដោយ[84] ករណីលើកលែងនេះ មានសារៈសំខាន់ណាស់ចំពោះអ្នកទិញ។ អ្នកទិញដែលទទួលបានសិទ្ធិដោយមិនមានជាប់សិទ្ធិប្រាតិភោគលើទំនិញមានដូចជា អ្នកទិញក្នុងអាជីវកម្មធម្មតា អ្នកទិញទំនិញប្រើប្រាស់ អ្នកទិញយានយន្តដែលមានលេខស៊េរី អ្នកទិញកសិផល ជាដើម។

[83] មាត្រា១៣ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

[84] មាត្រា១០ កថាខណ្ឌទី៣ ច្បាប់ប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

ចំណាំ ម្ចាស់បំណុលដែលមានកិច្ចធានា និងម្ចាស់បំណុលដទៃទៀតដែលមានសិទ្ធិអាទិភាពតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា អាចព្រមព្រៀងគ្នាក្នុងការកែប្រែ ឬលុបចោលអាទិភាពរបស់ខ្លួនបាន និងមិនចាំបាច់ធ្វើការតម្កល់លិខិតជូនដំណឹងទេ។

ដោយឡែកបន្ទាប់ពីកិច្ចសន្យាមួយត្រូវបានបង្កើតឡើងហើយ ប្រសិនបើស្ថិតនៅក្នុងស្ថានភាពណាមួយដែលកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមខ្លឹមសារនៃកិច្ចសន្យានោះទេ តើម្ចាស់បំណុលត្រូវធ្វើបែបណាដើម្បីទទួលបានសំណងត្រលប់មកវិញ? តើកូនបំណុលខ្លួនឯងនឹងត្រូវទទួលបានការការពារ ឬវិធីសាស្ត្រសង្គ្រោះយ៉ាងណាខ្លះ? ចំណុចនេះនឹងត្រូវបានលើកមកយកបង្ហាញនៅផ្នែកបន្ទាប់(៣.៣)។

## ៣.៣ ការអនុវត្តសិទ្ធិ និងកាតព្វកិច្ច

កិច្ចប្រតិបត្តិការអាចដំណើរការបានល្អ លុះត្រាតែគូភាគីនៃការអនុវត្តយល់ដឹងអំពីសិទ្ធិ និងករណីយកិច្ចរបស់ខ្លួនជាមុន។ ការស្វែងយល់អំពីសិទ្ធិ និងករណីយកិច្ចរបស់គូភាគី បង្កឱ្យមានលក្ខណៈងាយស្រួលសម្រាប់កូនបំណុលជាដំបូង មុននឹងជ្រើសរើសនូវទម្រង់ប្រតិបត្តិការណាមួយដែលខ្លួនយល់ថាមានសមត្ថភាពគ្រប់គ្រាន់ដើម្បីបំពេញលក្ខខណ្ឌទាំងឡាយដែលបានកំណត់ដោយច្បាប់ ហើយម្ចាស់បំណុលដែលមានកិច្ចធានា ក៏អាចធ្វើការតតាំងសិទ្ធិជាមួយម្ចាស់បំណុលដទៃទៀត ឬលើកឡើងអំពីសិទ្ធិស្របច្បាប់របស់ខ្លួន។ នៅក្នុងផ្នែកនេះយើងនឹងសិក្សាទៅលើការអនុវត្តប្រតិបត្តិការដែលមានកិច្ចធានា ដោយផ្តោតជាពិសេសលើ សិទ្ធិ និងករណីយកិច្ចរបស់គូភាគីដែលមានកិច្ចធានា(៣.៣.១) និងកត្តាមួយចំនួនដែលអាចនាំឱ្យសិទ្ធិ និងករណីយកិច្ចរបស់គូភាគីត្រូវបានរំលត់(៣.៣.២)។

### ៣.៣.១ សិទ្ធិ និងករណីយកិច្ចរបស់គូភាគី

#### ៣.៣.១.១ សិទ្ធិ និងករណីយកិច្ចរបស់ម្ចាស់បំណុល

ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាពុំបានកំណត់ពីការមិនសងបំណុល ឬមិនបានចែងថាតើពេលណា ឬក្នុងកាលៈទេសៈណាដែលការមិនសងបំណុលកើតឡើងនោះទេ បើយោងតាមកិច្ចព្រមព្រៀងប្រាតិភោគ ជាកិច្ចសន្យារវាងគូភាគី។ ដូចនេះហើយ គូភាគីនៃកិច្ចសន្យាមានសេរីភាពក្នុងការកំណត់ពីស្ថានភាពនៃការមិនសងបំណុលបាន។ បញ្ហាកើតត្រង់ថា ប្រសិនបើស្ថិតនៅក្នុងស្ថានភាពណាមួយដែលកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមខ្លឹមសារនៃកិច្ចសន្យានោះទេ តើម្ចាស់បំណុលត្រូវធ្វើបែបណាដើម្បីទទួលបានសំណង? ដោយយោងតាមមាត្រា៤៦ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា បានអនុញ្ញាតឱ្យភាគីជាម្ចាស់បំណុលអនុវត្តសិទ្ធិណាមួយ ឬទាំងអស់របស់ខ្លួនទៅលើកូនបំណុល នៅពេលដែលកូនបំណុលមិនបានអនុវត្តកាតព្វកិច្ច តាមការកំណត់របស់គូភាគីក្នុងកិច្ចសន្យាប្រាតិភោគ។ សិទ្ធិទាំងនោះរួមមាន សិទ្ធិក្នុងការឃាត់ទុក(ក) សិទ្ធិក្នុងការកាន់កាប់(ខ) និងសិទ្ធិក្នុងការប្រមូលទ្រព្យធានា (គ)។

**ក.សិទ្ធិក្នុងការឃាត់ទុក**

មាត្រា៥១ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ម្ចាស់បំណុលនៃកិច្ចធានាអាចធ្វើការស្នើសុំឃាត់ទុកទ្រព្យធានាដើម្បីឱ្យមានការទូទាត់ពីកូនបំណុល។ ការស្នើសុំនេះអាចកើតឡើងបាន លុះត្រាតែកូនបំណុលយល់ព្រមក្នុងរយៈពេល២០ថ្ងៃ បន្ទាប់ពីមានការស្នើសុំដើម្បីឃាត់ទុកទ្រព្យធានាកាតព្វកិច្ចពីម្ចាស់បំណុលរួចម្ចាស់បំណុលអាចរក្សាទុកទ្រព្យធានានោះ រហូតដល់កូនបំណុលអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ ក៏ប៉ុន្តែច្បាប់ស្តីពីប្រតិបត្តិដែលមានកិច្ចធានា មិនបានកំណត់លក្ខខណ្ឌនៃការឃាត់ទុកទ្រព្យធានាពីកូនបំណុលឡើយ តម្រូវឱ្យបញ្ញត្តិស្តីពីការឃាត់ទុកដែលមាននៅក្នុងក្រមរដ្ឋប្បវេណីចូលខ្លួនមកគ្រប់គ្រងបញ្ហានេះជំនួសវិញ។ យោងតាមមាត្រា៧៧៤ នៃក្រមរដ្ឋប្បវេណី បានចែងថា សិទ្ធិឃាត់ទុកមិនត្រូវកើតមាន ប្រសិនបើសិទ្ធិលើបំណុលមិនទាន់ដល់ពេលកំណត់ត្រូវសង។ ផ្ទុយទៅវិញ ប្រសិនបើកូនបំណុលមិនយល់ព្រមក្នុងរយៈពេល២០ថ្ងៃខាងលើទេនោះម្ចាស់បំណុលត្រូវជ្រើសរើសវិធីផ្សេងមួយទៀតគឺ ការជម្រះចោលទ្រព្យធានា។

**ខ.សិទ្ធិក្នុងការកាន់កាប់**

ក្រោយពេលដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ម្ចាស់បំណុលមានកិច្ចធានាអាចធ្វើការស្នើសុំទៅកូនបំណុលជាលាយលក្ខណ៍អក្សរដើម្បីធ្វើការកាន់កាប់ ឬ ត្រួតត្រាលើទ្រព្យធានាមួយផ្នែក ឬ ទាំងមូលដោយមិនចាំបាច់ដាក់ពាក្យបណ្តឹងទៅតុលាការ។ ក្រោយមក ប្រសិនបើក្នុងកំឡុងពេលបន្ទាប់ពីមានការស្នើសុំរួចហើយ កូនបំណុលបែរជាធ្វើការជំទាស់ នោះម្ចាស់បំណុលអាចធ្វើការប្តឹងទៅតុលាការដើម្បីផ្តល់សិទ្ធិឱ្យខ្លួនក្នុងការកាន់កាប់ ឬត្រួតត្រាទ្រព្យធានាតាមរយៈ ***ដីកាសម្រេចជាប្រញាប់ដោយស្របច្បាប់***។[85]

ម្ចាស់បំណុលអាចយកដីកាសម្រេចស្ពាពររបស់តុលាការមកអនុវត្តបាន ក្នុងករណីដែលត្រូវការកម្លាំងដើម្បីកាន់កាប់ទ្រព្យធានា។ ម្ចាស់បំណុលអាចពឹងពាក់កម្លាំងអាជ្ញាសាលា ឬមន្ត្រីនគរបាលយុត្តិធម៌ដោយត្រូវបង់ថ្លៃសេវាជាប្រាក់រៀល តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងយុត្តិធម៌។

**គ.សិទ្ធិក្នុងការប្រមូលទ្រព្យធានា**

ករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចសងបំណុលទៅម្ចាស់បំណុលទេនោះ ម្ចាស់បំណុលខ្លួនឯងមានសិទ្ធិភ្លាមៗក្នុងការប្រមូលនូវគណនីដែលជាទ្រព្យធានា ឬផលនៃទ្រព្យធានាបាន ដោយមិនចាំបាច់ប្តឹងទៅតុលាការដើម្បីអនុវត្តនីតិវិធីឡើយ។ ម្ចាស់បំណុលអាចធ្វើការជូនដំណឹងទៅកូនបំណុលដើម្បីឱ្យសង ឬមិនសងបំណុលមកខ្លួន។ នៅពេលម្ចាស់បំណុលបានប្រមូលបំណុលពីគណនីរបស់កូនបំណុលហើយ ប្រសិនបើ

[85] ដីកាសម្រេចកិច្ចការប្រញាប់នេះ ជាសាញ្ញាណនៅក្នុងសារាចរលេខ០៤ នៅក្នុងនីតិវិធីរដ្ឋប្បវេណី ដែលដាក់ឱ្យប្រើក្នុងសម័យរដ្ឋកម្ពុជា និងបន្តប្រើប្រាស់នៅក្នុងសម័យអន្តរកាល រហូតដល់ពេលដែលក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧ ដាក់ឱ្យអនុវត្តទើបនិរាករណ៍សារាចរណ៍នេះ។

ចំនួនទឹកប្រាក់មានទំហំលើសពីទំហំបំណុលដែលត្រូវសង ម្ចាស់បំណុលត្រូវទូទាត់ចំណែកដែលលើសឱ្យមកកូនបំណុលវិញ។ ប៉ុន្តែ ចំណែកដែលលើសនោះ មិនអាចរំលត់សិទ្ធិលើបំណុលរបស់ម្ចាស់បំណុលបានឡើយ កូនបំណុលនៅតែមានកាតព្វកិច្ចសងបំណុលទៅឱ្យម្ចាស់បំណុលនូវទំហំសេសសល់ដដែរ។ ក៏មិនអាចអនុវត្តបានឡើយ ចំពោះប្រតិបត្តិការជាការលក់គណនី ឬកិច្ចសន្យាលក់ដែលមានកិច្ចធានា ដែលម្ចាស់បំណុលត្រូវទទួលខុសត្រូវលើការខាតបង់ ឬចំណេញពីការប្រមូលបំណុលពីកូនបំណុល លើកលែងតែមានចែងផ្សេងពីនេះនៅក្នុងកិច្ចព្រមព្រៀងប្រាតិភោគ។[86]

### ៣.៣.១.២ សិទ្ធិ និងករណីយកិច្ចរបស់កូនបំណុល

#### ក.សិទ្ធិក្នុងការសម្រេចអំពីប្រភេទចលនវត្ថុ និងការបង់រំលស់

តាមរយៈប្រតិបត្តិការដែលមានកិច្ចធានា កូនបំណុលមានសិទ្ធិក្នុងការសម្រេចអំពីប្រភេទចលនវត្ថុ ទៅតាមតម្រូវការអាជីវកម្មរបស់ខ្លួន ដូចជា រថយន្តដឹកទំនិញ ម៉ាស៊ីនកិបស្រូវជាដើម ដោយដាក់ទ្រព្យធានារបស់ខ្លួនចំពោះម្ចាស់បំណុលដែលមានកិច្ចធានា។ ករណី កូនបំណុលបង្កើតកិច្ចសន្យាប្រាតិភោគជាមួយធនាគារ CIMB BANK(ស៊ីអាយអឹមប៊ី) ឃើញថា មានលក្ខខណ្ឌមួយចំនួនទាមទារឱ្យកូនបំណុលធ្វើការបង់រំលស់ថេរជាប្រចាំខែ ឬពាក្យបច្ចេកហៅថា EMI។ ចំនួនទឹកប្រាក់បង់រំលស់ប្រចាំខែ គឺអាស្រ័យលើទំហំទឹកប្រាក់ឥណទាន រយៈពេលឥណទាន និងអត្រាការប្រាក់ នៃឥណទាន។ ការបង់រំលស់ជាមួយ ធនាគារ CIMB BANK(ស៊ីអាយអឹមប៊ី) កូនបំណុលត្រូវបង់រំលស់ប្រាក់ដើម និងការប្រាក់ EMI ទៅធនាគារ នៅថ្ងៃដំបូង នៃរៀងរាល់ខែនីមួយៗ។ ប្រសិនបើខែដំបូង កូនបំណុលមិនបានបង់ពេញមួយខែទេ នោះតម្រូវឱ្យបង់តែការប្រាក់ប៉ុណ្ណោះ ហើយរយៈពេលនៃការបង់រំលស់តែអត្រាការប្រាក់នេះ ហៅថា Pre-EMI។ EMI = ប្រាក់ដើម + ការប្រាក់។ ការប្រាក់ត្រូវបានគណនា លើសមតុល្យប្រាក់ដើមដែលនៅសល់ ចំណែកឯ ប្រាក់ដើមឥណទាន នឹងត្រូវបានថយចុះ បន្ទាប់ពីមានការបង់រំលស់ជារៀងរាល់ខែ។ ក្នុងអំឡុងពេលចាប់ផ្ដើមដំបូង EMI នឹងគិតលើការប្រាក់ជាចម្បង គិតរហូតដល់ចប់ EMI ធនាគារនឹងទូទាត់ឥណទានដើមដែលនៅសេសសល់វិញ។ ការណ៍អនុវត្តប្រតិបត្តិការខាងលើ កូនបំណុល ត្រូវអនុលោមទៅតាមកាលវិភាគទូទាត់ប្រាក់ ឬហៅថា កាលវិភាគបង់រំលស់ ពីក្រុមការងារផ្នែកឥណទាន ជាមួយនឹងព័ត៌មានលម្អិត លើការបង់រំលស់ប្រចាំខែ ប្រាក់ដើម ការប្រាក់ និងសមតុល្យឥណទាន។ ដូច្នេះ មានន័យថាកូនបំណុលមានសិទ្ធិក្នុងការសម្រេចអំពីប្រភេទចលនវត្ថុទៅតាមតម្រូវការជាក់ស្តែង ជាមួយការបង់រំលស់ដោយដាក់ទ្រព្យធានានឹងម្ចាស់បំណុលដែលមានកិច្ចធានា ហើយកូនបំណុល ចាំបាច់ទទួលខុសត្រូវសងប្រាក់សមតុល្យរវាងប្រាក់បំណុល និងប្រាក់ដែលប្រមូលបាន លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ[87]។ ផ្ទុយមកវិញ

[86] ក្រសួងពាណិជ្ជកម្ម, ការពន្យល់ និងឧទាហរណ៍ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា, (ឯកសារបណ្ដុះបណ្ដាល) ១០២

[87] មាត្រា៤៧ កថាខណ្ឌទី៣ នៃស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

ប្រសិនបើកូនបំណុលមិនបានស្វែងយល់អំពីសិទ្ធិ និងករណីយកិច្ចរបស់ខ្លួនជាមុនទេ កូនបំណុលនឹងជួបប្រទះនូវផលវិបាកដូចជា ការជំពាក់បំណុល ដែលអាចនាំឱ្យម្ចាស់បំណុលអនុវត្តសិទ្ធិស្របច្បាប់ធ្វើការរឹបអូសទ្រព្យធានាយកមកជម្រះចោលបានគ្រប់ពេល។ ដូចនេះ ករណីយកិច្ចចម្បងជាងគេរបស់កូនបំណុល គឺសងបំណុលដែលជំពាក់ទៅម្ចាស់បំណុលវិញ តាមការព្រមព្រៀងក្នុងកិច្ចសន្យា។

. **ខ.សិទ្ធិលោះមកវិញនូវទ្រព្យធានារបស់កូនបំណុល**

ទោះបីជា ទ្រព្យធានាត្រូវបានម្ចាស់បំណុលមានកិច្ចធានាអនុវត្តសិទ្ធិរឹបអូសយកមកជម្រះចោលក៏ដោយក៏បទបញ្ញត្តិនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា អនុញ្ញាតឱ្យកូនបំណុលមានសិទ្ធិលោះមកវិញនូវទ្រព្យដាក់ធានា។ ប៉ុន្តែ កូនបំណុលត្រូវតែបំពេញកាតព្វកិច្ចទាំងអស់ដែលខ្លួនបានធានាដោយទ្រព្យធានា ដូចជា ការចំណាយផ្សេងៗក្នុងកាន់កាប់ ការជួសជុល និងក្នុងការរៀបចំការជម្រះចោលនូវទ្រព្យធានាដែលបានទូទាត់ពីកូនបំណុល។[៨៨] ការលោះទ្រព្យធានានេះ គឺត្រូវធ្វើឡើងមុនពេលដែលម្ចាស់បំណុលមានកិច្ចធានា ធ្វើការជម្រះចោលនូវទ្រព្យធានា ឬចុះកិច្ចសន្យាជម្រះចោលនូវទ្រព្យធានា ឬមុនកាតព្វកិច្ចរបស់កូនបំណុលត្រូវបានរំលត់។

**៣.៣.២ កត្តាដែលមានឱ្យសិទ្ធិ និងករណីយកិច្ចរបស់គូភាគីត្រូវបានរំលត់**

ក្នុងការអនុវត្តប្រតិបត្តិការដែលមានកិច្ចធានា ផ្តោតសំខាន់ទៅលើការធានាកាតព្វកិច្ច ពោលគឺធានាថាកូនបំណុលដែលមានកិច្ចធានានឹងសង ឬបំពេញកាតព្វកិច្ចតាមការព្រមព្រងក្នុងប្រតិបត្តិការដែលមានកិច្ចធានានេះ។ ហើយការរំលត់សិទ្ធិ និងករណីយកិច្ចដែលយើងកំពុងសិក្សានៅក្នុងចំណុចនេះ គឺសំដៅទៅលើគូភាគីនៃការអនុវត្តព្រមព្រៀងគ្នាបញ្ចប់ប្រតិបត្តិការដែលមានកិច្ចធានា។ ប៉ុន្តែ កត្តាដែលឱ្យសិទ្ធិ និងករណីយកិច្ចរបស់គូភាគីត្រូវបានរំលត់គឺមានពីរធំៗ កូនបំណុលបំពេញកាតព្វកិច្ចដោយអាចសងបំណុលរួចរាល់(៣.៣.២.១) និងជួនកាលទៀតកើតចេញពី ការដែលកូនបំណុលមិនអាចអនុវត្តកាតព្វកិច្ចបាន(៣.៣.២.២)

**៣.៣.២.១ កូនបំណុលបំពេញកាតព្វកិច្ចរួចរាល់**

ជាគោលការណ៍ ភាគីនៃកិច្ចសន្យាត្រូវគោរពតាមប្បញ្ញត្តិដែលមានចែងនៅក្នុងកិច្ចសន្យា កាលបើកិច្ចសន្យានោះមានសុពលភាព និងស្របតាមទំនៀមទំលាប់ល្អរបស់ប្រទេសជាតិ។ ការបញ្ចប់កិច្ចសន្យា កើតឡើងនៅពេល ភាគីទាំងសងខាងនៃកិច្ចសន្យាបានបំពេញកាតព្វកិច្ចរបស់ខ្លួនចប់សព្វគ្រប់តាមប្បញ្ញត្តិនៃកិច្ចសន្យា។ មិនខុសប្លែកគ្នាពីកិច្ចសន្យាទូទៅទេ ប្រតិបត្តិការដែលមានកិច្ចធានា មានលក្ខណៈជាកិច្ចសន្យាមួយដែរ ដូចនេះ វានឹងបញ្ចប់ទៅតាមការព្រមព្រៀងរវាងម្ចាស់បំណុលដែលមានកិច្ចធានា និងកូនបំណុលដែលមានកិច្ចធានា។ ប្រតិបត្តិការដែលមានកិច្ចធានា ផ្តោតសំខាន់លើការធានាកាតព្វកិច្ចដោយទ្រព្យធានា មានន័យថា ប្រតិបត្តិការអាចបញ្ចប់ទៅវិញបាន នៅពេលដែលកូនបំណុលសងបំណុលរួចរាល់ ហើយទ្រព្យធានានឹងមិនស្ថិតនៅក្នុង

[៨៨] មាត្រា៥២ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

ស្ថានភាពជាទ្រព្យធានាទៀតទេ ទ្រព្យធានាប្រែក្លាយជាទ្រព្យធម្មតារបស់កូនបំណុលវិញ ដូចកាលដែលមិនទាន់ដាក់ធានា។ ទ្រព្យធានាត្រូវលុបចេញពីបញ្ជី ប្រសិនបើត្រូវបានចុះបញ្ជីនៅការិយាល័យតម្កល់លិខិតជូនដំណឹងប្រតិបត្តិការដែលមានកិច្ចធានា។ ស្ថានភាពរវាងម្ចាស់បំណុល និងកូនបំណុល ក៏គ្មានទៀតដែរ ពោលគឺគ្មានម្ចាស់បំណុល និងកូនបំណុលទៀតឡើយ។

### ៣.៣.២.២ កូនបំណុលមិនអាចអនុវត្តកាតព្វកិច្ចបាន

ក្នុងករណី កូនបំណុលដែលមានកិច្ចធានាមិនអាចសងបំណុលឱ្យទៅម្ចាស់បំណុលដែលមានកិច្ចធានា ក៏អាចបញ្ចប់ការអនុវត្តប្រតិបត្តិការដែលមានកិច្ចធានាបានដែរ។ ប៉ុន្តែ ការបញ្ចប់ដោយមិនអាចសងបំណុលបាន មិនដូចគ្នានឹងការសងបំណុល ឡើយ។ កាលណា កូនបំណុលមិនអាចសងបំណុលបាន ការបញ្ចប់ការអនុវត្តប្រតិបត្តិការដែលមានកិច្ចធានា មានដូចតទៅ៖

- ភាគីទាំងសងខាងអនុវត្តតាមការព្រមព្រៀងគ្នា ក្នុងកិច្ចសន្យាប្រាតិភោគ នូវចំណុចដែលមិនអាចសងបំណុលបាន។ ក្នុងន័យនេះ ការបញ្ចប់មានភាពខុសប្លែកគ្នាពីការព្រមព្រៀងរបស់គូភាគី។[89]
- បញ្ចប់ដោយផ្តល់សិទ្ធិឱ្យទៅម្ចាស់បំណុលអនុវត្តសិទ្ធិស្របច្បាប់ រឹបអូសជម្រះចោលនូវទ្រព្យធានា។

ការជម្រះចោលទ្រព្យធានា មានន័យថា ម្ចាស់បំណុលអាចជ្រើសរើសវិធីណាមួយក្នុងការជម្រះចោលទ្រព្យធានា ដើម្បីយកប្រាក់ដែលកូនបំណុលបានជំពាក់មកសងបំណុលខ្លួន។ នេះជាសិទ្ធិរបស់ម្ចាស់បំណុលក្នុងការជម្រះចោលទ្រព្យធានា។ ការជម្រះចោល អាចធ្វើឡើងក្នុងរូបភាពជាការលក់ ឬជួល។[90] ការលក់ ឬជួលទ្រព្យធានាអាចធ្វើមួយផ្នែក ឬទាំងស្រុង និងអាចជ្រើសរើសពេលវេលាក្នុងការជម្រះ។ ការជម្រះអាចធ្វើឡើងនៅក្នុងវេទិកាសាធារណៈ ឬឯកជន ហើយម្ចាស់បំណុលក៏អាចមានសិទ្ធិទិញទ្រព្យធានានោះបានដែរ។[91] ក្នុងការលក់ទ្រព្យធានាទៀតសោត ម្ចាស់បំណុលត្រូវគោរពតាម "ភាពសមស្របនៃគោលការណ៍ពាណិជ្ជកម្ម" ពោលគឺស្របទៅនឹងការប្រព្រឹត្ត ការគិត ដែលបុគ្គលទូទៅមានក្នុងអាជីវកម្មធម្មតានៃការលក់ប្រភេទដូចគ្នានៃទ្រព្យធានា និងជ្រើសរើសយកមកអនុវត្ត។[92] កូនបំណុលមិនអាចអះអាងថា ការលក់ទ្រព្យធានានៅកន្លែងផ្សេង ឬនៅពេលវេលាផ្សេងអាចទទួលបានតម្លៃខ្ពស់ជាងនោះទេ។[93] ប៉ុន្តែប្រសិនបើម្ចាស់បំណុល មិនគោរពតាមពេលវេលា ម្យ៉ាង

[89] មាត្រា៤៦ កថាខណ្ឌទី១ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

[90] មាត្រា៥២ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

[91] មាត្រា៤៩ កថាខណ្ឌទី៦ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

[92] មាត្រា៥៣ កថាខណ្ឌទី២ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

[93] មាត្រា៥៣ កថាខណ្ឌទី២ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

បើមានការធ្វេសប្រហែស ឬលក់ខុសពីតម្លៃទីផ្សារជាអាទិ៍ ត្រូវចាត់ទុកថារំលោភកាតព្វកិច្ចរបស់ម្ចាស់បំណុលដែលមានកិច្ចធានាចំពោះកូនបំណុល។ ពេលដែលម្ចាស់បំណុលមានកិច្ចធានាអនុវត្តសិទ្ធិក្នុងការជម្រះចោលនូវទ្រព្យធានា ម្ចាស់បំណុលត្រូវជូនដំណឹងសមស្របអំពីពេលវេលា និងទីកន្លែងដែលប្រព្រឹត្តទៅនៃការជម្រះ។ លើកលែងតែ ទ្រព្យដែលត្រូវជម្រះងាយផុយរលួយ ឬឆាប់ធ្លាក់ថ្លៃ ដែលមិនតម្រូវឱ្យម្ចាស់បំណុលជូនដំណឹងទៅកូនបំណុលនោះទេ។ [94]

ករណី ទ្រព្យធានាមួយជាកម្មវត្ថុនៃការធានាដែលមានម្ចាស់បំណុលច្រើន ហើយម្ចាស់បំណុលដទៃទៀតធ្វើលិខិតជូនដំណឹងអំពីសិទ្ធិរបស់ខ្លួន នោះម្ចាស់បំណុលដែលមានបំណងធ្វើការជម្រះ ត្រូវជូនដំណឹងដល់ម្ចាស់បំណុលដទៃទៀតមុននឹងការជម្រះចោលទ្រព្យធានា។

ចំណែកឯ ផលនៃទ្រព្យដំបូងដែលបានមកពីការជម្រះចោលទ្រព្យធានា ត្រូវយកមកទូទាត់ការចំណាយដូចជា ការរក្សាទុកទ្រព្យធានា ការរៀបចំទ្រព្យធានាសម្រាប់ការជម្រះចោល និងការចំណាយលើឯកសារច្បាប់របស់ម្ចាស់បំណុល។[95] ហើយផលនៃទ្រព្យធានាបន្ទាប់ ត្រូវយកទៅប្រើប្រាស់សម្រាប់សងបំណុលដែលមានកិច្ចធានា។ ប្រសិនបើផលនៃទ្រព្យធានាមិនគ្រប់គ្រាន់សម្រាប់សងបំណុលទេ កូនបំណុលត្រូវតែទទួលខុសត្រូវចំនួនដែលនៅសេសសល់។[96] ហើយទ្រព្យដែលនៅសេសសល់ ម្ចាស់បំណុលត្រូវប្រគល់ជូនកូនបំណុលវិញ។ ករណីបើមានម្ចាស់បំណុលដទៃទៀតធ្វើការអះអាងអំពីសិទ្ធិលើទ្រព្យធានាតែមួយ គឺត្រូវយកផលនោះទៅទូទាត់ នៅពេលម្ចាស់បំណុលដទៃទៀតបានធ្វើលិខិតជូនដំណឹងដល់ម្ចាស់បំណុលមានកិច្ចធានាតាំងពីដំបូងនៃដំណើរការជម្រះចោល ឬទទួលលិខិតជូនដំណឹងពីម្ចាស់បំណុលមានកិច្ចធានាដទៃទៀត។

ចំពោះអ្នកទិញទ្រព្យធានាវិញ ការណ៍នេះមិនជាប់សិទ្ធិប្រាតិភោគទេ ដើម្បីការពារការខាតបង់ដែលអាចកើតឡើងលើអ្នកទិញទ្រព្យធានា និងដើម្បីធានាថាតម្លៃនៃទ្រព្យធានានឹងមិនធ្លាក់ចុះ។

[94] មាត្រា៤៩ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧
[95] មាត្រា៤៩ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ច លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧
[96] មាត្រា៥០ កថាខណ្ឌទី២ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា លេខ នស/រកម/០៥០៧/០១២,២២ ឧសភា ២០០៧

# សេចក្តីសន្និដ្ឋាន

សង្គមកាន់តែជឿនលឿនតម្រូវរបស់មនុស្សក៏កាន់តែកើតឡើង ប៉ុន្តែនៅក្នុងស្ថានភាពមួយចំនួនបានធ្វើឱ្យមនុស្សមិនអាចបំពេញតម្រូវរបស់ខ្លួនបានដោយសារកត្តាជីវភាព ព្រមទាំងកត្តាផ្សេងៗផងដែរ។ គិតមកដល់សម័យកាលបដិវត្តឧស្សាហកម្ម ៤.០ រឿងទាំងនេះលែងជាបញ្ហាតទៅទៀតហើយ ដោយសារការធ្វើសមាហរណកម្មនៃជីវភាពរស់នៅរបស់បុគ្គលឯកជនពិតជាមានភាពល្អប្រសើរជាខ្លាំង ទាំងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និងច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុសុទ្ធតែមានគោលដៅ ក្នុងការជម្រុញដល់វិស័យពាណិជ្ជកម្ម ពិសេសគឺការផ្តល់ហិរញ្ញប្បទានតែម្តង។ វិធានទាំងពីរនេះសុទ្ធតែជួយសម្របសម្រួលដល់អ្នកវិនិយោគក្នុងការកាត់បន្ថយពេលវេលា ការចំណាយ និងជៀសវាងនូវនីតិវិធីវែងឆ្ងាយក្នុងការអនុវត្តសិទ្ធិ។ ដូច្នេះ បានធ្វើឱ្យអ្នកវិនិយោគ មានទំនុកចិត្តក្នុងការចំណាយប្រាក់យ៉ាងច្រើនដើម្បីផ្តល់ជាហិរញ្ញប្បទានដល់អ្នកដែលមានតម្រូវការ។ ការទទួលបានឧបករណ៍ដើម្បីដំណើរការអាជីវកម្ម និងសម្របសម្រួលដល់ជីវភាពរស់នៅប្រចាំថ្ងៃពិតជាមានភាពចាំបាច់ណាស់សម្រាប់ចរាចរទំនិញ លំហូរសាច់ប្រាក់ និងផលិតកម្ម។

ទោះបីជាមូលដ្ឋានគតិយុត្តផ្សេងគ្នាក៏ដោយ ក៏ច្បាប់ទាំងអស់សុទ្ធតែមានគុណសម្បត្តិ និងគុណវិបត្តិរាងខ្លួន។ ជាក់ស្តែងច្បាប់ស្តីពី ភតិសន្យាហិរញ្ញវត្ថុ វាមានភាពមានងាយស្រួលក្នុងការអនុវត្ត និងមានទំនុកចិត្តខ្ពស់ដល់ម្ចាស់ហិរញ្ញប្បទាន ព្រោះកម្មវត្ថុនៃកិច្ចសន្យានៅតែជាកម្មសិទ្ធិរបស់ម្ចាស់ហិរញ្ញប្បទានដដែល កត្តានេះក៏ធ្វើឱ្យខ្លួនមានភាពងាយស្រួលក្នុងការអនុវត្តសិទ្ធិទាមទារនៅពេលដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ច គ្រាន់តែវិធាននេះ មិនត្រូវបានយកមកអនុវត្តដោយបុគ្គលធម្មតានោះទេ ហើយកូនបំណុលត្រូវកាន់កាប់វត្ថុក្នុងនាមជាភតិបតីប៉ុណ្ណោះ ក្នុងអំឡុងពេលនេះកិច្ចសន្យាមិនមែនជាកម្មករនៃវត្ថុនោះទេ។ ចំណែកឯ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាវិញ ត្រូវបានអនុញ្ញាតឱ្យបុគ្គលទាំងអស់ដែលមានសមត្ថភាពតាមក្រមរដ្ឋប្បវេណី អាចជ្រើសរើសក្នុងការអនុវត្តច្បាប់នេះបានដោយមិនត្រូវបានកម្រិតនោះទេ ហើយក៏មានភាពងាយស្រួលដល់ម្ចាស់បំណុលក្នុងការភ្ជាប់សិទ្ធិប្រាតិភោគទៅលើទ្រព្យធានា សិទ្ធិប្រាតិភោគនេះត្រូវមានអានុភាពជាប់នឹងទ្រព្យធានាគ្រប់ពេលទាំងអស់ មិនថាវត្ថុនោះត្រូវបានផ្ទេរដល់បុគ្គលណាក៏ដោយ មិនតែប៉ុណ្ណោះម្ចាស់បំណុលថែមទាំងមានសិទ្ធិឃាត់ទុកទ្រព្យធានាដើម្បីជម្រះបញ្ជី ដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីតុលាការទៀតផង។ ចំណុចទាំងនេះហើយធ្វើឱ្យម្ចាស់បំណុលមានទំនុកចិត្តជាខ្លាំងក្នុងការផ្តល់ហិរញ្ញប្បទាន តាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។ ប៉ុន្តែកម្មវត្ថុនៃប្រាតិភោគជាកម្មសិទ្ធិរបស់កូនបំណុល ដូច្នេះហើយកូនបំណុលនៅតែអាចចាត់ចែងវត្ថុបាន ហើយការចាត់ចែងបែបនេះក៏អាចបង្កើតឱ្យមាននូវ បញ្ហាអាទិភាពនៃសិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុល ឬអាចធ្វើឱ្យនឹងបាត់បង់សិទ្ធិប្រាតិភោគលើទ្រព្យធានាតែម្តង ក្នុងករណីដែលម្ចាស់បំណុលមានធ្វេសប្រហែសណាមួយដូចដែលបញ្ញត្តិក្នុងច្បាប់។

សរុបមក របបគតិយុត្តមួយណាក៏ផ្តល់នូវគុណសម្បត្តិ និងគុណវិបត្តិរួមគ្នាដែរ ដូចនេះហើយវាជាបញ្ហាសម្រាប់ម្ចាស់បំណុល និងកូនបំណុលប៉ុណ្ណោះ ថាខ្លួនអាចថ្លឹងថ្លែងអំពីទម្ងន់នៃលទ្ធភាពដែលអាចធ្វើទៅបានតាមរយៈប្រតិបត្តិការទាំងពីរខាងលើ។ បូករួមជាមួយ ការដែលទទួលបានការការពារ និងការជួបប្រទះនូវផលវិបាក តាមបែបទម្រង់នៃរបបគតិយុត្តនីមួយៗ។ គួរកត់សម្គាល់ត្រង់ថា វិធាននៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា មិនទាន់ត្រូវយល់ដឹង និងផ្សព្វផ្សាយបានទូលំទូលាយនោះទេ ព្រោះវាមានភាពលំបាកក្នុងស្វែងយល់អំពីអត្ថន័យដើមដែលនីតិពន្ធចង់បង្ហាញ បើទោះបីជាមានការពន្យល់ក្នុងមាត្រា៣ក៏ដោយ ហើយដោយសារការបកប្រែពីច្បាប់បរទេស និងមិនមានអត្ថបទក្នុងស្រុកច្រើនទេដែលធ្វើការពន្យល់ ណែនាំលើប្រតិបត្តិការនីមួយៗ ដូចនេះ ទាមទារឱ្យនិស្សិតខ្លួនឯងត្រូវស្រាវជ្រាវពីប្រភពដើមនៃច្បាប់នេះដោយខ្លួនឯង។ ចំណែកឯការអនុវត្តវិញ មិនមានស្ថាប័នហិរញ្ញវត្ថុដែលមានឆន្ទៈក្នុងការផ្តល់ឥណទាន ដោយចលនវត្ថុធ្វើជាទ្រព្យធានានោះទេ ហើយការចុះបញ្ជីសិទ្ធិប្រាតិភោគលើចលនវត្ថុមានដំណើរការមិនទាន់បានល្អ ពីព្រោះតែការខ្វះខាតនូវការផ្សព្វផ្សាយជាសាធារណៈបានទូលំទូលាយ។

# អនុសាសន៍

តាមរយៈការស្រាវជ្រាវលើប្រធានបទស្តីអំពី ប្រតិបត្តិការលក់ទិញចលនវត្ថុដោយបង់រំលស់ ឃើញថាមានច្បាប់ពាណិជ្ជកម្មពិសេសចំនួនពីរដែលជាចលករជួយជម្រុញសកម្មភាពពាណិជ្ជកម្មបែបទំនើបរបស់កម្ពុជាឱ្យឈានទៅរកចំណុចមួយដែលល្អប្រសើរ។ បើទោះបីជាមានការអនុវត្តមួយចំនួនកន្លងមកក៏ដោយ ក៏វិធានទាំងពីរនេះ មិនទាន់ត្រូវបានផ្សព្វផ្សាយឱ្យទូលំទូលាយនៅឡើយ។ អាជីវករ ពាណិជ្ជករ និងមន្ត្រីមូលដ្ឋានមួយចំនួនមិនទាន់មានការយល់ច្បាស់ពីវិធានពិសេសទាំងនេះដែលធ្វើឱ្យម្ចាស់សិទ្ធិលើបំណុលមានការលំបាកក្នុងការអនុវត្តសិទ្ធិដោយខ្លួនឯងនៅពេលមានវិវាទកើតឡើង ហើយករណីមួយចំនួនធ្វើឱ្យម្ចាស់បំណុលជៀសមិនផុតពីការពឹងពាក់តុលាការ និងធ្វើឱ្យមានការអូសបន្លាយពេលវេលា ព្រមទាំងរចំណាយកើនឡើង ដែលជាកត្តាធ្វើឱ្យគោលគំនិតនៃច្បាប់ពាណិជ្ជកម្មទាំងនេះ មិនទាន់ត្រូវបានអនុវត្តឱ្យមានភាពល្អប្រសើរនោះទេ។

បន្ទាប់ពីការសិក្សាស្រាវជ្រាវរយៈពេលកន្លងមកនេះ យើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើនពីច្បាប់ពិសេសបែបទំនើបរបស់កម្ពុជាទាំងពីរខាងលើ ប៉ុន្តែទន្ទឹមនឹងការទទួលបាន យើងខ្ញុំទាំងពីរនាក់ក៏បានជួបប្រទះការលំបាកមួយចំនួនផងដែរ ជាពិសេសគឺវិធាននៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ដែលក្នុងនោះមានដូចជា៖

- ការខ្វះខាតនូវឯកសារក្នុងការស្រាវជ្រាវ ដោយការស្រាវជ្រាវនេះស្ថិតក្នុងស្ថានភាពនៃការរីករាលជំងឺកូវីដ១៩ នៅប្រទេសកម្ពុជា ធ្វើឱ្យគ្រឹះស្ថានអប់រំ និងកន្លែងមួយចំនួនត្រូវបានបិទ។ វាបានធ្វើឱ្យយើងមិនអាចស្រាវជ្រាវឯកសារនៅតាមបណ្ណាល័យ និងសូមការអនុញ្ញាតចុះស្រាវជ្រាវនៅតាមស្ថាប័នផ្សេងៗដោយផ្ទាល់បានទេ។ ជាមួយគ្នានោះដែរ ច្បាប់នេះមិនត្រូវបានអនុវត្តទូលំទូលាយដូចក្រមរដ្ឋប្បវេណីឡើយ ដែលប្រតិបត្តិការភាគច្រើនអនុវត្តតែក្នុងការិយាល័យច្បាប់មួយចំនួនប៉ុណ្ណោះម្យ៉ាងទៀតឯកសារទាំងនោះ យើងមិនអាចដកយកមកសិក្សាជាសាធារណៈបាននោះទេព្រោះវាប៉ះពាល់ដល់សិទ្ធិឯកជនរបស់អតិថិជន។
- ការខ្វះខាតមូលដ្ឋានគ្រឹះចំណេះដឹងពីសាកលវិទ្យាល័យដោយហេតុថា ច្បាប់នេះមិនត្រូវបានបញ្ចូលក្នុងកម្មវិធីសិក្សានៅឡើយ ហើយក៏មិនសូវមានកម្មវិធីផ្សព្វផ្សាយច្បាប់ណាលើកយកប្រធានបទខាងលើមកបង្ហាត់បង្ហាញផងដែរ។ ហេតុនេះ ដើម្បីឱ្យវិធានគតិយុត្តដ៏មានតម្លៃខាងលើបានចូលខ្លួនមកបម្រើ និងជួយជម្រុញដល់ការអភិវឌ្ឍផ្នែកសេដ្ឋកិច្ចចំពោះ បុគ្គលឯកជន និងសង្គមទាំងមូលបានពេញលេញ យើងខ្ញុំសូមផ្តល់ជាការសំណូមពរមួយចំនួនដូចជា៖

១. សំណូមពរសូមឱ្យមានការចូលរួមពីគ្រប់ស្ថាប័នដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងផ្សព្វផ្សាយនូវវិធានពិសេសទាំងពីរខាងលើឱ្យបានទូលំទូលាយជាងមុន ដើម្បីជាបច្ច័យក្នុងការចូលរួមចែករំលែកនូវចំណេះដឹងឱ្យ

បានកាន់តែច្រើនបន្ថែមទៀតដល់ សិស្ស និស្សិត ពលរដ្ឋ ពាណិជ្ជករ បុគ្គលធនាគារ និង អាជ្ញាធរថ្នាក់ក្រោមជាដើម។ ព្រោះវាពិតបានជួយជម្រុញវិស័យសេដ្ឋកិច្ច និងដឹកនាំការរស់នៅរបស់ប្រជាពលរដ្ឋឱ្យទៅឱ្យទំនើបកម្ម កាលណាដែលសង្គមមានការយល់ដឹងច្បាស់លាស់អំពីវិសាលភាព និងការប្រើប្រាស់បទដ្ឋានទាំងនេះ។

២. សំណូមពរដល់អាជ្ញាធរគួរគប្បីយកចិត្តទុកដាក់ចំពោះការកំណត់ឱ្យបានច្បាស់លាស់ពីវិសាលភាពនៃច្បាប់ និងបង្កើតនូវការយល់ដឹងនូវលក្ខណៈពិសេសនៃវិធានពាណិជ្ជកម្មបែបទំនើបទាំងពីរនេះ ជាពិសេសគួរបង្កើតនូវនីតិវិធីអនុវត្តដោយឡែក ដោយធានានូវដំណើរការនីតិវិធីដែលឆាប់រហ័ស និងមានលក្ខណៈអាចបត់បែនបានគ្រប់ពេល ដោយធ្វើយ៉ាងណាកុំឱ្យប្រើប្រាស់ផ្លូវតុលាការ។

៣. សំណូមពរដល់ក្រសួងមានសមត្ថកិច្ចដូចជា ក្រសួងពាណិជ្ជកម្ម ក្រសួងយុត្តធម៌ គប្បីពិចារណាក្នុងការតាក់តែងនីតិវិធីពិសេស ក្រោមរូបភាពជាច្បាប់ ឬប្រកាសអន្តរក្រសួងសម្រាប់ធ្វើការណែនាំលើការអនុវត្តសិទ្ធិឱ្យកាន់តែច្បាស់លាស់ សមស្របទៅនឹងគោលគំនិតនៃការបង្កើតរបបគតិយុត្តនេះផងដែរ។

# គន្ថនិទ្ទេស

## I. បទដ្ឋានគតិយុត្ត

### ច្បាប់

១. រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

២. ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/ រកម/ ០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

៣. ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/ រកម/ ១២០៧/ ០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧។

៤. ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ប្រកាសប្រើឱ្យដោយព្រះរាជក្រមលេខ នស/ រកម/ ០៥០៧/ ០១២ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៧។

៥. ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/ រកម/ ០៥១១/ ០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១។

៦. ច្បាប់ស្តីពី ភតិសន្យាហិរញ្ញវត្ថុ ឆ្នាំ២០០៩ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រតម/ ០៦០៩/០០៨ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៩។

### អនុក្រឹត្យ

១. អនុក្រឹត្យលេខ ១៣១ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងពាណិជ្ជកម្ម។

### ប្រកាស

១. ប្រកាសអន្តរក្រសួងស្តីពីកម្រៃសេវាតម្កល់ និងស្រាវជ្រាវរកលិខិតលេខ ៨២៥ សហវប្រក.ចមព ចុះថ្ងៃទី០៣ កញ្ញា ឆ្នាំ២០០៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ជូនដំណឹង នៃប្រតិបត្តិការណ៍មានដែលកិច្ចធានា។

២. ប្រកាសស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ លេខ ធ៧-០១១-២៥២ ប្រ.ក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១។

៣. ប្រកាសស្តីពី អាជីវកម្មភតិសន្យាហិរញ្ញវត្ថុ លេខធ៧-០១១-២៤១ ប្រ.ក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០១១។

៤. ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ០២៨ សហវប្រក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ ២០១០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួល ប្រាតិភោគដោយអនុប្បទាន។

**សេចក្តីជូនដំណឹង**

១. សេចក្តីជូនដំណឹង លេខ ៣០៥៨ ព.ណនតក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ របស់ក្រសួងពាណិជ្ជកម្ម ស្តីពីការតម្កល់លិខិតជូនដំណឹង នៃប្រតិបត្តិការដែលមានកិច្ចធានា និងការស្រាវជ្រាវរកកំណត់ត្រាតាមមធ្យោបាយអេឡិចត្រូនិច។

## II. បទដ្ឋានគតិយុត្តអន្តរជាតិ

១. Uniform Commercial Code of United States, Article 9.

## III. ឯកសារពិគ្រោះ

១. ក្រសួងពាណិជ្ជកម្ម, ការអភិវឌ្ឍវិស័យពាណិជ្ជកម្ម និងជំនួយពាណិជ្ជកម្មនៅប្រទេសកម្ពុជា ២០១១។

២. សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី រៀបរៀងដោយគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី ឆ្នាំ២០១១។

៣. សេចក្តីកំណត់ចំពោះមាតិកានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៤៖ គន្ថីទី៦, រៀបចំដោយគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាង ក្រមរដ្ឋប្បវេណី, ក្រសួងយុត្តិធម៌, ឆ្នាំ២០០៩។

៤. សេចក្តីកំណត់ចំពោះមាតិកានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ១៖ គន្ថីទី១ ដល់គន្ថីទី៣ រៀបចំដោយគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, ក្រសួងយុត្តិធម៌, ឆ្នាំ២០០៩។

៥. សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ១ និងភាគ២ ដែលរៀបរៀងដោយក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាល នៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការខែមេសា ឆ្នាំ២០១៣។

៦. គណៈកម្មាការទទួលបន្ទុកកិច្ចការផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណីកម្ពុជា និងក្រុមការងារ

ជប៉ុនទទួលបន្ទុករៀបចំសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, ភ្នំពេញ៖ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន , ឆ្នាំ២០១១។

៧. ធនាគារអភិវឌ្ឍន៍អាស៊ី (Asia Development Bank, ADB), សៀវភៅស្តីពី "ការពន្យល់ និងឧទាហរណ៍នៃប្រតិបត្តិការដែលមានកិច្ចធានា", ឯសារបណ្តុះបណ្តាល, ភ្នំពេញ៖ ក្រសួងពាណិជ្ជកម្ម។

៨. សៀវភៅមេរៀន "នីតិប្រាតិភោគ" លោកស្រី សាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១៣។

៩. មេរៀនសង្ខេបស្តីពី "សិទ្ធិប្រាតិភោគប្រត្យក្ស" រៀបរៀងដោយ លោកមេធាវី អ៊ីវ ប៉ូលី។

១០. វចនានុក្រមសម្តេចព្រះសង្ឃរាជ្យ ជួន ណាត បោះពុម្ពក្នុងឆ្នាំ១៩៦៧។

១១. ព្រឹត្តិបត្រមេធាវី ត្រីមាសទី៣ លេខ១៤ ខែកក្កដា-កញ្ញា ឆ្នាំ២០១៧ ប្រធានបទ ភតិសន្យាហិរញ្ញវត្ថុ ដោយលោកមេធាវី កុយ គន្ធី។

## IV. គេហទំព័រ

១. Khmer - Welcome to Secured Transactions Registry (setfo.gov.kh)

២. https://t.me/KubotaLeasingCambodiaGroup

៣. https://www.facebook.com/ttfc.kh/

៤. Toyota Cambodia | Leasing price

៥. ស៊ីអាយអិមប៊ីខេ (cimbbank.com.kh)

៦. Kubota Leasing (Cambodia) Plc. - EuroCham Cambodia (eurocham-cambodia.org)

**បញ្ជីរាយនាមឧបសម្ព័ន្ធ**

| ល.រ | ឈ្មោះឧបសម្ព័ន្ធ |
|---|---|
| ១. | ប្រកាសស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ |
| ២. | គម្រូតារាង បង់រំលស់របស់ក្រុមហ៊ុន តូយ៉ូតាកម្ពុជាហ្វាយនែន |
| ៣. | បញ្ជីរាយនាមគ្រឹះស្ថានភតិសន្យាហិរញ្ញវត្ថុ ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅកម្ពុជា |
| ៤. | កិច្ចព្រមព្រៀងប្រាតិភោគ |
| ៥. | ការពិពណ៌នាពីលក្ខណៈនៃទ្រព្យសម្បត្តិ |
| ៦. | លំហូរនីតិវិធីនៃការបង្កើតប្រតិបត្តិការដែលមានកិច្ចធានា |
| ៧. | តារាងនៃប្រតិបត្តិការដែលធ្វើសុក្រឹត្យកម្ម |
| ៨. | គម្រូលិខិតជូនដំណឹង |
| ៩. | គម្រូលិខិតសុំកែតម្រូវលិខិតជូនដំណឹង |
| ១០. | គម្រូលិខិតសុំបញ្ចប់លិខិតជូនដំណឹង |
| ១១. | អាស័យដ្ឋានការិយាល័យតម្កល់លិខិតជូនដំណឹង |

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

# ប្រកាសស្តីពី ការផ្តល់អាជ្ញាបណ្ណចំពោះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ

ធ៧-០១១-២៤២ ប្រ.ក

# ប្រកាស
# ស្តីពី
# ការផ្តល់អាជ្ញាបណ្ណចំពោះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ

---

## សម្រេច
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលបំណង

ប្រកាសនេះ មានគោលបំណងបង្កើត លើកកម្ពស់ និងអភិវឌ្ឍវិស័យភតិសន្យាហិរញ្ញវត្ថុនៅកម្ពុជា ដើម្បីពង្រឹងការត្រួតពិនិត្យនិងគ្រប់គ្រងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ដោយកំណត់លក្ខខណ្ឌក្នុងការផ្តល់អាជ្ញាបណ្ណនិងដាក់បទប្បញ្ញត្តិចំពោះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ។

### ប្រការ ២.- វិសាលភាព

ប្រកាសនេះ គ្របដណ្តប់លើប្រតិបត្តិការរបស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុនៅព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ជាគ្រឹះស្ថានដែលធ្វើតែអាជីវកម្មភតិសន្យាហិរញ្ញវត្ថុប៉ុណ្ណោះ។

### ប្រការ ៣.- ដើមទុនចុះបញ្ជី

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ត្រូវមានដើមទុនចុះបញ្ជីអប្បបរមាចំនួន ២០០.០០០.០០០ រៀល (ពីររយលានរៀល) ហើយដើមទុនចុះបញ្ជីនេះត្រូវតែជាដើមទុនបង់ជម្រះ។

## ជំពូកទី ២
## នីតិវិធីនៃការដាក់ពាក្យសុំអាជ្ញាបណ្ណ

### ប្រការ ៤.- ការដាក់ពាក្យសុំអាជ្ញាបណ្ណ

១. គ្មានបុគ្គលណាម្នាក់ ទោះជារូបវន្តបុគ្គល ឬនីតិបុគ្គល ត្រូវបានអនុញ្ញាតឲ្យធ្វើអាជីវកម្មភតិសន្យាហិរញ្ញវត្ថុ ដោយគ្មានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជាឡើយ។

២. ពាក្យសុំអាជ្ញាបណ្ណត្រូវធ្វើឡើងដោយបុគ្គល ដែលមានសិទ្ធិអំណាចនៅក្នុងក្រុមហ៊ុន (នាយកគ្រប់គ្រង ឬបុគ្គលដែលត្រូវបានផ្តល់សិទ្ធិអំណាច) និងបង្ហាញព័ត៌មានដូចខាងក្រោម៖

- ក. កិច្ចព្រមព្រៀងចូលភាគហ៊ុន ឬកិច្ចព្រមព្រៀងរបស់ភាគទុនិក
- ខ. នាម ឬនាមករណ៍របស់ក្រុមហ៊ុន
- គ. អាសយដ្ឋាននៃទីស្នាក់ការកណ្តាល ឬសាខានៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងករណីជាសាខាក្រុមហ៊ុនបរទេស
- ឃ. រូបភាពគតិយុត្ត និងលក្ខន្តិកៈរបស់ក្រុមហ៊ុន ឬឯកសារផ្សេងទៀត
- ង. ប្រភេទមូលបត្រតំណាងឲ្យដើមទុន និងទំនាក់ទំនងរវាងការកាន់កាប់មូលបត្រ និងការអនុវត្តសិទ្ធិបោះឆ្នោត

ច. ចំនួនទឹកប្រាក់នៃភាគហ៊ុនដែលបានបោះផ្សាយ និងដើមទុនបង់ជម្រះ
ឆ. ការបែងចែងភាគហ៊ុន សិទ្ធិបោះឆ្នោត និងកិច្ចព្រមព្រៀង ដែលអាចមានរវាងភាគទុនិកដែលធ្វើសកម្មភាពក្នុងការដឹកនាំគោលនយោបាយរបស់ក្រុមហ៊ុន
ជ. ភាគទុនិកដែលកាន់កាប់៥% (ប្រាំភាគរយ) នៃសិទ្ធិបោះឆ្នោត ឬលើស ត្រូវផ្តល់ព័ត៌មានដូចមាន រៀបរាប់នៅក្នុងប្រការ ១៣ នៃប្រកាសនេះ។
ឈ. អត្តសញ្ញាណរបស់បុគ្គលយ៉ាងតិច១រូប (មួយរូប) ដែលទទួលខុសត្រូវក្នុងការដឹកនាំប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុន។ បុគ្គលនោះត្រូវផ្តល់ព័ត៌មានតាមឧបសម្ព័ន្ធ២ ព្រមទាំងមានបញ្ជាក់លិខិតថ្កោលទោសមួយច្បាប់ផង
ញ. អត្តសញ្ញាណរបស់បុគ្គលទទួលខុសត្រូវក្នុងការចេញសេចក្តីសម្រេច។ បុគ្គលនោះត្រូវបំពេញប្រវត្តិរូប និងបញ្ជាក់ថាខ្លួនមិនត្រូវបានហាមឃាត់នៅក្នុងប្រការ១៤នៃប្រកាសនេះទេ។ បុគ្គលនោះត្រូវមានបទពិសោធន៍ពាក់ព័ន្ធនឹងអាជីវកម្មភតិសន្យានិងឥណទានយ៉ាងតិច៣ឆ្នាំ (បីឆ្នាំ)
ដ. ប្រសិនបើនីតិបុគ្គល ដែលបានដាក់ពាក្យស្នើសុំអាជ្ញាបណ្ណនេះ ជាក្រុមហ៊ុនដែលបានបង្កើតរួចហើយ ក្រុមហ៊ុនត្រូវផ្តល់ព័ត៌មានអំពីអាជីវកម្ម ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុបញ្ជាក់ដោយស្នងការគណនី សម្រាប់ប្រតិបត្តិការរយៈពេល៣ឆ្នាំ (បីឆ្នាំ)
ឌ. ភស្តុតាងសមស្របផ្សេងទៀត ដូចជា៖
- ដំណើរការគ្រប់គ្រងហានិភ័យ ដូចជា ការកំណត់អត្តសញ្ញាណ ការវាស់វែង ការតាមដាន និងត្រួតពិនិត្យហានិភ័យ
- ផែនការគ្រប់គ្រង៖
    - ហានិភ័យសន្ទនីយភាព អត្រាការប្រាក់ និងកាលវសាន្ត (ការគ្រប់គ្រងទ្រព្យសកម្ម និងទ្រព្យអកម្ម)
    - ហានិភ័យឥណទាន
    - ហានិភ័យប្រតិបត្តិការ
    - ហានិភ័យទីផ្សារ
    - ហានិភ័យទ្រព្យសកម្ម
    - ហានិភ័យឯកសារ (Documentation Risk)
    - ហានិភ័យប្រមូលផ្តុំ (Concentration Risk)
    - ហានិភ័យដទៃទៀត ដែលអាចកើតមានចំពោះក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុនៅពេលធ្វើប្រតិបត្តិការភតិសន្យាតាមផែនការអាជីវកម្ម។

**ប្រការ ៥.- សំណើសុំផ្លាស់ប្តូរព័ត៌មាន**

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវជូនដំណឹងដល់ធនាគារជាតិនៃកម្ពុជា ដូចជា៖
ក . ការផ្លាស់ប្តូរនាមករណ៍
ខ. ការផ្លាស់ប្តូរទម្រង់ក្រុមហ៊ុន
គ. ការកែប្រែវិសាលភាពអាជីវកម្ម
ឃ .ការផ្លាស់ប្តូរដើមទុនចុះបញ្ជី

ង. ការកែប្រែលក្ខន្តិកៈ

ច. ការផ្លាស់ប្តូរទីតាំងអាជីវកម្ម

ឆ. ការផ្លាស់ប្តូរអភិបាល ឬអ្នកគ្រប់គ្រងជាន់ខ្ពស់

ជ. ការរួមបញ្ចូល ឬការបែងចែកឬ

ឈ.បញ្ហាផ្សេងទៀតដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

## ជំពូកទី ៣
## អនុមតិផ្តល់អាជ្ញាបណ្ណ និង ការយកកំរៃ

### ប្រការ ៦.- ការផ្តល់លិខិតអនុញ្ញាតជាគោលការណ៍

ធនាគារជាតិនៃកម្ពុជា នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសេចក្តីសម្រេចរបស់ខ្លួន ក្នុងរយៈពេល ៣ខែ(បីខែ) ចាប់ពីពេលបានទទួលពាក្យស្នើសុំពេញលេញ។ ក្នុងករណីចាំបាច់ ធនាគារជាតិនៃកម្ពុជានឹងដាក់លក្ខខណ្ឌ និងរយៈពេលនៃការអនុវត្តលិខិតអនុញ្ញាត។ ប្រសិនបើពុំបានអនុវត្តតាមពេលវេលាកំណត់ ឬពុំបានសុំពន្យារពេល លិខិតអនុញ្ញាតនោះត្រូវចាត់ទុកជាមោឃៈ។

### ប្រការ៧.- អនុមតិផ្តល់អាជ្ញាបណ្ណ

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវបំពេញគ្រប់លក្ខខណ្ឌដែលមានចែងក្នុងលិខិតអនុញ្ញាតជាគោលការណ៍ជាមុនសិន មុននឹងទទួលបានអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា។

### ប្រការ៨.- សុពលភាពនៃអាជ្ញាបណ្ណ

អាជ្ញាបណ្ណរបស់ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមានសុពលភាពរយៈពេល៥ឆ្នាំ (ប្រាំឆ្នាំ) ហើយអាចសុំបន្តជាថ្មីទៀតបាន។

### ប្រការ៩.- សោហ៊ុយសិក្សាឯកសារ និងសោហ៊ុយអាជ្ញាបណ្ណ

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវបង់សោហ៊ុយសិក្សាឯកសារចំនួន ៥០០.០០០ រៀល (ប្រាំរយពាន់រៀល) នៅពេលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជា។

សោហ៊ុយអាជ្ញាបណ្ណប្រចាំឆ្នាំត្រូវបង់មុនថ្ងៃទី១៥ ខែមករា រៀងរាល់ឆ្នាំដូចខាងក្រោម៖

- ៤.០០០.០០០រៀល (បួនលានរៀល) សម្រាប់ស្នាក់ការកណ្តាល
- ២.០០០.០០០រៀល (ពីរលានរៀល) ក្នុងមួយសាខា។

សម្រាប់ក្រុមហ៊ុនដែលបង្កើតនៅក្នុងឆ្នាំ សោហ៊ុយអាជ្ញាបណ្ណត្រូវបង់តាមសមាមាត្រនៃរយៈពេលដែលនៅសល់រហូតដល់ដំណាច់ឆ្នាំ។

## ជំពូកទី ៤
## និធានប្រុងប្រយ័ត្ន

### ប្រការ១០.- ការបង់ដើមទុន

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវបង់ជម្រះ ១០០% (មួយរយភាគរយ) នៃដើមទុនចុះបញ្ជីទៅក្នុងគណនីដែលបានបើកនៅធនាគារជាតិនៃកម្ពុជា មុនពេលចាប់ផ្តើមប្រតិបត្តិការ។

ក្រុមហ៊ុនត្រូវតម្កល់ប្រាក់ចំនួន៥% (ប្រាំភាគរយ) នៃដើមទុនចុះបញ្ជី ដោយគ្មានការប្រាក់នៅក្នុងគណនីអចិន្ត្រៃយ៍នៅធនាគារជាតិនៃកម្ពុជា។

ធនាគារជាតិនៃកម្ពុជានឹងប្រគល់ប្រាក់តម្កល់ឲ្យក្រុមហ៊ុនវិញ តែក្នុងករណីជម្រះបញ្ជី និងគ្មានបំណុល។

### ប្រការ ១១.- កាតព្វកិច្ចរាយការណ៍

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវអនុវត្តតាមកាតព្វកិច្ចរាយការណ៍ ដូចខាងក្រោម :

១. ក្រុមហ៊ុនត្រូវបង្ហាញព័ត៌មាន ស្របតាមស្តង់ដារគណនេយ្យសម្រាប់អាជីវកម្មសហគ្រាស និងបញ្ញត្តិនានារបស់ធនាគារជាតិនៃកម្ពុជា។

២. ក្រុមហ៊ុនត្រូវរៀបចំរបាយការណ៍តុល្យការ របាយការណ៍ចំណូលនិងចំណាយ និង របាយការណ៍ដទៃទៀតតាមតម្រូវការរបស់អាជ្ញាធរត្រួតពិនិត្យ។ តំណាងស្របច្បាប់ និងអ្នកទទួលខុសត្រូវដទៃទៀតនៃក្រុមហ៊ុន ត្រូវទទួលខុសត្រូវចំពោះភាពត្រឹមត្រូវនៃរបាយការណ៍ទាំងអស់។

៣. ក្រុមហ៊ុនត្រូវផ្ញើរបាយការណ៍ប្រចាំខែមកធនាគារជាតិនៃកម្ពុជា ក្នុងរយៈពេល១៥ថ្ងៃ (ដប់ប្រាំថ្ងៃ) ដំបូងនៃខែបន្ទាប់។

៤. ក្រុមហ៊ុនត្រូវផ្ញើរបាយការណ៍សវនកម្មប្រចាំឆ្នាំ បញ្ជាក់ដោយសវនករដែលបានទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា ក្នុងរយៈពេល៤ខែ (បួនខែ) ដំបូងនៃឆ្នាំបន្ទាប់។

### ប្រការ ១២.- បទប្បញ្ញត្តិប្រុងប្រយ័ត្ន

ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុត្រូវអនុវត្តតាមបទប្បញ្ញត្តិប្រុងប្រយ័ត្ននានា ដែលចេញដោយធនាគារជាតិនៃកម្ពុជា។

## ជំពូកទី ៥
## រចនាសម្ព័ន្ធភាគហ៊ុន និងអភិបាលកិច្ច

### ប្រការ ១៣.- ភាគទុនិក

ភាគទុនិកត្រូវផ្តល់ព័ត៌មានមកធនាគារជាតិនៃកម្ពុជាដូចខាងក្រោម៖

១. អត្តសញ្ញាណនៃភាគទុនិក :

ក. ក្នុងករណីជានីតិបុគ្គល ត្រូវផ្តល់នាមករណ៍អាជីវកម្ម រូបភាពគតិយុត្ត អាសយដ្ឋាននៃស្នាក់ការកណ្តាល របាយការណ៍សវនកម្មហិរញ្ញវត្ថុ លក្ខន្តិកៈ និងព័ត៌មានផ្សេងទៀតដែលតម្រូវដោយអាជ្ញាធរត្រួតពិនិត្យ

ខ. ក្នុងករណីជារូបវន្តបុគ្គល ត្រូវរៀបរាប់ គោត្តនាម នាម ទីកន្លែង និងថ្ងៃខែឆ្នាំកំណើត សញ្ជាតិ អាសយដ្ឋាន និងឯកសារពាក់ព័ន្ធផ្សេងទៀត។

២. ភាគរយនៃភាគហ៊ុនដែលកាន់កាប់ និងភាគរយនៃសិទ្ធិបោះឆ្នោត ដោយរៀបរាប់លំអិតអំពីនីតិវិធីនៃការទិញភាគហ៊ុន។ ប្រសិនបើភាគទុនិកជាឯកត្តជន ត្រូវបញ្ជាក់ច្បាស់លាស់ពីប្រភពដើមនៃទុនវិនិយោគ។

៣. ការបញ្ជាក់ពីចំនួនភាគរយនៃភាគហ៊ុនដែលកាន់កាប់ដោយភាគទុនិកម្នាក់ៗ ក្នុងករណីចាំបាច់ភាគទុនិកត្រូវ :

ក. រៀបរាប់អំពីការបែងចែកភាគហ៊ុនរបស់ក្រុមហ៊ុនមេ និងក្រុមហ៊ុនហូលឌីង (Intermediate Holding Companies) ដោយផ្តល់ជាភាគរយនៃភាគហ៊ុន និងសិទ្ធិបោះឆ្នោត

ខ. ធ្វើបញ្ជីអ្នកគ្រប់គ្រងសំខាន់ៗដែលជាភាគទុនិក។

៤. ប្រសិនបើភាគទុនិកនោះជាផ្នែកនៃសម្ព័ន្ធមួយ ភាគទុនិកត្រូវ៖

ក. រៀបរាប់អំពីក្រុមហ៊ុនសំខាន់ៗនៃសម្ព័ន្ធនោះ រួមជាមួយអង្គការលេខផង

ខ. បញ្ជាក់អំពីចំនួនភាគហ៊ុននៅក្នុងគ្រឹះស្ថានឥណទានផ្សេងទៀត ទាំងនៅក្នុងប្រទេស និងនៅបរទេស។

៥. ចំណងទាក់ទងរវាងភាគទុនិក និងក្រុមហ៊ុនដែលមានសកម្មភាពហិរញ្ញវត្ថុ ដូចជា ធនាគារ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

៦. នីតិវិធីសវនកម្មផ្ទៃក្នុង និងសវនកម្មខាងក្រៅរបស់ភាគទុនិក។

៧. សាវតារនៃអំពើល្មើសរបស់ភាគទុនិកក្នុងរយៈពេល១០ឆ្នាំ (ដប់ឆ្នាំ)កន្លងមក ប្រសិនបើមាន។

៨. គោលដៅរបស់ភាគទុនិកក្នុងការដាក់បញ្ចូលដើមទុនផ្ទាល់ទៅក្នុងក្រុមហ៊ុន ដែលបានដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ និងផ្តល់ព័ត៌មានដែលពាក់ព័ន្ធ។

៩. ទំនាក់ទំនងអាជីវកម្មសំខាន់ៗរវាងភាគទុនិក និងអ្នកដាក់ពាក្យស្នើសុំ។

១០. ទំនាក់ទំនងអាជីវកម្មសំខាន់ៗខាងភតិសន្យាហិរញ្ញវត្ថុរបស់ភាគទុនិកនៅព្រះរាជាណាចក្រកម្ពុជា។

១១. គណនីរបស់ភាគទុនិក ឬក្រុមហ៊ុនមេរបស់ខ្លួន សំរាប់រយៈពេល៣ឆ្នាំ (បីឆ្នាំ)ចុងក្រោយព្រមទាំងព្យាករណ៍សំរាប់ឆ្នាំនេះ (រួមមានព័ត៌មានតួបសរុបផង ប្រសិនបើមាន)។ ក្នុងករណីភាគទុនិកជាគ្រឹះស្ថានហិរញ្ញវត្ថុ ត្រូវផ្តល់ព័ត៌មានពីអនុបាតប្រុងប្រយ័ត្នសំខាន់ៗ។

១២. អភិបាលកិច្ចក្រុមហ៊ុន (រចនាសម្ព័ន្ធចាត់តាំង សន្និបាតប្រចាំឆ្នាំរបស់ភាគទុនិក ក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាត្រួតពិនិត្យ និងនាយកជាន់ខ្ពស់) ដោយបែងចែកភារកិច្ចឲ្យបានច្បាស់លាស់ ធានាប្រតិបត្តិការដោយឯករាជ្យ និងប្រព័ន្ធត្រួតពិនិត្យមានតម្លាភាព ព្រមទាំងបង្កើតយន្តការគោលនយោបាយប្រកបដោយប្រសិទ្ធភាព យន្តការលើកទឹកចិត្ត និងរក្សាបុគ្គលិក។

១៣. គោលនយោបាយ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

### ប្រការ ១៤.- សមត្ថភាពរបស់សមាជិកក្រុមប្រឹក្សាភិបាល និងនាយក

បុគ្គលណាក៏មិនអាចជាសមាជិកក្រុមប្រឹក្សាភិបាល ឬក្រុមប្រឹក្សាត្រួតពិនិត្យ ឬនាយករបស់ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណ ឬដឹកនាំ គ្រប់គ្រង ឬដំណើរការក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណដោយផ្ទាល់ ឬតាមរយៈអន្តរការីក្នុងទម្រង់ណាក៏ដោយ ឬត្រូវបានផ្តល់សិទ្ធិចុះហត្ថលេខាក្នុងនាមក្រុមហ៊ុន ប្រសិនបើរូបវន្តបុគ្គលនោះ៖

១. ត្រូវបានផ្តន្ទាទោសពីបទៈ

- ឧក្រិដ្ឋកម្ម
- ចោរកម្ម ឆបោក ឬរំលោភលើការទុកចិត្ត
- គ្រប់គ្រងមិនបានត្រឹមត្រូវក្នុងតួនាទីខ្លួនជាអ្នករក្សាប្រាក់បញ្ញើ
- គែបន្លំមូលនិធិ ឬមូលបត្រ ឬក្បាលធន
- ធ្វើព្រឹទ្ធិកម្ម

- ការសម្អាតប្រាក់
- ក្លែងបន្លំ/និងប្រើលិខិតឯកជន ឬសាធារណៈក្លែងក្លាយ។

២. ត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារពីបទចេញមូលប្បទានបត្រគ្មានសាច់ប្រាក់។

៣. ត្រូវបានផ្ដន្ទាទោសជាស្ថាពរនៅបរទេសពីបទឧក្រិដ្ឋ ឬមជ្ឈិម ដែលមានចែងនៅក្នុងចំណុច១ និង២ ខាងលើ។

៤. ត្រូវបានផ្ដន្ទាទោសនៅព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេសពីបទក្ស័យធន ឬការជម្រះបំណុលតាមផ្លូវតុលាការ ឬការជម្រះទ្រព្យសម្បត្តិ។

៥. ត្រូវរងវិធានការតាមផ្លូវតុលាការ ដោយការតម្លោះយសពីមុខងារសាធារណៈ។

៦. ត្រូវបានទទួលរងទណ្ឌកម្មខាងវិន័យក្នុងការគ្រប់គ្រងគ្រឹះស្ថានចំណុះច្បាប់នេះ ដែលអាជ្ញាបណ្ណត្រូវបានដកហូត។

សមាជិកក្រុមប្រឹក្សាភិបាល និងនាយកដែលត្រូវបានតែងតាំង ត្រូវផ្ដល់ព័ត៌មានដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ២ នៃប្រកាសនេះ។

## ជំពូកទី ៦
## វិធានការ និង ការពិន័យ

### ប្រការ ១៥.- សិទ្ធិអំណាចរបស់អាជ្ញាធរត្រួតពិនិត្យ

១. ធនាគារជាតិនៃកម្ពុជាមានសិទ្ធិអំណាចក្នុងការផ្ដល់ ព្យួរ ដកហូតអាជ្ញាបណ្ណ ដាក់បទប្បញ្ញត្តិ បទបញ្ជា និងការណែនាំសម្រាប់ត្រួតពិនិត្យ អាជីវកម្មរបស់ក្រុមហ៊ុន តាមការចាំបាច់។

២. ធនាគារជាតិនៃកម្ពុជាអាចព្យួរ ឬដកហូតអាជ្ញាបណ្ណ ដោយផ្អែកលើមូលហេតុមួយ ឬច្រើន ដូចខាងក្រោម:

ក. ក្រុមហ៊ុនមិនបានចាប់ផ្ដើមអាជីវកម្មក្នុងកំឡុងពេលបីខែ បន្ទាប់ពីទទួលបានអាជ្ញាបណ្ណ

ខ. ក្រុមហ៊ុនបំពានច្បាប់ ឬបទប្បញ្ញត្តិ ដែលគ្រប់គ្រងលើប្រតិបត្តិការក្រុមហ៊ុន

គ. ក្រុមហ៊ុនមិនអាចប្រកបអាជីវកម្មភតិសន្យាហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព

ឃ. ក្រុមហ៊ុនផ្អាកអាជីវកម្មភតិសន្យាហិរញ្ញវត្ថុនៅព្រះរាជាណាចក្រកម្ពុជា

ង.ក្រុមហ៊ុនស្ម័គ្រចិត្តបញ្ឈប់ប្រតិបត្តិការ បន្ទាប់ពីទទួលបានការយល់ព្រមពីអាជ្ញាធរត្រួតពិនិត្យ

ច. ក្រុមហ៊ុនអសាធនភាព ឬក្ស័យធន ឬស្ថិតក្នុងដំណើរការជម្រះបញ្ជី ឬក្នុងដំណាក់កាលតែងតាំងអភិបាលបណ្ដោះអាសន្នតាមផ្លូវតុលាការ។

**ប្រការ ១៦.- វិធានការចំពោះក្រុមហ៊ុន**

១. ក្នុងករណីក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុបានប្រព្រឹត្តល្មើសនឹងច្បាប់ភតិសន្យាហិរញ្ញវត្ថុ ឬបទប្បញ្ញត្តិជាធរមាន ធនាគារជាតិនៃកម្ពុជានឹងដាក់ទណ្ឌកម្មខាងវិន័យចំពោះក្រុមហ៊ុននោះយោងតាមមាត្រា ៣៥ នៃច្បាប់ស្តីពីភតិសន្យាហិរញ្ញវត្ថុ។

២. ប្រសិនបើក្រុមហ៊ុនបានប្រព្រឹត្តល្មើសនឹងខ្លឹមសារនៃប្រកាសនេះ ធនាគារជាតិនៃកម្ពុជា អាចចាត់វិធានការកែតម្រូវក្នុងរយៈពេលកំណត់មួយ។ ក្នុងករណីក្រុមហ៊ុនមិនអាចអនុវត្តបានតាមពេលកំណត់ ឬសកម្មភាពរបស់ក្រុមហ៊ុនអាចប៉ះពាល់ដល់ស្ថិរភាពប្រតិបត្តិការ ឬប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់អតិថិជន ធនាគារជាតិនៃកម្ពុជានឹងចាត់វិធានការ ដូចជា ផ្អាកដំណើរការអាជីវកម្ម និងកំណត់សិទ្ធិរបស់ភាគទុនិក ជាដើម ផ្អែកទៅលើស្ថានភាពជាក់ស្តែង និងស្របតាមបទប្បញ្ញត្តិជាធរមាន។

**ប្រការ ១៧.- ពិន័យអន្តរការណ៍**

បន្ថែមលើទណ្ឌកម្មខាងវិន័យ ធនាគារជាតិនៃកម្ពុជានឹងដាក់ពិន័យអន្តរការណ៍ដូចខាងក្រោម៖

១. ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ដែលមិនបានគោរពតាមកាលកំណត់នៃការបញ្ជូនរបាយការណ៍នឹងត្រូវពិន័យដូចខាងក្រោម៖

ក. ចំពោះរបាយការណ៍៖

| <u>ចំនួនថ្ងៃដែលយឺតយ៉ាវ</u> | <u>ចំនួនទឹកប្រាក់</u> |
|---|---|
| ▪ ពី ១ទៅ ៥ ថ្ងៃ | ៥០.០០០ រៀល (ហាសិបពាន់រៀល) ក្នុងមួយថ្ងៃ |
| ▪ ពី ៦ទៅ ១០ ថ្ងៃ | ៣០០.០០០ រៀល (បីរយពាន់រៀល) ក្នុងមួយថ្ងៃ |
| ▪ ពី ១១ទៅ ១៥ ថ្ងៃ | ៧០០.០០០ រៀល (ប្រាំពីររយពាន់រៀល) ក្នុងមួយថ្ងៃ។ |

លើសពី១៦ថ្ងៃឡើងទៅ ក្រុមហ៊ុនត្រូវរងបន្ថែមនូវការព្រមានជាលាយលក្ខណ៍អក្សរ និងការផ្សព្វផ្សាយជាសាធារណៈ។

ខ.ចំពោះលិខិតឆ្លើយតប និងការផ្តល់ព័ត៌មានផ្សេងៗ ៖

| <u>ចំនួនថ្ងៃដែលយឺតយ៉ាវ</u> | <u>ចំនួនទឹកប្រាក់</u> |
|---|---|
| ▪ ពី ១ទៅ ៥ ថ្ងៃ | ៥០.០០០ រៀល (ហាសិបពាន់រៀល) ក្នុងមួយថ្ងៃ |
| ▪ ពី ៦ទៅ ១០ ថ្ងៃ | ៣០០.០០០ រៀល (បីរយពាន់រៀល) ក្នុងមួយថ្ងៃ។ |

លើសពី១១ថ្ងៃឡើងទៅ ក្រុមហ៊ុនត្រូវរងបន្ថែមនូវការព្រមានជាលាយលក្ខណ៍អក្សរ និងការផ្សព្វផ្សាយជាសាធារណៈ។

២. ការល្មើសនឹងបទប្បញ្ញត្តិជាធរមាន ត្រូវពិន័យទឹកប្រាក់ ១.០០០.០០០ រៀល (មួយលានរៀល) ក្នុងមួយថ្ងៃ គិតចាប់ពីថ្ងៃប្រសិទ្ធភាពដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**ប្រការ ១៨**.-

បុគ្គល ឬក្រុមហ៊ុនដែលបាន និងកំពុងធ្វើអាជីវកម្មភតិសន្យាហិរញ្ញវត្ថុដោយមិនមានអាជ្ញាបណ្ណ ត្រូវស្នើសុំអាជ្ញាបណ្ណពីធនាគារជាតិនៃកម្ពុជាក្នុងរយៈពេល ៦ខែ (ប្រាំមួយខែ) គិតចាប់ពីថ្ងៃដែលប្រកាសនេះចូលជាធរមាន។

**ប្រការ ១៩**.-

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ២០**.-

ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

# ឧបសម្ព័ន្ធទី ២

# គម្រូតារាងបង់រំលស់របស់ក្រុមហ៊ុន

# តូយ៉ូតាកម្ពុជាហ្វាយនែន

( TOYOTA CAMBODIA FINANCE )

# Leasing Price Table

Last update: May 20, 2021

| Model | Advance Payment | Payment Duration | | | | |
|---|---|---|---|---|---|---|
| | | 12 Months | 24 Months | 36 Months | 48 Months | 60 Months |
|  COROLLA CROSS | $24,950 | $2,204 | $1,168 | $828 | $656 | $554 |
| | $19,960 | $2,645 | $1,401 | $993 | $787 | $664 |
| | $14,970 | $3,086 | $1,635 | $1,159 | $918 | $775 |
| | $9,980 | $3,526 | $1,868 | $1,324 | $1,049 | $886 |
|  REVO-PREMIUM | $24,950 | $2,204 | $1,168 | $822 | $656 | $554 |
| | $19,960 | $2,645 | $1,401 | $993 | $787 | $664 |
| | $14,970 | $3,086 | $1,635 | $1,159 | $918 | $775 |
| | $9,980 | $3,526 | $1,868 | $1,324 | $1,049 | $886 |

# ឧបសម្ព័ន្ធទី៣

# បញ្ជីរាយនាមគ្រឹះស្ថានឥតិសន្យាហិរញ្ញវត្ថុ

# ធនាគារឯកទេស និងគ្រឹះស្ថាន

# មីក្រូហិរញ្ញវត្ថុនៅកម្ពុជា

# ឧបសម្ព័ន្ធទីទី៤
# កិច្ចព្រមព្រៀងប្រាតិភោគ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កិច្ចព្រមព្រៀងប្រាតិភោគ**

**ម្ចាស់សិទ្ធិប្រាតិភោគ៖** ឈ្មោះ..........ភេទ... អាយុ... ជនជាតិ... កាន់អត្តសញ្ញាណប័ណ្ណលេខ.......... ចុះថ្ងៃទី..... ខែ...... ឆ្នាំ.......... មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.......... ក្រុមទី... ភូមិ........ ឃុំ/សង្កាត់........ ស្រុក/ខណ្ឌ........... ខេត្ត/រាជធានី................ ជាម្ចាស់បំណុល ហៅកាត់ថា ភាគី "ក" ។

**អ្នកបង្កើតប្រាតិភោគ៖** ឈ្មោះ..........ភេទ... អាយុ... ជនជាតិ... កាន់អត្តសញ្ញាណប័ណ្ណលេខ.......... ចុះថ្ងៃទី..... ខែ...... ឆ្នាំ.......... មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.......... ក្រុមទី... ភូមិ........ ឃុំ/សង្កាត់........ស្រុក/ខណ្ឌ...........ខេត្ត/រាជធានី................ជាកូនបំណុល/អ្នកធានាកាតព្វកិច្ចដោយវត្ថុ ហៅកាត់ថា ភាគី "ខ" ។

**ភាគីទាំងពីរ បានព្រមព្រៀង និងឯកភាពគ្នាដោយសុឆន្ទៈអនុវត្តន៍តាមប្រការដូចខាងក្រោម៖**

**ប្រការ១៖** ភាគី "ក" បានឲ្យភាគី "ខ" ខ្ចីប្រាក់ចំនួន..................................ដុល្លាអាមេរិកគត់។

**ប្រការ២៖** ភាគី "ខ" បានទទួលប្រាក់ចំនួន ............................. ដុល្លាអាមេរិកគត់ ពីភាគី "ក"
នៅថ្ងៃទី... ខែ...... ឆ្នាំ..... សម្រាប់រយៈពេល............ គិតចាប់ពីថ្ងៃចុះកិច្ចសន្យារហូតដល់ ថ្ងៃទី... ខែ....... ឆ្នាំ............ នឹងត្រូវសងប្រាក់ជំពាក់ឲ្យមកភាគី "ក" វិញយ៉ាងយូរត្រឹមថ្ងៃទី..... ខែ......... ឆ្នាំ...........។

**ប្រការ៣៖** ថ្ងៃនេះ ភាគី "ខ" បានផ្ទេរកម្មសិទ្ធិនៃទ្រព្យសម្បត្តិដែលបានរៀបរាប់ខាងក្រោម (ការពណ៌នាពី "លក្ខណៈនៃទ្រព្យសម្បត្តិ") ទៅភាគី "ក" ក្នុងគោលបំណងធានាសិទ្ធិលើបំណុលរបស់ភាគី "ក" សម្រាប់ការទូទាត់សងប្រាក់ពីភាគី "ខ" ដែលបានខ្ចីដោយយោងលើប្រការ១ និង ប្រការ២ នៃកិច្ចសន្យានេះ។

## ការពណ៌នាពីលក្ខណៈនៃទ្រព្យសម្បត្តិ

**ប្រការ៤៖** ថ្ងៃនេះ ភាគី "ខ" បានផ្ទេរការកាន់កាប់នៃទ្រព្យសម្បត្តិទៅភាគី "ក" ដោយការប្តូរលក្ខណៈនៃការ កាន់កាប់។

**ប្រការ៥៖** ភាគី "ក" យល់ព្រម និងបានអនុញ្ញាតឲ្យភាគី "ខ" បន្តការកាន់កាប់ និងប្រើប្រាស់ទ្រព្យសម្បត្តិ នោះ ហើយភាគី "ខ" បានយល់ព្រម។

**ប្រការ៦៖** ភាគី "ខ" ត្រូវចាត់វិធានការសមស្របជូនដំណឹងជាសាធារណៈពីទ្រព្យសម្បត្តិដែលស្ថិតនៅក្រោម សិទ្ធិប្រាតិភោគដោយអនុប្បទានរបស់ភាគី "ក"។ ប្រសិនបើភាគី "ខ" មិនចាត់វិធានការណាមួយទេ នោះភាគី "ក" អាចចាត់វិធានការជំនួសភាគី "ខ" ហើយនៅក្នុងករណីនេះ ភាគី "ក" អាចទាមទារ សំណងនៃការចំណាយក្នុងការចាត់វិធានការនោះពី ភាគី "ខ"។

**ប្រការ៧៖** ក្នុងអំឡុងពេលខ្ចីប្រាក់ ភាគី "ខ" បានយល់ព្រមបង់ការប្រាក់ ............ ស្មើ .....% ក្នុងមួយខែ នៅលើចំនួនទឹកប្រាក់សរុបទៅភាគី "ក" យ៉ាងយូរនៅថ្ងៃទី.... ខែ...... ឆ្នាំ............។

**ប្រការ៨៖** ភាគី "ខ" នឹងបាត់បង់ផលប្រយោជន៍នៃការកំណត់ពេលនៅក្នុងករណីដូចខាងក្រោមនេះ៖

(១). ភាគី "ខ" បានផ្ទេរកម្មសិទ្ធិនៃទ្រព្យសម្បត្តិនោះទៅតតិយជនមួយដោយគ្មានការយល់ព្រម ពី ភាគី "ក"។

(២). ភាគី "ខ" ដកយកចេញវិធានការនៃការជូនដំណឹងតាមប្រការ៦ នៃកិច្ចសន្យានេះ។

**ប្រការ៩៖** ការកែប្រែណាមួយនៃកិច្ចសន្យា ឬបន្ថែមខ្លឹមសារផ្សេងៗអាចធ្វើទៅបាន លុះត្រាតែមានការយល់ ព្រម និងកិច្ចព្រមព្រៀងពីភាគីទាំងសងខាង។

# ឧបសម្ព័ន្ធទី៥

# ការពិពណ៌នាពីលក្ខណៈនៃទ្រព្យសម្បត្តិ

## ការពណ៌នាពីលក្ខណៈនៃទ្រព្យសម្បត្តិ

**ប្រការ៤៖** ថ្ងៃនេះ ភាគី "ខ" បានផ្ទេរការកាន់កាប់នៃទ្រព្យសម្បត្តិទៅភាគី "ក" ដោយការប្តូរលក្ខណៈនៃការ កាន់កាប់។

**ប្រការ៥៖** ភាគី "ក" យល់ព្រម និងបានអនុញ្ញាតឲ្យភាគី "ខ" បន្តការកាន់កាប់ និងប្រើប្រាស់ទ្រព្យសម្បត្តិ នោះ ហើយភាគី "ខ" បានយល់ព្រម។

**ប្រការ៦៖** ភាគី "ខ" ត្រូវចាត់វិធានការសមស្របជូនដំណឹងជាសាធារណៈពីទ្រព្យសម្បត្តិដែលស្ថិតនៅក្រោម សិទ្ធិប្រាតិភោគដោយអនុប្បទានរបស់ភាគី "ក"។ ប្រសិនបើភាគី "ខ" មិនចាត់វិធានការណាមួយទេ នោះភាគី "ក" អាចចាត់វិធានការជំនួសភាគី "ខ" ហើយនៅក្នុងករណីនេះ ភាគី "ក" អាចទាមទារ សំណងនៃការចំណាយក្នុងការចាត់វិធានការនោះពី ភាគី "ខ"។

**ប្រការ៧៖** ក្នុងអំឡុងពេលខ្ចីប្រាក់ ភាគី "ខ" បានយល់ព្រមបង់ការប្រាក់ ........... ស្មើ .....% ក្នុងមួយខែ នៅលើចំនួនទឹកប្រាក់សរុបទៅភាគី "ក" យ៉ាងយូរនៅថ្ងៃទី.... ខែ...... ឆ្នាំ ...........។

**ប្រការ៨៖** ភាគី "ខ" នឹងបាត់បង់ផលប្រយោជន៍នៃការកំណត់ពេលនៅក្នុងករណីដូចខាងក្រោមនេះ៖

(១). ភាគី "ខ" បានផ្ទេរកម្មសិទ្ធិនៃទ្រព្យសម្បត្តិនោះទៅតតិយជនមួយដោយគ្មានការយល់ព្រម ពី ភាគី "ក"។

(២). ភាគី "ខ" ដកយកចេញវិធានការនៃការជូនដំណឹងតាមប្រការ៦ នៃកិច្ចសន្យានេះ។

**ប្រការ៩៖** ការកែប្រែណាមួយនៃកិច្ចសន្យា ឬបន្ថែមខ្លឹមសារផ្សេងៗអាចធ្វើទៅបាន លុះត្រាតែមានការយល់ ព្រម និងកិច្ចព្រមព្រៀងពីភាគីទាំងសងខាង។

# ឧបសម្ព័ន្ធទី៦
# លំហូរនីតិវិធីនៃការបង្កើតប្រតិបត្តិការដែលមានកិច្ចធានា



បង្កើតប្រតិបត្តិការ
សុក្រឹត្យកម្ម
1. កិច្ចព្រមព្រៀងប្រាតិភោគ
2. កូនបំណុលត្រូវទទួលបានតម្លៃតប
3. កូនបំណុលមានសិទ្ធិលើទ្រព្យធានា
1. សុក្រឹតកម្មតាមរយៈការតម្កល់លិខិតជូនដំណឹង
2. សុក្រឹតកម្មតាមរយៈការកាន់កាប់
3. សុក្រឹតកម្មដោយស្វ័យប្រវត្តិ
អាទិភាពនៃសុក្រឹតកម្មត្រូវយកមកពិចារណាក្នុងករណីមានការប្រជែងសិទ្ធិ
កូនបំណុលអនុវត្តកាតព្វកិច្ច
កាតព្វកិច្ចបានរលត់
កូនបំណុលមិនអនុវត្តកាតព្វកិច្ច
ម្ចាស់បំណុលឃាត់ទុកធានា
ម្ចាស់បំណុលកាន់កាប់ទ្រព្យធានា
ម្ចាស់បំណុលប្រមូលទ្រព្យធានា
ម្ចាស់បំណុលជម្រះទ្រព្យធានា

# ឧបសម្ព័ន្ធទី៧
# តារាងនៃប្រតិបត្តិការដែលធ្វើសុក្រឹត្យកម្ម

| កម្មវត្ថុនៃកិច្ចសន្យា | វិធីក្នុងការធ្វើឱ្យកិច្ចសន្យាប្រាតិភោគនៃប្រតិបត្តិការដែលមានកិច្ចធានាមានសុក្រិតភាព | | |
|---|---|---|---|
| | ដោយការតម្កល់លិខិតជូនដំណឹង | ដោយការកាន់កាប់ | ដោយស្វ័យប្រវត្តិ |
| ទំនិញ | ✓ | ✓ | |
| លិខិតស្នាម | ✓ | ✓ | |
| ឯកសារកម្មសិទ្ធ | ✓ | ✓ | |
| ប័ណ្ណភាគហ៊ុន | ✓ | ✓ | |
| កិច្ចសន្យាលក់ដែលមានកិច្ចធានា | ✓ | ✓ | |
| ទំនិញប្រើប្រាស់ | | | ✓ |
| ផលនៃទ្រព្យ | | | ✓ |
| យានយន្តដែលមានលេខសេរី | ✓ | | |
| សិទ្ធិប្រាតិភោគលើរូបិយវត្ថុ | | ✓ | |

# ឧបសម្ព័ន្ធទី៨

# គម្រូលិខិតជូនដំណឹង

# លិខិតជូនដំណឹងពី ប្រតិបត្តិការមានកិច្ចធានា

ប្រភេទសិទ្ធិប្រាតិភោគ :សិទ្ធិប្រាតិភោគ
ទំហំម្ចាស់បំណុល:ប្រតិបត្តិការមានកិច្ចធានារបស់កូនបំណុលផ្ទាល់ខ្លួន ឬក្រុមគ្រួសារ
កាលបរិច្ឆេទដែលផុតកំណត់:1/2/2021 15:52:30

## ការចុះឈ្មោះជាលើកដំបូង

| លេខលិខិតជូនដំណឹង | កាលបរិច្ឆេទបង្កើត |
|---|---|
| 1000000404 | 3/2/2016 15:52:30 |

## កូនបំណុល

| ប្រភេទភាគី | អ្នកកំណត់អត្តសញ្ញាណ | អាស័យដ្ឋាន |
|---|---|---|
| ពលរដ្ឋ | 010199631 | 598 - Chraing Chamres Ti 1 - Rusey Keo - ភ្នំពេញ - កម្ពុជា |
| ពលរដ្ឋ | 010556293 | 598 - Chraing Chamres Ti 1 - Rusey Keo - ភ្នំពេញ - កម្ពុជា |

## ភាគីមានកិច្ចធានា

| ឈ្មោះ | អាស័យដ្ឋាន |
|---|---|
| ACLEDA Bank Plc. | Preah Monivong Blvd. - Srah Chork - Daun Penh - ភ្នំពេញ - កម្ពុជា |

## ប្រភេទទ្រព្យធានា

ផ្សេងទៀត

## ពិពណ៌នាទ្រព្យធានា

Inventory (All Kinds of Steel) as of date December 30, 2015.

# លិខិតជូនដំណឹងពី ប្រតិបត្តិការមានកិច្ចធានា

ប្រភេទសិទ្ធិប្រាតិភោគ :សិទ្ធិប្រាតិភោគ

ទំហំម្ចាស់បំណុល:កូនបំណុលដែលមានអាជីវកម្ម ជាមួយបុគ្គលិកចាប់ពី ៣០០នាក់ឡើង

កាលបរិច្ឆេទដែលផុតកំណត់:15/6/2021 10:38:31

## ការចុះឈ្មោះជាលើកដំបូង

| លេខលិខិតជូនដំណឹង | កាលបរិច្ឆេទបង្កើត |
|---|---|
| 1000000610 | 16/6/2016 10:38:31 |

## កូនបំណុល

| ប្រភេទភាគី | អ្នកកំណត់ភិនភាគ | អាស័យដ្ឋាន |
|---|---|---|
| នីតិបុគ្គលដែលបានចុះឈ្មោះ (ក្រុមហ៊ុន) | Co. 8923KH/2006 | No. 27DEF, Preah Monivong Blvd - Sangkat Srah Chork - Khan Daun Penh - ភ្នំពេញ - កម្ពុជា |

## ភាគីមានកិច្ចធានា

| ឈ្មោះ | អាស័យដ្ឋាន |
|---|---|
| MAYBANK (CAMBODIA) PLC | No.43, Preah Norodom Boulevard - Sangkat Phsar Thmey III - Khan Daun Penh - ភ្នំពេញ - កម្ពុជា |

## ប្រភេទទ្រព្យធានា

ផ្សេងទៀត

## ពិពណ៌នាទ្រព្យធានា

Debenture is to be created over all fixed and floating present and future assets of the company.

# លិខិតជូនដំណឹងពី ប្រតិបត្តិការមានកិច្ចធានា

ប្រភេទសិទ្ធិប្រាតិភោគ :សិទ្ធិប្រាតិភោគ

ទំហំម្ចាស់បំណុល: កូនបំណុលមានអាជីវកម្មជាមួយបុគ្គលិកតិចជាង១០នាក់

កាលបរិច្ឆេទដែលផុតកំណត់: 2/2/2021 10:43:13

## ការចុះឈ្មោះជាលើកដំបូង

| លេខលិខិតជូនដំណឹង | កាលបរិច្ឆេទបង្កើត |
|---|---|
| 1000000405 | 4/2/2016 10:43:13 |

## កូនបំណុល

| ប្រភេទភាគី | អ្នកកំណត់អត្តសញ្ញាណ | អាស័យដ្ឋាន |
|---|---|---|
| នីតិបុគ្គលដែលបានចុះឈ្មោះ (ក្រុមហ៊ុន) | Co.2815KH/1997 | 294 - Tonle Bassac - Chamkarmon - ភ្នំពេញ - កម្ពុជា |

## ភាគីមានកិច្ចធានា

| ឈ្មោះ | អាស័យដ្ឋាន |
|---|---|
| INDOCHINA ASSETS LIMITED | office of Trident Trust Company Limited - Trident Chambers, P.O Box 146 - Road Town - Tortola - |

## ប្រភេទទ្រព្យធានា

ផ្សេងទៀត

## ពិពណ៌នាទ្រព្យធានា

510 (Five Hundred Ten) shares in CAMBODIA INDOCHINA ASSETS CORPORATION PTE LTD. (C.I.A.L), a Private Limited Company incorporated under the laws of the Kingdom of Cambodia, with Registration Number Co. 3770KH/1998, dated 27 February 1998, having its registered address at No. 361E2E3 + 363E0E1E2 +365E0E1E2+367E0E1E2, Corner of Street 1 and Street 178, Sangkat Chey Chumneas, Khan Dun Penh, Phnom Penh, Kingdom of Cambodia.

# ឧបសម្ព័ន្ធទី៩

# គម្រូលិខិតសុំកែតម្រូវលិខិតជូនដំណឹង

## ការកែតម្រូវ

| ការកែតម្រូវ លេខលិខិតជូនដំណឹង | កាលបរិច្ឆេទបង្កើត |
|---|---|
| 4000000085 | 11/5/2016 15:23:42 |

## កូនបំណុល

| ប្រភេទភាគី | អ្នកកំណត់អត្តសញ្ញាណ | អាសយដ្ឋាន |
|---|---|---|
| នីតិបុគ្គលដែលបានចុះឈ្មោះ (ក្រុមហ៊ុន) | Co.2815KH/1997 | 294 - Tonle Bassac - Chamkarmon - ភ្នំពេញ - កម្ពុជា |

## ភាគីមានកិច្ចធានា

| ឈ្មោះ | អាសយដ្ឋាន |
|---|---|
| FCC HOTELS AND HOSPITALITY LTD. | P.O. Box 170 - Churchill Building - Front Street - Turks and Caicos Islands - |

## ប្រភេទទ្រព្យធានា

ផ្សេងទៀត

## ពិពណ៌នាទ្រព្យធានា

510 (Five Hundred Ten) shares in CAMBODIA INDOCHINA ASSETS CORPORATION PTE LTD. (C.I.A.L), a Private Limited Company incorporated under the laws of the Kingdom of Cambodia, with Registration Number Co. 3770KH/1998, dated 27 February 1998, having its registered address at No. 361E2E3 + 363E0E1E2 +365E0E1E2+367E0E1E2, Corner of Street 1 and Street 178, Sangkat Chey Chumneas, Khan Dun Penh, Phnom Penh, Kingdom of Cambodia.

## ភាគីដែលមានសិទ្ធិ

| AUTHORIZER | ប្រភេទភាគី | ឈ្មោះ | អាសយដ្ឋាន |
|---|---|---|---|
| ☑ | | INDOCHINA ASSETS LIMITED | office of Trident Trust Company Limited - Trident Chambers, P.O Box 146 – Road Town - Tortola |

# ឧបសម្ព័ន្ធទី១០
# គម្រូលិខិតសុំបញ្ឈប់លិខិតជូនដំណឹង

### Termination

| TERMINATION NOTICE NUMBER | CREATED DATE |
|---|---|
| 10011501 | 27 Jan 2015 19:10:09 |

### Securing Parties

| PARTY TYPE | IDENTIFIER | ADDRESS |
|---|---|---|

### Secured Parties

### Collateral categories

Vehicle

### Collateral Description

### Authorizing Parties

| AUTHORIZER | PARTY TYPE | NAME | ADDRESS |
|---|---|---|---|
| ☑ | | ANZ ROYAL BANK (CAMBODIA) LTD. | 20 KRAMUON SAR & CORNER OF STREET 67, PO BOX 624 - DAUN PENH - PHNOM PENH - CAMBODIA |

# ឧបសម្ព័ន្ធទី១១
# អាស័យដ្ឋានការិយាល័យតម្កល់លិខិត
# ជូនដំណឹង

ទំនាក់ទំនងតាមរយៈ ៖

- **ទូរស័ព្ទ៖** លោកអ្នកអាចទូរស័ព្ទមកកាន់ការិយាល័យតម្កល់ ប្រតិបត្តិការមានកិច្ចធានាតាមរយៈលេខ (៨៥៥) ២៣ ៨៦៦ ០៤៣។
- **អ៊ីមែល៖** ផ្ញើសារមកកាន់ការិយាល័យតម្កល់ setomoc.info@gmail.com
- **ទីតាំង៖** ឬអាចមកកាន់ការិយាល័យរដ្ឋបាលនៃការិយាល័យតម្កល់ ប្រតិបត្តិការមានកិច្ចធានា ដែលទីតាំងស្ថិតនៅជាន់ទីបីនៃអគារB ក្នុងក្រសួងពាណិជ្ជកម្ម ឡូត៍លេខ19-61 វិថីក្រសួងពាណិជ្ជកម្ម (113B) ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។
- លោកស្រី កឹម សារឿង ប្រធាននាយកដ្ឋាននីតិកម្ម ទូរស័ព្ទលេខ (855) 12 831 769។
- ការិយាល័យតម្កល់ លោក សៀង កុមិរ៉ា ទូរស័ព្ទលេខ (855) 12 723 645។